**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.លៀប លីស**

**កុល សុវិជ្ជា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.លៀប លីស**

**កុល សុវិជ្ជា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លៀប លីស** និងខ្ញុំបាទឈ្មោះ **កុល សុវិជ្ជា** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣ ។

ជាបឋមខ្ញុំបាទ និងនាងខ្ញុំ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិការ និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ចដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់ខ្ញុំទាំងពីរក្នុងរយៈពេលបួនឆ្នាំកន្លងមកដើម្បីឱ្យ ខ្ញុំបាទ និងនាងខ្ញុំ ទទួលបាននូវចំណេះដឹង ផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការ នៃការតាក់តែង កិច្ចការស្រាវជ្រាវនេះឡើង ប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះ គាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិយើង រួមទាំងប្រជាជនកម្ពុជាទាំងអស់ជួបតែសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍរីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍។

# អារម្ភកថា

ក្រោយពីបានសិក្សា និងឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល ០៤ឆ្នាំ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នូវមុខវិជ្ជាជាច្រើន ដែលទាក់ទងនឹងវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយអ្វីដែលពិសេសនោះ គឺទាក់ទងជាមួយនឹងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យខ្ញុំបាទ និងនាងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងទូលំទូលាយ ប្រកបដោយភាពច្បាស់លាស់ ក្រោមការយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនានា។ ដោយមានការជ្រោមជ្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្ត ទាំងអស់នេះហើយ ទើបធ្វើឱ្យខ្ញុំបាទ និងនាងខ្ញុំ អាចឈានមកដល់ការចងក្រងសារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី២៣ និងដើម្បីចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួន ដល់និស្សិតជំនាន់ក្រោយផង។ ក្នុងការសរសេរសារណា បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះខ្ញុំបាទ និងនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានប្រធានបទ "**នីតិវិធីនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ**"។

តាមរយៈការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទ និងនាងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងអាចជាឯកសារជំនួយស្មារតី ជាឯកសារសម្រាប់សិក្សាស្រាវជ្រាវរបស់មិត្តនិស្សិត និងផ្តល់អត្ថប្រយោជន៍ដល់អ្នកអានគ្រប់រូប ជាពិសេស គឺនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឱ្យកាន់តែស៊ីជម្រៅ ថែមទាំងមានភាពងាយស្រួលក្នុងការសិក្សាស្វែងយល់អំពី នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ឱ្យបានត្រឹមត្រូវជាក់លាក់តាមដំណាក់កាលនីមួយៗ និងស្របតាមច្បាប់ដែលចូលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយលើសពីនេះទៅទៀតផងនោះ គឺចង់បន្សល់ទុកនូវស្នាដៃមួយដើម្បីជាការចងចាំមួយ ដែលខ្ញុំបាទ និងនាងខ្ញុំ ក៏ធ្លាប់ជាអតីតនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះផងដែរ។

ទោះបីជាយ៉ាងណាក្តី ខ្ញុំបាទ និងនាងខ្ញុំ ក៏សូមធ្វើការខន្តី អភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយ ក្នុងប្រការណាមួយដោយអចេតនា ដូចជាការប្រើប្រាស់ពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងដោយអចេតនាណាមួយដែលមាននៅក្នុងសារណាមួយនេះទុកជាមុន ព្រោះខ្ញុំបាទ និងនាងខ្ញុំ ជឿជាក់ថាពិតជាគ្មានអ្វីដែលល្អឥតខ្ចោះនោះឡើយ ដូចនេះហើយត្រូវតែទទួលស្គាល់នូវកំហុសទាំងឡាយ និងទទួលយកនូវការកែតម្រូវរបស់លោកអ្នកអានតាមរយៈការផ្តល់ជាមតិយោបល់រិះគន់ ដើម្បីភាពស្ថាបនារបស់មិត្តៗនិស្សិត លោក លោកស្រីទាំងអស់ ដើម្បីឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** .......... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**

**១.១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ** .......... ៥

**១.១.១. អត្ថន័យនៃការអនុវត្តដោយបង្ខំ** .......... ៥

១.១.១.១. ប្រភេទនៃការអនុវត្តដោយបង្ខំ .......... ៦

១.១.១.២. កម្មវត្ថុនៃការអនុវត្តដោយបង្ខំ .......... ៧

**១.១.២. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ** .......... ១១

១.១.២.១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំ .......... ១១

១.១.២.២. លិខិតអនុវត្ត .......... ១១

១.១.២.៣. រូបមន្តអនុវត្ត .......... ១៥

១.១.២.៤. បណ្ដឹងតវ៉ាចំពោះការទាមទារ .......... ១៨

**១.២. ស្ថាប័នអនុវត្តនៃនីតិវិធីអនុវត្តដោយបង្ខំ** .......... ១៨

**១.២.១. ប្រភេទនៃស្ថាប័នអនុវត្ត** .......... ១៩

១.២.១.១. តុលាការអនុវត្ត .......... ១៩

១.២.១.២. អាជ្ញាសាលា .......... ២១

១.២.១.២. វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ .......... ២៥

**១.២.២. ភាគីនៃការអនុវត្ត និងអ្នកតំណាង** .......... ២៥

១.២.២.១. ភាគីអនុវត្ត .......... ២៥

១.២.២.២. អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីអនុវត្តដោយបង្ខំ .......... ២៦

**១.២.៣. នីតិវិធីប្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះការអនុវត្ត** .......... ២៦

១.២.៣.១. ការតវ៉ាចំពោះការអនុវត្ត .......... ២៦

១.២.៣.២. បណ្ដឹងជំទាស់ .......... ២៧

**១.៣. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** .......... ២៨

**១.៣.១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**............................................ ២៨
**១.៣.២. កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** ............................................ ២៩
១.៣.២.១. ដី ឬអគារ ............................................................................................ ២៩
១.៣.២.២. កម្មសិទ្ធិអរិភោគលើដី ឬអគារ ................................................................ ២៩
១.៣.២.៣. សិទ្ធិជួលអចិន្ត្រៃយ៍ចំពោះអចលនវត្ថុ.......................................................... ៣១
១.៣.២.៤. ផលុបភោគដែលត្រូវបានចុះបញ្ជី ................................................................ ៣៣

## ជំពូកទី២

## លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**២.១. នីតិវិធីនៃការដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ**............................................ ៣៥
២.១.១. លិខិតបញ្ជាក់ពីការបញ្ជូនលិខិតអនុវត្ត .......................................................... ៣៦
២.១.២. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ.......................................................... ៣៦
**២.២. ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ**.......................................... ៣៧
**២.៣. នីតិវិធីនៃការរឹបអូសចំពោះការអនុវត្តដោយបង្ខំ** ...................................................... ៣៧
២.៣.១. ការចុះបញ្ជីនៃការរឹបអូស និងរបាយការណ៍នៃការរឹបអូស...................................... ៣៨
២.៣.២. អានុភាពនៃការរឹបអូស................................................................................ ៣៨
២.៣.៣. នីតិវិធីវាយតម្លៃ និងគណនា ........................................................................ ៤០
**២.៣.៤. នីតិវិធីលក់ដោយបង្ខំ** ............................................................................ ៤១
២.៣.៤.១. ការលក់ឡាយឡុងដោយស្រោមសំបុត្រ.......................................................... ៤១
២.៣.៤.២. ការលក់ឡាយឡុងដោយផ្ទាល់មាត់............................................................... ៤២
២.៣.៥. នីតិវិធីចែកចំណែក .................................................................................. ៤៥
២.៣.៦.ការដាក់ប្រាតិភោគ និងការផ្ញើ ...................................................................... ៤៦
២.៣.៧. សោហ៊ុយសម្រាប់ការអនុវត្ត.......................................................................... ៤៦
**២.៤. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ** ........................................................ ៤៧
២.៤.១. ការផ្អាកកាអនុវត្តដោយបង្ខំ ........................................................................ ៤៧
២.៤.២. ការលុបចោលការអនុវត្តដោយបង្ខំ.................................................................. ៤៨
**២.៥. ទំនាក់ទំនងនៃការរក្សាការពារ និងការអនុវត្តដោយបង្ខំ**............................................... ៤៩
២.៥.១. ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ ........................................ ៥០

២.៥.២. ការប្តូរពីការរឹបអូសជាបណ្តោះអាសន្នទៅជាការអនុវត្តពិតប្រាកដ................................ ៥០
**សេចក្តីសន្និដ្ឋាន**........................................................................................................... ៥១
**អនុសាសន៍**.................................................................................................................. ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នីតិវិធីអនុវត្តដោយបង្ខំ គឺមានចែងក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។ តាមមាត្រា៩៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនេះនឹងត្រូវចូលជាធរមាននៅរាជធានីភ្នំពេញនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦និងនៅទូទាំងប្រទេសនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦។ ប៉ុន្តែយោងតាមមាត្រា៥៨៧នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា ក្រោយពីចូលធរមានក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ឆ្នាំទើបអនុវត្ត។ អាស្រ័យហេតុនេះ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុវត្តទាំងស្រុងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។

ជាទូទៅនៅពេលដែលមានវិវាទកើតឡើង យើងសង្កេតឃើញថា មានវិធីសាស្ត្រ ក៏ដូចជាយន្តការជាច្រើនក្នុងការដោះស្រាយវិវាទ ដែលជាគោលការណ៍ គេបែងចែកយន្តការដោះស្រាយវិវាទទាំងនោះជាពីរប្រភេទធំៗ គឺការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចជា ការចរចា ការផ្សះផ្សារ ឬតាមរយៈមជ្ឈត្តការ ឬតាមសន្ធានកម្ម និងការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ។ ហើយប្រសិនបើ នៅតែមិនអាចដោះស្រាយវិវាទតាមរយៈការប្រឹងប្រែងដោយស្ម័គ្រចិត្ត និងដោយឆន្ទៈរបស់ភាគីនៃវិវាទបានទេ ជម្រើសចុងក្រោយក្នុងការអនុវត្តសិទ្ធិគឺត្រូវពឹងពាក់តុលាការ ដែលជាស្ថាប័នរដ្ឋក្នុងការទាមទារសិទ្ធិរបស់ខ្លួន។ ដូច្នេះតុលាការជាស្ថាប័ន ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទ ហើយករណីបើមានការដាក់ពាក្យបណ្តឹងពីភាគីម្ខាងទៀត តុលាការត្រូវកោះហៅគូភាគីទាំងសងខាង ដើម្បីធ្វើការអះអាង ពិនិត្យ ភស្តុតាង ធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេច ដើម្បីឱ្យភាគីម្ខាងទៀតដែលជាអ្នកមានកាតព្វកិច្ចតាមផ្លូវច្បាប់ត្រូវតែគោរពតាម។

ម្យ៉ាងទៀតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលជាច្បាប់ទម្រង់មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ ដោយផ្អែកលើទៅច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ដើម្បីការពារសិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជន បើត្រឹមតែជាការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម និងសាលដីកានៅមិនទាន់គ្រប់គ្រាន់នោះទេ។ ហេតុនេះហើយ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលមានគោលបំណង នៃការការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចត្រូវផ្តល់តាវកាលិក ឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលបំណងសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ

តាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ជារបស់ស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច។ ហើយអ្វីដែលត្រូវបានរៀបចំឡើងនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដើម្បីបំពេញភាពចាំបាច់នេះ គឺជាការអនុវត្តដោយបង្ខំ។

នីតិវិធីអនុវត្តដោយបង្ខំ គឺជាយន្តការមួយ ដែលតាមរយៈនេះស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចជួយសម្រេចនូវសិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគចុងក្រោយរបស់ម្ចាស់បំណុល ដើម្បីទទួលបាននូវកម្មវត្ថុដែលជាការផ្តល់តាវកាលិកចុងក្រោយជូនទៅម្ចាស់បំណុល។ ការអនុវត្តដោយបង្ខំ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមានច្រើនប្រភេទ ប៉ុន្តែការអនុវត្តដោយបង្ខំ ដែលបាននឹងកំពុងតែពេញនិយមពីសំណាក់អ្នកច្បាប់ និងកំពុងតែអនុវត្តន៍ច្រើនជាងគេ គឺជាការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។ ហើយក្នុងសារណាបញ្ចប់ការសិក្សានេះ និងធ្វើការសិក្សាស្រាវជ្រាវទៅលើ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី **នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** បានផ្តោតសំខាន់ទៅលើកាលានុវត្តភាព និងសកម្មភាពនៃដំណើរការអនុវត្តរបស់ស្ថាប័នអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។ ការសិក្សាស្រាវជ្រាវនេះសំដៅជាសំខាន់ទៅលើបញ្ហាចំនួន ៣មានដូចជា៖

១. តើអ្វីទៅការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ? ហើយត្រូវមានល័ក្ខខណ្ឌអ្វីខ្លះ?ស្ថាប័នណាខ្លះមានសមត្ថកិច្ចក្នុងកាអនុវត្ត?

២. តើលំហូរនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុត្រូវចាប់ផ្តើមនៅពេលណា? ហើយបញ្ចប់ទៅវិញនៅពេលណា?

៣. តើការអនុវត្តការប្រគល់អចលនវត្ថុមានដំណើរការយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការជ្រើសរើសនូវប្រធានបទស្តីពី **នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** មកធ្វើការសិក្សាស្រាវជ្រាវសរសេរចេញជាសារណានេះ គឺក្នុងគោលបំណងសិក្សាឈ្វេងយល់ ពីក្របខណ្ឌបទដ្ឋានគតិយុត្តនៃបទប្បញ្ញត្តិស្តីពីការអនុត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលបាននឹងកំពុងអនុវត្តន៍ ជាធរមានក្នុងពេលសព្វថ្ងៃ បូករួមនឹងទ្រឹស្តីដែលបានសិក្សា តាមរយៈសាស្ត្រាចារ្យច្បាប់នៅក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់។ គោលបំណងសំខាន់នៃការសរសេរប្រធានបទខាងលើនេះដើម្បីស្វែងយល់អំពី៖

១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

២. ស្ថាប័នអនុវត្តចំពោះអចលនវត្ថុ។

៣. សិទ្ធិអំណាច និងករណីយកិច្ចនៃស្ថាប័នអនុវត្ត។

៤. សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។

៥. នីតិវិធីការចាប់ផ្ដើមអនុវត្តដោយបង្ខំ រហូតដល់នីតិវិធីបិទបញ្ចប់ការអនុវត្ត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ និងតាក់តែងនៅសារណាមួយនេះ បានផ្អែកទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ដែលបានចូលជាធរមាន និងមានវិសាលភាពអនុវត្តនៅ ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីដែល មានភាពស្មុគស្មាញ និងប្រើពេលវេលាវែងគួរសមក្នុងការអនុវត្ត។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបានក្ដោបរួមនូវ វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដូចជាៈដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ ដោយហេតុថា អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តនេះ មានវិសាលភាពយ៉ាងទូលំទូលាយ និងមាននីតិវិធីស្មុគស្មាញ ដូច្នេះការសិក្សាទៅលើប្រធានបទខាងលើនេះ គឺសិក្សាតែចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុជារួមតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងនេះក្ដី នៅក្នុងនីតិវិធីនៃការប្រគល់អចលនវត្ថុបន្ទាប់ពីការលក់ដោយបង្ខំ បទប្បញ្ញត្តិដែលទាក់ទងនឹងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ នៅក្នុងការអនុវត្តដោយបង្ខំ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ក៏ត្រូវបានលើកយកមកធ្វើការសិក្សាផងដែរ ដើម្បីគាំទ្រទៅលើបទប្បញ្ញត្តិស្ដីពីការប្រគល់អចលនវត្ថុ ដែលមានចែងតិចតួចផងដែរនៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក្នុងការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់។

## ៥. សារសំខាន់នៃការសិក្សាស្រាវជ្រាវ

លើសពីនេះទៅទៀតដើម្បីទទួលបានចំណេះដឹងខាងផ្នែកទ្រឹស្ដី និងចំណេះដឹងទាក់ទងនឹងការអនុវត្តជាក់ស្ដែង ព្រមទាំងទទួលបានបទពិសោធន៍នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ឱ្យកាន់តែមានភាពច្បាស់លាស់ជាងមុនថែមទៀត ការស្រាវជ្រាវប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ ខ្ញុំបាទ និងនាងខ្ញុំ ព្រោះដើម្បីឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ និងដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅកម្ពុជាឱ្យមានលក្ខណៈកាន់តែមានភាពប្រសើរឡើងថែមទៀតផង។ ជាពិសេសសង្ឃឹមថាសម្មិទ្ធិផល នៃការសិក្សាស្រាវជ្រាវប្រធានបទនេះអាចទុកជាឯកសារមួយសម្រាប់បងប្អូនដែលជានិស្សិតជំនាន់ក្រោយៗ ធ្វើការសិក្សាស្វែងយល់បន្ថែមអំពីនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់ និងមានភាពត្រឹមត្រូវបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាលើប្រធានបទនេះខ្ញុំបាទ និងនាងខ្ញុំ បានធ្វើការប្រមូលឯកសារគតិយុត្ត មានដូចជា៖ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ ឬសៀវភៅទាក់ទងនឹងនីតិវិធីការអនុវត្តចំពោះអចលនវត្ថុ។ បន្ថែមពីនេះទៅទៀត ក៏បានធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមួយចំនួនផ្សេងទៀតពីបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងឯកសារមួយចំនួនទៀតតាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចនានា។

បន្ទាប់ពីបានប្រមូលយកទិន្នន័យខាងលើរួចហើយនោះ ខ្ញុំបាទ និងនាងខ្ញុំ ក៏បានយកទិន្នន័យដែលបានទទួលយកមកធ្វើការសិក្សាវិភាគ និងប្រៀបធៀបជាមួយទ្រឹស្តីដែលបានសិក្សាកន្លងមកពីសាស្ត្រាចារ្យ ដើម្បីឈានទៅរក ការសន្និដ្ឋានជាមួយ ព្រមទាំងផ្តល់មតិយោបល់ ឬអនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះសារណាបញ្ចប់ការសិក្សារបស់ខ្ញុំទាំងពីរ បានធ្វើការបែកចេញជា ២ជំពូកដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** នៅក្នុងជំពូកនេះបានបែងចែកជា ៣ចំណុចបន្ថែមទៀត គឺចំណុចទី១ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ,ចំណុចទី២ ស្ថាប័នអនុវត្តនៃនីតិវិធីអនុវត្តដោយបង្ខំ, ចំណុចទី៣ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។

**ជំពូកទី២៖ លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** នៅក្នុងជំពូកនេះបានបែងចែកជា ៥ចំណុចបន្ថែមទៀត គឺចំណុចទី១ នីតិវិធីនៃការដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ, ចំណុចទី២ ដីកាសម្រេចការចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ, ចំណុចទី៣ នីតិវិធីចំពោះការរឹបអូសលក់ដោយបង្ខំ, ចំណុចទី៤ ការផ្អាក់ និងការលុបចោលការអនុវត្តដោយបង្ខំ, ចំណុចទី៥ ទំនាក់ទំនងការរក្សាការពារ និងការអនុវត្តដោយបង្ខំ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះ
# អចលនវត្ថុ

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

## ១.១. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

### ១.១.១. អត្ថន័យនៃការអនុវត្តដោយបង្ខំ

**ការអនុវត្តដោយបង្ខំ** ជានីតិវិធីអនុវត្តមួយដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដើម្បីធ្វើឱ្យបាន សម្រេចនូវសិទ្ធិតាមផ្លូវច្បាប់។ មានន័យថា ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវ សិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជន ដោយប្រើអំណាចរដ្ឋ ដែលសិទ្ធិទាមទារ សិទ្ធិប្រាតិភោគនោះមានកំណត់នៅក្នុងលិខិតអនុវត្ត។ អាចនិយាយបានថា ការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធមួយ ដែលមានលក្ខណៈបង្ខំដោយប្រើប្រាស់អំណាចរដ្ឋ ដើម្បីជួយសម្រេចសិទ្ធិរបស់បុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដោយផ្អែកតាមរដ្ឋធម្មនុញ្ញ បញ្ញត្តិក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី និងលិខិតបទដ្ឋាន គតិយុត្តិដទៃទៀត។

ការអនុវត្តដោយបង្ខំ ជានីតិវិធីឯករាជ្យមួយដែលអនុវត្តដោយអាជ្ញាធររដ្ឋផ្សេងពីអាជ្ញាធរ ដែលអនុវត្ត នីតិវិធីបណ្តឹង ដែលហៅក្នុងន័យចង្អៀតថា នីតិវិធីរដ្ឋប្បវេណី (នីតិវិធីដែលមានចែងចាប់ពីគន្ថីទី១ ដល់គន្ថីទី៤) ការអនុវត្តដោយបង្ខំមិនមែនជានីតិវិធីបន្ទាប់ ឬបន្តពីនីតិវិធីបណ្តឹងទេ តែគឺជានីតិវិធីឯករាជ្យមួយ ដែលចាប់ផ្តើម ដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុល ដែលត្រូវការឱ្យមានការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ របស់ខ្លួន។[១]

ការអនុវត្តដោយបង្ខំ មានលក្ខណៈស្រដៀងគ្នាទៅនឹងនីតិវិធីបណ្តឹងនៅត្រង់ថា នីតិវិធីនេះក៏ត្រូវបានអនុវត្ត ក្នុងលក្ខណៈជានីតិវិធីនៃការតទល់ ក្នុងនោះមានភាគីពីរ ដែលមានផលប្រយោជន៍ប្រឆាំងគ្នា បន្ថែមពីលើស្ថាប័នរដ្ឋ ដែលទទួលបន្ទុកក្នុងការផ្តល់យុត្តិធម៌។ ចំពោះស្ថាប័នរដ្ឋ ដែលមានតួនាទីក្នុងការធ្វើការអនុវត្តដោយបង្ខំហៅថា **ស្ថាប័នអនុវត្ត** ចំពោះភាគីទំនាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំវិញ ភាគីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយ បង្ខំហៅថា "**ម្ចាស់បំណុលនៃការអនុវត្ត**" ចាប់ពីត្រង់នេះតទៅ ហៅដោយសាមញ្ញថា "**ម្ចាស់បំណុល**" ចំណែកភាគី ម្ខាងទៀតហៅថា "**កូនបំណុលនៃការអនុវត្ត**" ចាប់ពីត្រង់នេះតទៅ ហៅដោយសាមញ្ញថា "**កូនបំណុល**"។ ប្រធាន នៃនីតិវិធីនៃការអនុវត្តដោយបង្ខំរួមមាន ស្ថាប័នអនុវត្ត ម្ចាស់បំណុល និងកូនបំណុល។ ក៏ប៉ុន្តែដោយសារថា នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលដាក់បន្ទុកនៃការអនុវត្តទៅលើកូនបំណុល ដើម្បីឱ្យសម្រេចនូវសិទ្ធិ ទាមទារ សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ឋានៈរបស់ភាគីទាំងពីរនៅក្នុងនីតិវិធីនេះ គឺមិនស្មើគ្នាទេ

[១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៤

ដោយខុសពីឋានៈរបស់ភាគីទាំងសងខាងនៅក្នុងនីតិវិធីបណ្តឹង ក៏ព្រោះតែនីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបានរៀបចំឡើងដោយផ្អែកលើការសន្មត់ថា ម្ចាស់បំណុល គឺជាបុគ្គលដែលមានសិទ្ធិ ហើយកូនបំណុល គឺជាបុគ្គលដែលមានកាតព្វកិច្ច តែមិនបានអនុវត្តកាតព្វកិច្ច ដូច្នេះគោលការណ៍នៃសិទ្ធិស្មើគ្នារវាងភាគី មិនត្រូវបានយកមកអនុវត្តនៅក្នុងនីតិវិធីនេះទេ។ លើសពីនេះទៅទៀត តតិយជន ផ្សេងពីបុគ្គលដែលបានរៀបរាប់ខាងលើ អាចចូលរួមនៅក្នុងដំណាក់កាលណាមួយ នៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ក្នុងឋានៈជាជនដែលមានផលប្រយោជន៍ពាក់ព័ន្ធបាន ប៉ុន្តែតតិយជននេះ មិនមែនជាប្រធាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំទាំងមូលនោះឡើយ។[២]

**១.១.១.១. ប្រភេទនៃការអនុវត្តដោយបង្ខំ**

ប្រភេទនៃការអនុវត្តដោយបង្ខំ ត្រូវបានចែកចេញជា ៣យ៉ាងធំៗ គឺការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ និងការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់។

❖ **ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់**

ជាគោលការណ៍ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ធ្វើឡើងដើម្បីរឹបអូសទ្រព្យរបស់កូនបំណុលនៃការអនុវត្ត ហើយបម្លែងជាប្រាក់រួចចែកទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត រួមទាំងម្ចាស់បំណុលទាំងអស់ដែលបានដាក់ពាក្យស្នើសុំចែកចំណែក។[៣]

ការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់មានដូចជា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងការអនុវត្តដោយបង្ខំចំពោះនាវា។

❖ **អនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ជាប្រភេទនៃការអនុវត្តមួយ ដែលជាគោលការណ៍ត្រូវអនុវត្តតាមបទប្បញ្ញត្តិទូទៅនៃការអនុវត្តដោយបង្ខំ ដែលមានចែងក្នុងជំពូកទី១ នៃគន្ថីទី៦។

ការអនុវត្តបង្ខំប្រភេទនេះ មានដូចជាការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត។[៤]

[២] ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៨, ជំពូកទី១ ការអនុវត្តដោយបង្ខំ និងច្បាប់ពាក់ព័ន្ធការអនុវត្តដោយបង្ខំ ផ្នែកទី១ ទំព័រទី២-៣

[៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, គន្ថីទី៦ ការអនុវត្តដោយបង្ខំ ជំពូកទី២

[៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, គន្ថីទី៦ ការអនុវត្តដោយបង្ខំ ជំពូកទី៣

❖ **ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់**

ផ្ទុយពីការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ គោលការណ៍នៃការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ពុំមានចរិតលក្ខណៈរឹបអូសវត្ថុ ឬសិទ្ធិរបស់កូនបំណុលនៃការអនុវត្តដើម្បីប្តូរជាប្រាក់នោះឡើយ តែវាមានចរិតលក្ខណៈដោយឡែកផ្សេងទៀត ដូចជាការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ ការអនុវត្តជំនួស ការអនុវត្តដោយប្រយោល ការបង្ហាញឆន្ទៈជាដើម។[៥]

**១.១.១.២. កម្មវត្ថុនៃការអនុវត្តដោយបង្ខំ**

កម្មវត្ថុនៃការអនុវត្តដោយបង្ខំមានបួនប្រភេទធំៗ គឺការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះនាវា និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។

❖ **ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**

កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានគោលបំណងឱ្យសងជាប្រាក់។ អចលនវត្ថុ គឺសំដៅលើដី អាគារ ដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនៃសិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនោះ គឺជាសិទ្ធិរួម។ ជាទូទៅវត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលអាចក្លាយជាភាគមួយនៃដី ជាពិសេសអាគារសំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរទីតាំងបាន ឬពូជដែលសាបនៅលើដីដំណាំដែលបានដាំ រុក្ខជាតិដែលនៅលើដី គឺជាសមាសភាគនៃដី លុះត្រាតែមិនអាចបំបែកបានចេញពីដីទេ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានទេ លើកលែងតែមានបញ្ញត្តិផ្សេងបានចែង។ ចំពោះការចាត់ទុកអាគារ មិនមែនជាអចលនវត្ថុឯករាជ្យ គឺអាស្រ័យទៅលើ គោលនយោបាយនីតិកម្មរបស់ប្រទេសផ្សេងៗគ្នា។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាចែងថាៈ អាគារ គឺជាសមាសភាគនៃដី ពោលគឺអាគារមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលមានលក្ខណៈជាអចលនវត្ថុឯករាជ្យបានឡើយ។[៦]

ប៉ុន្តែមានករណីដែលអាចចុះបញ្ជី អាគារ គឺជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យបានដែរ ដោយសារតែមានកាលៈទេសៈពិសេសដែលថា ដី មិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិតាមច្បាប់រដ្ឋប្បវេណីទេ នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដូចជារាជធានីភ្នំពេញ។ ក្នុងករណីបែបនេះហើយទើបអាគារ ដែលត្រូវបានចុះបញ្ជីក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំបានដែរ។ រីឯអាគារ ដែលមិនបានចុះបញ្ជីនោះ គឺជាសមាសភាគនៃកម្មសិទ្ធិលើដី ឬសមាសភាគនៃសិទ្ធិប្រត្យក្សប្រើប្រាស់ដី សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ ដែលមិនអាច

[៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, គន្ថីទី៦ ការអនុវត្តដោយបង្ខំ ជំពូកទី៤

[៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤១៧

ក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដោយឯករាជ្យបាន។ ដោយសារថាអានុភាពនៃការអនុវត្តដោយបង្ខំចំពោះកម្មសិទ្ធិលើដី ឬចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ដីមាននៅលើអាគារ ដែលជាសមាសភាគនៃសិទ្ធិនោះដែរ។ អាគារទាំងនោះនឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងកម្មសិទ្ធិលើដី ឬសិទ្ធិប្រត្យក្សប្រើប្រាស់នៃដី។[៧]

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីដែលមានលក្ខណៈស្មុគស្មាញជាងគេ។ ការអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬទីទំនេរណាមួយឱ្យទៅម្ចាស់បំណុលនៃការអនុវត្ត ឬតតិយជន។

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះត្រូវធ្វើឡើងដោយវិធីលក់ដោយបង្ខំ ពោលគឺតុលាការអនុវត្តរឹបអូសអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយយកប្រាក់ដែលបានមកពីការលក់ទៅសងម្ចាស់បំណុល។[៨]

❖ **ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

ចលនវត្ថុតាមក្រមរដ្ឋប្បវេណី សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុទាំងឡាយដែលរួមមានដូចជា រូបិយវត្ថុ និងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចទទួលបានផលយ៉ាងច្បាស់ នៅក្នុងអំឡុងពេល ១(មួយ)ខែ។[៩]ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវធ្វើឡើងតាមការរឹបអូសយកវត្ថុ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តដោយអាជ្ញាសាលា។[១០] ប៉ុន្តែនៅក្នុងករណី ដែលចលនវត្ថុនោះត្រូវបានកាន់កាប់ដោយតតិយជន អាជ្ញាសាលាអាចរឹបអូសបានលុះត្រាតែ តតិយជននោះមិនបដិសេធក្នុងការប្រគល់។[១១]

ជាគោលការណ៍ ការរឹបអូសចលនវត្ថុអាចធ្វើបានតែចំពោះទ្រព្យរូបិយ ឬទ្រព្យអរូបិយទាំងឡាយណាដែលធ្លាក់ទៅលើកូនបំណុលតែប៉ុណ្ណោះ ដែលមានន័យថាទ្រព្យសម្បត្តិទាំងអស់នោះរបស់កូនបំណុលនៃការអនុវត្ត អាចក្លាយជា កម្មវត្ថុនៃការរឹបអូសបានតែក្នុងករណីដែលមានមូលហេតុពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី ក៏មានទ្រព្យសម្បត្តិមួយចំនួនដែលច្បាប់បានហាមឃាត់មិនឱ្យរឹបអូសមានដូចខាងក្រោម៖

- សម្លៀកបំពាក់ សម្ភារៈដំណេក តុ ទូ សម្ភារៈសម្រាប់ដាំស្ល និងសម្ភារៈសំរាប់ឃាំងនៅ បន្ទប់របស

[៧] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២២

[៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤១៩.កថាខណ្ឌ១

[៩] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា១២០ កថាខណ្ឌ៣

[១០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៨៥ កថាខណ្ឌ១

[១១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៨៦

កូនបំណុលនៃកាអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នាជាដើម។

- គ្រឿងបរិភោគ និងទំហំនៃវត្ថុដែលត្រូវកាជារចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល ២ (ពីរ)ខែ របស់កូនបំណុលនៃការអនុវត្ត រួមទាំងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តមានជីវភាពរួមគ្នាជាដើម។
- របបឧបត្ថម្ភខាងផ្នែកជីវភាព របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភផ្នែកសុខភាព និងប្រាក់ ឬវត្ថុឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬអាជ្ញាធរដែនដីដើម្បីការពារដល់ជីវភាពរស់នៅរបស់កូនបំណុលនៃការអនុវត្ត។
- ផ្នែកប្រាក់តិចជាង ឬស្មើនឹង ១,០០០,០០០(មួយលាន)រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុចខាងលើនេះ។
- ឧបករណ៍ ជី សត្វពាហនៈ ដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និងចំណីសត្វទាំងនេះ ព្រមទាំងគ្រាប់ពូជ ឬកសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចំបាច់សម្រាប់បន្តការងារកសិកម្ម រហូតដល់រដូវទទួលបានផលបន្ទាប់របស់កសិករក្នុងការប្រកបកសិកម្ម។
- មង សំណាញ់ ឬនេសាទុបករណ៍ផ្សេងៗ ដែលចាំបាច់ ចំណី និងកូនត្រី ឬជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ។
- ឧបករណ៍ និងវត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និងអ្នកផ្សេងទៀត ដែលប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម ដោយកំលាំងប្រាជ្ញា និងកម្លាំងកាយ។ ប៉ុន្តែបើជាវត្ថុ ដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់លក់ ឬជួលវិញអាចរឹបអូសបាន។
- ព្រះពុទ្ធរូប ក្បួនរីយ៍សាសនា និងវត្ថុផ្សេងៗដែលចំបាច់សម្រាប់ពិធីក្នុងសាសនា។
- ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និងឯកសារប្រភេទដូចគ្នាផ្សេងទៀត ដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត។
- គ្រឿងឥស្សរិយស និងប័ណ្ណសរសើរផ្សេងឯទៀតរបស់កូនបំណុលនៃការអនុវត្ត ឬរបស់ញាតិរបស់ជននោះ។
- ឯកសារ និងឧបករណ៍ដែលចាំបាច់ក្នុងការសិក្សានៅសាលារៀន ឬនៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។
- វត្ថុដែលទាក់ទងទៅនឹងតក្កកម្ម ឬស្នាដៃនិពន្ធដែលមិនទាន់បានផ្សាយជាសាធារណៈ។

- អវៈយវៈសិប្បនិមិត្ត សរីរាង្គសប្បនិមិត្តផ្សេងទៀត និងឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀតដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាពរួមគ្នា។
- ម៉ាស៊ីន ឬឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជម្លៀសខ្លួនពេលមានអាសន្ន ឬឧបករណ៍ផ្សេងទៀតសម្រាប់អាគារ ឬសំណង់ផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងៗតម្រូវឱ្យមានបរិក្ខាដើម្បីបង្ការមហន្តរាយ និងការពារសន្តិសុខ។[១២]

❖ **ការអនុវត្តដោយបង្ខំចំពោះនាវា**

នាវាសំដៅទៅលើជលយាន ដែលមានចំណុះសរុបជាតោនស្មើនឹង ឬលើសពី២០តោន និងជលយានដែលមានចំណុះសរុបគិតជាតោនក្រោម ២០តោន ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះជលយានដែលមានចំណុះសរុបជាតោនស្មើនឹង ឬលើសពី២០តោននោះ ទោះបីជាមិនបានចុះបញ្ជីក៏ដោយក៏ចាត់ទុកជា នាវាក្នុងន័យក្រមរដ្ឋប្បវេណីដែរ។ នាវា ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះនាវានៅទីនោះ សំដៅទៅលើនាវាដែលមានរចនាសម្ព័ន្ធជាក់លាក់មួយ និងមានសមត្ថភាពអាចធ្វើដំណើរតាមផ្លូវទឹក ដើម្បីដឹកអ្នកដំណើរ ឬវត្ថុផ្សេងៗបាន។[១៣]

នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើឡើងដោយតុលាការអនុវត្តតាមរយៈវិធីលក់ដោយបង្ខំ ហើយតុលាការអនុវត្តដែលមានសមត្ថកិច្ចលើការអនុវត្តដោយបង្ខំចំពោះនាវា គឺសាលាដំបូងនៃទីកន្លែងដែលនាវាស្ថិតនៅជាអ្នកមានសមត្ថកិច្ចនៅពេលចេញដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ។[១៤]

❖ **ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចបាននូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល ឬប្រគល់ចលនវត្ថុហៅថា ការអនុវត្តសិទ្ធិលើបំណុលតាមរយៈការរឹបអូស សិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងជាប្រាក់ ប៉ុន្តែប្រសិនបើតតិយជនដែលកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត មិនព្រមប្រគល់ចលនវត្ថុនោះ ការអនុវត្តដោយបង្ខំត្រូវបានធ្វើដោយមិនអាចធ្វើតាមការអនុវត្តចំពោះចលនវត្ថុទេ ត្រូវធ្វើតាមការអនុវត្តចំពោះសិទ្ធិលើបំណុល។ គឺកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសហៅថា **កូនបំណុលទី៣**។ តុលាការអនុវត្តមានសមត្ថកិច្ចធ្វើការអនុវត្ត ចំពោះសិទ្ធិលើ

---

[១២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៨០

[១៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៥៤

[១៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៥៥ កថាខណ្ឌ១

បំណុលត្រូវកំណត់តាមលំនៅឋានរបស់កូនបំណុលនៃការអនុវត្ត។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តគ្មានលំនៅឋាននៅក្នុងប្រទេសកម្ពុជាទេ គឺត្រូវយកលំនៅឋានទី៣ ដើម្បីកំណត់ជាមូលដ្ឋាន។[១៥]

### ១.១.២. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

#### ១.១.២.១. ពាក្យសុំឱ្យអនុវត្តដោយបង្ខំ

ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមពាក្យសុំរបស់ភាគី ហើយពាក្យសុំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ការសរសេរពាក្យសុំ ឱ្យអនុវត្តចំពោះអចលនវត្ថុ ដែលក្នុងនោះម្ចាស់បំណុលនៃការអុវត្ត ត្រូវសរសេរដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកកំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត៖ អាចសរសេរបញ្ជាក់អំពីប្រភេទនៃលិខិតអនុវត្ត ប្រភពនៃលិខិតអនុវត្ត រួមទាំងកាលបរិច្ឆេទនៃលិខិតអនុវត្តជាដើម។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ដែលក្នុងករណីនេះម្ចាស់បំណុលនៃការអនុវត្តមិនចាំបាច់រៀបរាប់លម្អិតអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តក៏បាន ពោលគឺម្ចាស់បំណុលនៃការអនុវត្តគ្រាន់តែបញ្ជាក់អំពីទីតាំងនៃអចលនវត្ថុរបស់កូនបំណុល គឺគ្រប់គ្រាន់ហើយ។[១៦]

#### ១.១.២.២. លិខិតអនុវត្ត

ជាគោលការណ៍ ការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយលិខិតអនុវត្ត។ មានន័យថាស្ថាប័នអនុវត្តពុំអាចចាប់ផ្តើមការអនុវត្តបានទេ បើពុំមានលិខិតអនុវត្តភ្ជាប់ជាមួយនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ លើកលែងតែការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ដែលអាជ្ញាសាលាអាចធ្វើការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគមកឱ្យអាជ្ញាសាលា ឬដាក់លិខិតបញ្ជាក់ថាអ្នកកាន់កាប់អចលនវត្ថុនោះ យល់ព្រមប្រគល់ឱ្យអាជ្ញាសាលាជាការស្រេច។ រីឯការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុត្រូវធ្វើឡើងដោយលិខិតអនុវត្ត។

**ក. និយមន័យ**

លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលបានកំណត់នៅក្រោមនីតិឯកជន លិខិតនេះ គឺច្បាប់ផ្តល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្តដើម្បីសម្រេចនូវអត្ថន័យ នៃសិទ្ធិ

---

[១៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤០២

[១៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤៩

តាមរយៈការអនុវត្តដោយបង្ខំ។[១៧]

ចំពោះខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំ ត្រូវកំណត់ដោយផ្អែកទៅលើលិខិតអនុវត្ត ដោយអាស្រ័យទៅតាមស្ថានភាពផ្សេងៗ។ ខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំអាចត្រូវបានកម្រិត ឬបន្ថែមដោយរូបមន្តអនុវត្ត។

**ខ. ប្រភេទនៃលិខិតអនុវត្ត**

ដើម្បីអនុវត្តដោយបង្ខំ លិខិតអនុវត្តជាឯកសារយ៉ាងសំខាន់មិនអាចខ្វះបាន។ លិខិតអនុវត្តមានច្រើនប្រភេទដូចជា៖

❖ **សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលបានចូលជាស្ថាពរ**

សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលចេញដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជា ហើយបានចូលជាស្ថាពរ ត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត។[១៨] ក្នុងចំណោមសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ មានតែសាលក្រម ឬសាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិកប៉ុណ្ណោះដែលមានអានុភាពអនុវត្ត។ ទោះបីជា ក្នុងករណីសាលក្រម ឬសាលដីកាដែលពាក់ព័ន្ធជាសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយ ប្រសិនបើការអនុវត្តដោយបង្ខំ មិនអាចធ្វើទៅបានអាស្រ័យដោយចរិតលក្ខណៈនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក នោះមានន័យថាសាលក្រម ឬសាលដីកាពុំមានអានុភាពអនុវត្តទេ។

❖ **សាលក្រម ឬសាលដីកាចុងក្រោយ ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន**

នៅក្នុងលិខិតអនុវត្តចំពោះសាលក្រម ឬសាលដីកាចុងក្រោយ ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន គឺស្រដៀងគ្នាទៅនឹងករណីនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរដែរ ដោយសារថា ការអនុវត្តដោយបង្ខំ ដែលផ្អែកលើសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបង្ខំ និងធ្វើឱ្យមានការវិវត្តទៅដល់ការសម្រេចនូវសិទ្ធិទាមទារជាស្ថាពរ ដូច្នេះការសម្រេចសិទ្ធិនេះ មិនមានលក្ខណៈបណ្តោះអាសន្នទេ។[១៩]

❖ **ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក**

ជាគោលការណ៍ ដីកាសម្រេចមានអានុភាពអនុវត្តភ្លាមបន្ទាប់ពីបានធ្វើការជូនដំណឹង។ ប្រសិនបើដីកាសម្រេចនោះ គឺជាដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ដីកាសម្រេចនោះត្រូវមានអានុភាពអនុវត្ត។ ក៏ប៉ុន្តែដីកា

---

[១៧] ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨, ជំពូកទី១ ការអនុវត្តដោយបង្ខំ និងច្បាប់ពាក់ព័ន្ធការអនុវត្តដោយបង្ខំ ផ្នែកទី៤ កថាភាគ២ ទំព័រទី៣៧

[១៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុច ក

[១៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុច ខ

សម្រេចដែលត្រូវបានកំណត់ថាមិនមានអានុភាពបើមិនទាន់ចូលជាស្ថាពរ មិនអាចក្លាយជាលិខិតអនុវត្តបានទេ រហូតដល់ពេលចូលជាស្ថាពរ។[២០]

❖ **ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន**

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យ សុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេលពីរសប្តាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬប្រសិនបើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរ នោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននឹងត្រូវបានភ្ជាប់ជាមួយដីកាសម្រេចដាស់តឿន ហើយដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបណ្តោះអាសន្ននោះ និងក្លាយទៅជាលិខិតអនុវត្ត។[២១]

❖ **ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលកំណត់អំពីចំនួនប្រាក់ប្រដាប់ក្តី**

បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគ និងបន្ទុកនៃប្រាក់ប្រដាប់ក្តីហើយ ចំនួនទឹកប្រាក់លម្អិតត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូង តាមពាក្យសុំរបស់ភាគី។ ភាគីម្ខាងអាចធ្វើការអនុវត្តដោយបង្ខំឱ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្តី ដោយយកការចាត់ចែងរបស់ក្រឡាបញ្ជីនេះធ្វើជាលិខិតអនុវត្ត។[២២]

❖ **លិខិតយថាភូតដែលធ្វើឡើងដោយសារការី**

លិខិតយថាភូត ដែលធ្វើដោយសារការី និងដែលបានបំពេញតាមលក្ខខណ្ឌទាមទារមួយចំនួន ត្រូវបានទទួលស្គាល់ថាមានអានុភាពអនុវត្តក្នុងលក្ខណៈជាលិខិតអនុវត្តហៅថា លិខិតបញ្ជាក់អនុវត្ត។[២៣] ដោយសារថាការអនុវត្តដោយបង្ខំ អាចធ្វើឡើងបានភ្លាមដោយពុំចាំបាច់ឆ្លងកាត់តាមបណ្តឹង។

ម៉្យាងវិញទៀត ទោះបីជាលិខិតយថាភូតដែលធ្វើដោយសារការី ត្រូវបានធ្វើឡើងដោយយកសុពលភាពនៃកិច្ចសន្យានៅក្រោមច្បាប់សារធាតុមកជាបុរេលក្ខខណ្ឌក៏ដោយ លិខិតនេះមិនកំណត់ជាស្ថាពរនូវសុពលភាពនៃកិច្ចសន្យាទេ ពោលគឺមិនដូចគ្នាទៅនឹងសាលក្រម ឬសាលដីកាស្ថាពរឡើយ។ វាគ្រាន់តែជាសិទ្ធិអំណាចនៅក្នុងការត្រួតពិនិត្យរបស់សារការី ដែលត្រូវបានកម្រិតប៉ុណ្ណោះ ដោយហេតុថាលិខិតយថាភូតធ្វើដោយសារការីត្រូវបានធ្វើឡើងមិនផ្អែកទៅលើការពិនិត្យ និងទទួលស្គាល់អង្គហេតុ និងការសម្រេចសេចក្តីតាមផ្លូវច្បាប់របស់ចៅក្រមទេ។ អាស្រ័យហេតុនេះហើយ ដោយសារថាលទ្ធភាព ដែលនាំឱ្យមានការអនុវត្តមិនត្រឹមត្រូវនេះមានទ្រង់ទ្រាយធំទើបអានុភាពអនុវត្តត្រូវបានទទួលស្គាល់តែចំពោះលិខិតយថាភូត ធ្វើដោយសារការី ដែលមាន

[២០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុច គ

[២១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុ ឃ

[២២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុ ង

[២៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុ ច

កម្មវត្ថុដែលជាសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ ព្រោះវាមានភាពងាយស្រួលក្នុងការធ្វើបដិទាននូវផលប្រយោជន៍ដែលបានទទួលដោយសារការអនុវត្តដោយបង្ខំ ឬក្នុងការសងសំណងនៃការខូចខាតប្រសិនបើការអនុវត្តដោយបង្ខំនោះធ្វើឡើងដោយមិនត្រឹមត្រូវ។

❖ **សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តបានចូលជាស្ថាពរ**

លិខិតអនុវត្តអាចជាសាលក្រម ដែលផ្តល់អានុភាពស្ថាពរទៅឱ្យសាលក្រម ឬសាលដីការបស់តុលាការបរទេស ប្រសិនបើសាលក្រម ឬសាលដីការបរទេស បានបំពេញគ្រប់លក្ខខណ្ឌនាំឱ្យសាលក្រម ឬសាលដីកាបរទេសនោះ ត្រូវបានទទួលស្គាល់នូវអានុភាព ដូចទៅនឹងសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការកម្ពុជាដែរ។[២៤] ក្នុងករណីដែលអានុភាពនៃសាលក្រម ឬសាលដីកាបរទេសក្លាយទៅជាបញ្ហាវិវាទនៅក្នុងនីតិវិធីបណ្តឹងនៅក្នុងតុលាការកម្ពុជា នោះតុលាការដែលទទួលបន្ទុកនូវបណ្តឹងនេះ គ្រាន់តែធ្វើការវិនិច្ឆ័យថា តើលក្ខខណ្ឌទាមទារនេះ មាត្រា១៩៩ ត្រូវបានបំពេញគ្រប់ដែរឬទេ នោះ គឺជាការគ្រប់គ្រាន់ហើយ។

ប្រសិនបើមានការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្អែកទៅលើសាលក្រម ឬសាលដីកាបរទេស នោះការវិនិច្ឆ័យអំពីលក្ខខណ្ឌទាមទារសម្រាប់ការទទួលស្គាល់សាលក្រម ឬសាលដីកាបរទេស នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ពុំមែនជាទង្វើត្រឹមត្រូវឡើយ ព្រោះថាស្ថាប័នដែលផ្តល់រូបមន្តអនុវត្ត និងស្ថាប័នអនុវត្តត្រូវបានបង្កើតឡើង ដោយផ្តោតភាពសំខាន់ទៅលើការសម្រេចនូវសិទ្ធិដែលមានលក្ខណៈ ឆាប់រហ័ស និងមានប្រសិទ្ធិភាព។

❖ **សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្ត ដែលបានចូលជាស្ថាពរ**

នីតិវិធីមជ្ឈត្តកម្ម គឺជានីតិវិធីនៃការដោះស្រាយវិវាទទៅជំនួសនីតិវិធីបណ្តឹងតាមផ្លូវតុលាការ ឬហៅថាការដោះស្រាយពិសេស ដែលចេញដោយមជ្ឈត្តករ ហៅថាមជ្ឈត្តវិនិច្ឆ័យដែលជាលទ្ធផលនៃនីតិវិធីនេះ ហើយមានអានុភាព ចងចំពោះភាគីដូចជាសាលក្រម ឬសាលដីកាស្ថាពរដែរ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើមានវិការៈនៅក្នុងនីតិវិធីមជ្ឈត្តកម្ម ភាគីអាចសុំឱ្យតុលាការលុបចោលមជ្ឈត្តវិនិច្ឆ័យបាន។

ភាពចាំបាច់នៃការទទួលស្គាល់ដោយតុលាការកម្ពុជា នូវអានុភាពនៃសេចក្តីសម្រេចមជ្ឈត្តករ ដោយចាត់ទុកថានេះ គឺជាបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្តីសម្រេច គឺដូចគ្នាទៅនឹងករណីនៃការអនុវត្តដោយបង្ខំតាមសាលក្រម ឬសាលដីកាបរទេសដែរ។ ក៏ប៉ុន្តែចរិតលក្ខណៈ និងគុណសម្បត្តិនៃនីតិវិធីមជ្ឈត្តកម្ម គឺការដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងឆាប់រហ័សតាមរយៈនីតិវិធីដែលមានលក្ខណៈបត់បែនដោយមជ្ឈត្តករជាបុគ្គលឯកជន។ ជាគោលការណ៍ ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍ របស់កូនបំណុលនៃ

[២៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥០ កថាខណ្ឌ២ ចំណុច ឆ

ការអនុវត្ត។ ក៏ប៉ុន្តែ ក្នុងករណីដែលពុំមានលំនៅឋានជាអាទិ៍ នាមតុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យរបស់កូនបំណុលនៃការអនុវត្ត ដែលអាចរឹបអូសបានស្ថិតនៅ។[២៥]

❖ **កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ**

កំណត់ហេតុនៃការទទួលស្គាល់ការទាមទារ និងកំណត់ហេតុនៃការសះជាតាមផ្លូវតុលាការ សុទ្ធតែត្រូវបានរាប់ចូលជាកំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ ។[២៦]

**១.១.២.៣. រូបមន្តអនុវត្ត**

ការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្អែកទៅលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។

**ក. អត្ថន័យនៃរូបមន្តអនុវត្ត**

រូបមន្តអនុវត្ត គឺជាប្រយោគដែលចេញដោយក្រឡាបញ្ជី ឬសារការី បានសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយវាបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាចអនុវត្តដោយបង្ខំឱ្យអនុវត្តនៃលិខិតអនុវត្តនោះ។ ជាគោលការណ៍ ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។[២៧]

**ខ. ប្រភេទនៃរូបមន្តអនុវត្ត**

ស្ថាប័នផ្តល់រូបមន្តអនុវត្ត អាចផ្តល់រូបមន្តអនុវត្តពីរបែប ឬពីរប្រភេទ គឺរូបមន្តអនុវត្តធម្មតា និងរូបមន្តអនុវត្តពិសេស។

❖ **រូបមន្តអនុវត្តធម្មតា**

រូបមន្តអនុវត្តធម្មតា សំដៅលើរូបមន្តទាំងឡាយណាមានលក្ខណៈខុសពីលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តពិសេសដែលបានរៀបរាប់ខាងក្រោម។

❖ **រូបមន្តអនុវត្តពិសេស**

រូបមន្តអនុវត្តពិសេសអាចត្រូវបានផ្តល់ឱ្យក្នុងករណីដែលៈ

- សិទ្ធិទាមទារដែលបានកំណត់ក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬពេលកំណត់

[២៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣

[២៦] ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៨, ជំពូកទី១ ការអនុវត្តដោយបង្ខំ និងច្បាប់ពាក់ព័ន្ធការអនុវត្តដោយបង្ខំ ផ្នែកទី៤ កថាភាគ២ ទំព័រទី៣៨-៤៥

[២៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៤

មិនពិតប្រាកដ។ លក្ខខណ្ឌបង្អង់ គឺជាលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតអនុវត្ត ដែលម្ចាស់បំណុលត្រូវបញ្ជាក់អំពីការបានបំពេញ ឬការមកដល់នៃពេលកំណត់មិនពិតប្រាកដ ទើបអាចធ្វើការអនុវត្តដោយបង្ខំ បាននាំឱ្យក្រឡាបញ្ជី ឬសារការីអាចចេញរូបមន្តអនុវត្តពិសេស ក្នុងករណីក្រឡាបញ្ជី ជាអ្នកចេញរូបមន្តអនុវត្តពិសេស ត្រូវតែទទួលបានសេចក្តីអនុញ្ញាតពីចៅក្រមដែលខ្លួនស្ថិតនៅជាមួយជាមុនសិន។

- ករណីម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត គឺជាបុគ្គលផ្សេងដែលកំណត់ក្នុងលិខិតអនុវត្ត ដូចជាអ្នកបន្តសិទ្ធិ ឬករណីកិច្ចជាដើម នាំឱ្យម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបានរូបមន្តអនុវត្តពិសេស (សរសេរនូវហេតុការណ៍បញ្ជាក់ក្នុងរូបមន្តអនុវត្ត)។[២៨]

**គ. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត**

ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរចំណុចដូចខាងក្រោមនេះ៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត
- ហេតុការណ៍ និងមូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើង។

ម្ចាស់បំណុលនៃការអនុវត្តត្រូវបញ្ជាក់អំពីចំណុចនានា ដែលស្ថាប័នផ្តល់រូបមន្តត្រូវស្រាវជ្រាវ ប្រសិនបើមានការចាំបាច់។[២៩]

**ឧទាហរណ៍** ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់លិខិតបញ្ជាក់ អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា ប្រសិនបើពុំមានភាពច្បាស់លាស់នៅក្នុងសំណុំរឿង ថាតើសាលក្រម ឬសាលដីកានោះត្រូវបានបញ្ជាក់អំពីការផ្ទេរសមត្ថភាពធ្វើជាភាគីនៃការអនុវត្តដោយបង្ខំ ដោយបញ្ជាក់លិខិតបញ្ជាក់ នៃអនុប្បទានសិទ្ធិលើបំណុល។

**ឃ. ស្ថាប័នផ្តល់រូបមន្តអនុវត្តដោយបង្ខំ និងនីតិវិធីផ្តល់រូបមន្តអនុវត្ត**

ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រម ឬសាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្ត គឺក្រឡាបញ្ជីនៃតុលាការអនុវត្តដែលមានសំណុំរឿងនៃបណ្តឹង ដែលនាំទៅដល់ការចេញសាលក្រម ឬសាលដីកានោះ យោងទៅលើមាត្រា៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះករណី

[២៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៦

[២៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៥ កថាខណ្ឌ១

ដែលលិខិតអនុវត្ត គឺជាសេចក្ដីសម្រេចផ្សេងទៀតដូចជា កំណត់ហេតុរបស់តុលាការ ឬការចាត់ចែងរបស់ក្រឡាបញ្ជី ស្ថាប័នផ្ដល់រូបមន្ដអនុវត្ត គឺក្រឡាបញ្ជីដែលរក្សាទុកសំណុំរឿងដែលជាឯកសារចាំបាច់សម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃលិខិតអនុវត្តនោះ។ ប៉ុន្តែត្រូវបានលើកលែងករណីដែលលិខិតអនុវត្ត គឺជាលិខិតយថាភូត ដែលធ្វើដោយសារការីផ្ដល់ដោយសារការី ដែលរក្សាទុកនូវលិខិតយថាភូតដើមនោះ។[៣០]

❖ **នីតិវិធីមុនផ្ដល់រូបមន្ដអនុវត្ត**

- ស្ថាប័នអនុវត្តចាំបាច់ត្រូវតែស្រាវជ្រាវទៅលើសុពលភាពនៃលិខិតអនុវត្ត ថាតើមានអានុភាពអនុវត្តឬយ៉ាងណា។
- ភាពសមស្របទៅនឹងស្ថានភាពជាក់ស្ដែងខ្លឹមសារនៃលិខិតអនុវត្ត គឺសំដៅពិនិត្យលើកម្មវត្ថុដែលអាចអនុវត្តបាន សេចក្ដីសម្រេចបានកំណត់ជាក់លាក់ និងលិខិតបញ្ជាក់អនុវត្ត ត្រូវបានបំពេញលក្ខខណ្ឌទាមទារគ្រប់ជ្រុងជ្រោយ។
- ការកើតឡើង និងមានអត្ថិភាពនៃអានុភាពអនុវត្តរបស់លិខិតអនុវត្ត សំដៅលើការចូលជាស្ថាពរនៃសេចក្ដីសម្រេចរបស់តុលាការ ហើយបន្តមានអានុភាព បើពុំទាន់ចូលជាស្ថាពរ តម្រូវឱ្យមានភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន និងមិនត្រូវបានរលត់។
- បានបំពេញលក្ខខណ្ឌបង្អង់ និងការមកដល់នូវពេលកំណត់។
- ជាគោលការណ៍ ការផ្ដល់រូបមន្ដអនុវត្ត មិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ។ ការផ្ដល់រូបមន្ដអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែមនៅផ្នែកក្រោយនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។

នៅក្នុងរូបមន្ដអនុវត្ត មានចំណុចមួយចំនួនចាំបាច់ត្រូវតែសរសេរ ដូចជា៖

- បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបានដោយលិខិតអនុវត្ត និងភាគីម្ខាងទៀត
- ហេតុការណ៍ក្នុងករណីដែលបានផ្ដល់រូបមន្ដអនុវត្ត តាមបញ្ញត្តិស្ដីពីការផ្ដល់រូបមន្ដពិសេស
- ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្ដល់រូបមន្ដអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត
- ហេតុការណ៍ ក្នុងករណីដែលផ្ដល់រូបមន្ដអនុវត្តច្រើនច្បាប់។

នៅចុងបញ្ចប់ នៃលិខិតរូបមន្ដអនុវត្ត ក្រឡាបញ្ជី ឬសារការី ត្រូវចុះហត្ថលេខាលើរូបមន្ដអនុវត្ត ដោយសរសេរកាលបរិច្ឆេទនៃការផ្ដល់។[៣១] យ៉ាងណាមិញ ក្នុងករណីមួយចំនួន ពុំចាំបាច់ត្រូវការរូបមន្ដអនុវត្តនោះទេដូចជា

---

[៣០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៤ កថាខណ្ឌ២

[៣១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៧

រឿងក្តីទឹកប្រាក់តិច រឿងក្តីដែលភ្ជាប់ជាមួយប្រកាសឱ្យអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន និងដីការសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

**១.១.២.៤. បណ្តឹងតវ៉ាចំពោះការទាមទារ**

ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត គឺជាការសង្គ្រោះមួយសម្រាប់ម្ចាស់បំណុល ក្នុងនីតិវិធីផ្តល់រូបមន្តអនុវត្ត។ ការសុំតវ៉ាអាចនឹងដោយមូលហេតុដូចជា៖

- ដើម្បីបដិសេធការផ្តល់រូបមន្តអនុវត្តរបស់ក្រឡាបញ្ជី ឬសារការី
- តវ៉ាការមិនផ្តល់រូបមន្តអនុវត្តពិសេស របស់ស្ថាប័នផ្តល់រូបមន្តអនុវត្ត។

របៀបនៃការដាក់ពាក្យសុំតវ៉ា គឺត្រូវដាក់ទៅកាន់តុលាការដែលក្រឡាបញ្ជីស្ថិតនៅ ឬសាលាដំបូងនៅទីតាំងការិយាល័យសារការីស្ថិតនៅ។ ចំពោះការសម្រេចសេចក្តីចំពោះការសុំតវ៉ា គឺចេញដោយដីកាសម្រេចដោយពិនិត្យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការតវ៉ា ហើយតុលាការអាចធ្វើការលើកចោល ការសុំតវ៉ាបើយល់ថាពាក្យស្នើពុំត្រឹមត្រូវ ឬអាចបង្គាប់ឱ្យស្ថាប័នផ្តល់រូបមន្តអនុវត្ត ធ្វើការផ្តល់រូបមន្តអនុវត្តដោយបញ្ជាក់ពីមូលហេតុដែលត្រូវផ្តល់នូវក្នុងដីកាសម្រេច។[៣២]

## ១.២. ស្ថាប័នអនុវត្តនៃនីតិវិធីអនុវត្តដោយបង្ខំ

សមត្ថភាព និងអំណាចធ្វើការអនុវត្តដោយបង្ខំ ធ្លាក់ទៅលើស្ថាប័នជាតិ។ ស្ថាប័នដែលទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំ ដែលជាអំណាចរបស់រដ្ឋហៅថា ស្ថាប័នអនុវត្ត។[៣៣] ដោយសារថា នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះវាមិនចាំបាច់ដែលតុលាការដែលទទួលពាក្យបណ្តឹង ត្រូវតែស្ថាប័នអនុវត្តទេ។ ផ្ទុយទៅវិញដោយគិតអំពីតម្រូវការនៃភាពងាយស្រួល និងភាពឆាប់រហ័ស ការដាក់ការទទួលបន្ទុកឱ្យស្ថាប័នមួយផ្សេងទៀត គឺជ ការសមស្រប។ ហេតុដូច្នេះហើយ បានជាច្បាប់ចែងឱ្យតុលាការអនុវត្ត និងអាជ្ញាសាលាធ្វើជាស្ថានអនុវត្ត។[៣៤]

តុលាការអនុវត្ត និងអាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័នទាំងពីរនេះមានចរិតលក្ខណៈផ្សេងពីគ្នា ហេតុនេះហើយ បានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ និងទៅតាមប្រភេទបែបបទ នៃការអនុវត្តជាអាទិ៍។

**ឧទាហរណ៍** ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលតម្រូវឱ្យមានសកម្មភាពជាក់ស្តែង ដោយប្រើប្រាស់កម្លាំងត្រូវបានដាក់ជាបន្ទុកទៅឱ្យអាជ្ញាសាលា ចំណែកឯការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលទង្វើ

[៣២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៦៣

[៣៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៦ កថាខណ្ឌ១

[៣៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៦ កថាខណ្ឌ២

បញ្ហាមានលក្ខណៈអរូបី និងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលត្រូវធ្វើឡើងតាមនីតិវិធីត្រូវបានទម្លាក់ជាបន្ទុកទៅឱ្យតុលាការអនុវត្ត។[៣៥]

### ១.២.១. ប្រភេទនៃស្ថាប័នអនុវត្ត

#### ១.២.១.១. តុលាការអនុវត្ត

**ក. គោលគំនិត**

តុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ (តុលាការតាមនិយមន័យចង្អៀត) ហៅថា តុលាការអនុវត្ត ។ សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្លីនេះ ហើយនឹងស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមនៃសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជាតុលាការអនុវត្ត។ [៣៦]

**ខ. សមត្ថកិច្ច**

នៅក្នុងករណី ដែលតុលាការអនុវត្តដើរតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះរួមមាន ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[៣៧] ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធប្រាតិភោគចំពោះអចលនវត្ថុ[៣៨] ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិលើប្រាតិភោគ ចំពោះនាវា[៣៩] ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន[៤០] និងការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច ដែលមានគោលបំណងឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពណាមួយ[៤១]។ សូមកត់សម្គាល់ថា សមត្ថកិច្ចតាមដែនដីនៅក្នុងករណីនីមួយៗ ក៏ត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិទាំងនេះដែរ (សូមមើលមាត្រា ៣៣៦ កថាខ័ណ្ឌទី៣)។

នៅពេលដើរតួនាទី ជាស្ថាប័នសម្រាប់ផ្តល់កិច្ចសហការ និងមើលខុសត្រូវលើនីតិវិធីនៃការអនុវត្ត ដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាសាលា តុលាការអនុវត្តមានសិទ្ធិអំណាចនៅក្នុងការអនុញ្ញាតឱ្យអនុវត្តនៅថ្ងៃសម្រាក

---

[៣៥] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៨, ជំពូកទី២ សេចក្តីពន្យល់ទូទៅ ផ្នែកទី១ កថាភាគ១ ទំព័រទី១៣

[៣៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៦ កថាខណ្ឌ៣

[៣៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, ផ្នែកទី៣ មាត្រា៤០២

[៣៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, ផ្នែកទី៤ មាត្រា៤១៨

[៣៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, ផ្នែកទី៥ មាត្រា៤៥៦

[៤០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, ជំពូកទី៤ មាត្រា៥២៦

[៤១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, ជំពូកទី៤ មាត្រា៥២៧-មាត្រា៥២៨

ឬពេលយប់។[៤២] ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូសជាអាទិ៍។[៤៣]ចំពោះអង្គហេតុ ដែលកើតឡើងនៅក្នុងអំឡុងពេល នៃការអនុវត្តតុលាការអនុវត្តក៏មានសមត្ថកិច្ចលើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្តជាអាទិ៍ដែរ។[៤៤] (សូមកត់សម្គាល់ថា) ការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្ត របស់អាជ្ញាសាលាស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។ នៅក្នុងករណីនេះ ដោយសារថាសាលាដំបូងនោះមិនដើរតួនាទី ជាស្ថាប័នអនុវត្ត គេមិនហៅតុលាការនោះថាជាតុលាការអនុវត្តទេ។[៤៥] សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ។[៤៦]

**គ. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត**

ទម្រង់នៃសេចក្តីសម្រេច ជាទូទៅការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្តី (សកម្មភាពធ្វើការសម្រេចសេចក្តី) ហើយទម្រង់នៃសេចក្តីសម្រេចនេះ គឺជាដីកាសម្រេច។ បើយល់ឃើញថាចាំបាច់នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចធ្វើការសួរនាំជនដែលទាក់ទងនឹងផលប្រយោជន៍ ឬជនផ្សេងទៀតដែលពាក់ព័ន្ធបាន។ វិធានការនៃការអនុវត្តដែលកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា៣៣៧ ឆ្លុះបញ្ចាំងនូវទស្សនទានដ៏ទូលំទូលាយ ដែលមិនត្រឹមតែរួមបញ្ចូលនូវសកម្មភាពរបស់តុលាការអនុវត្ត ដែលធ្វើឡើងនៅក្នុងនីតិវិធីនៃការអនុវត្ត ដូចជាការរឹបអូស ការប្តូរជាប្រាក់ ការចែកចំណែកជាអាទិ៍ប៉ុណ្ណោះទេ គឺថែមទាំងរួមបញ្ចូលនូវការចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្ត និងសកម្មភាពជាក់ស្តែងផ្សេងទៀតដែលមិនមែនជាការសម្រេចសេចក្តីផងដែរ។ [៤៧] ជាគោលការណ៍ ក្នុងករណីដែលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រោមទម្រង់ជាការចេញដីកាសម្រេច តុលាការនោះមានឆន្ទានុសិទ្ធិនៅក្នុងការកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ ហើយប្រសិនបើតុលាការ មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចសួរភាគីបាន។ នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ វិសាលភាពនៃអ្នកដែលតុលាការអាចសួរបានត្រូវបានពង្រីក គឺថាតុលាការអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ថែមទៀត បន្ថែមពីលើការសួរភាគី។[៤៨]

---

[៤២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤០

[៤៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤១

[៤៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤៤ កថាខណ្ឌ១

[៤៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៦

[៤៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤៦

[៤៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៧ កថាខណ្ឌ១-២

[៤៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា១១៤

### ១.២.១.២. អាជ្ញាសាលា

### ក. គោលគំនិត

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។[៤៩] ស្ថាប័នយុត្តាធិការនេះ ស្ថិតនៅក្រោមក្រសួងយុត្តិធម៌ និងមានសមាសភាពជាមន្ត្រីរាជការដែលមានឈ្មោះថាជាអាជ្ញាសាលាដែលបំពេញការងារនៅសាលាដំបូងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ។[៥០]

អាជ្ញាសាលា គឺជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ចេញពីក្នុងចំណោមបុគ្គលដែលបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារមួយចំនួន។[៥១] ក៏ប៉ុន្តែខុសពីមន្ត្រីរាជការទូទៅ អាជ្ញាសាលាមិនទទួលប្រាក់ខែពីរដ្ឋទេ គឺទទួលបានចំណូលជាប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំពោះការអនុវត្តមុខងាររបស់ខ្លួនវិញ ដែលនេះ គឺជាចរិតលក្ខណៈពិសេសមួយរបស់អាជ្ញាសាលា។[៥២]

### ខ. តួនាទីរបស់អាជ្ញាសាលា

អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួន នៅតំបន់សមត្ថកិច្ចរបស់សាលាដំបូង ដែលខ្លួនបំពេញការងារ។ ការកម្រិតទៅលើតំបន់នៃការបំពេញ មុខនាទីនេះ មានឥទ្ធិពលដោយប្រយោលទៅលើការកំណត់ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា។[៥៣]

នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យ ក្នុងនាមជាស្ថាប័នអនុវត្តរួមមាន ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ចាប់ពីមាត្រា៣៨៤ តទៅ) សិទ្ធិប្រាតិភោគចំពោះចលនវត្ថុ (ចាប់ពី មាត្រា៥០០ តទៅ)[៥៤] ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ[៥៥] និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ។[៥៦]

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលតុលាការអនុវត្តជាអ្នកទទួលបន្ទុកក្នុងនាមជាស្ថាប័នអនុវត្ត

---

[៤៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២៤៦

[៥០] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា២

[៥១] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា៤

[៥២] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា៣

[៥៣] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា៧

[៥៤] ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៨, ជំពូកទី២ កថាភាគ៣

[៥៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៥២៤

[៥៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៥២៥

អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំណុចដូចតទៅ៖ ការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[៥៧] ឬការអនុវត្តការលក់[៥៨] និងការដកហូតលិខិតបញ្ជាក់សញ្ញាតិនាវាជាអាទិ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ជាដើម។[៥៩] លើសពីនេះទៅទៀត នៅក្នុងនីតិវិធីនៃការអនុវត្តរក្សាការពារ អាជ្ញាសាលាមានសិទ្ធិអំណាចនៅក្នុងការថែរក្សាគ្រប់គ្រងអចលនវត្ថុ ដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់។[៦០]

**គ. ឋានៈរបស់អាជ្ញាសាលា នៅក្នុងការអនុវត្តដោយបង្ខំ**

**ទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល** អាជ្ញាសាលា ត្រូវធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំ ដោយផ្អែកលើពាក្យសុំត្រឹមត្រូវតាមច្បាប់របស់ម្ចាស់បំណុល និងដោយអនុលោមទៅតាមនីតិវិធី ដែលបានកំណត់ដោយច្បាប់។ ទំនាក់ទំនងនេះ គឺជាទំនាក់ទំនងរវាងបុគ្គលឯកជន និងអាជ្ញាធររដ្ឋនៅក្រោមបញ្ញត្តិ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេ។ គេអាចនិយាយម៉្យាងទៀតបានថា អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យ ហើយបើទោះបីជាប្រព័ន្ធនៃការបង់ប្រាក់កម្រៃ ត្រូវបានអនុវត្តដូចបានរៀបរាប់ខាងលើក៏ដោយ ក៏អាជ្ញាសាលាពុំមែនជាអ្នកតំណាងរបស់ម្ចាស់បំណុលឡើយ។ អាជ្ញាសាលាត្រូវធ្វើការអនុវត្តដោយបង្ខំ នៅក្នុងឆន្ទានុសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន។ ទោះបីជាអាជ្ញាសាលាធ្វើតាមការណែនាំរបស់ម្ចាស់បំណុលក៏ដោយ ប្រសិនបើសកម្មភាពនៃការអនុវត្តដោយបង្ខំនោះខុសច្បាប់ នោះអាជ្ញាសាលាមិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសកម្មភាពនោះបានទេ។ អាជ្ញាសាលាអាចគោរពតាមឆន្ទៈរបស់ម្ចាស់បំណុលបាន ចំពោះទំហំ និងកម្រិតនៃការអនុវត្តដោយបង្ខំ ប៉ុន្តែប្រសិន ការណែនាំ ឬសំណូមពរនោះខុសច្បាប់អាជ្ញាសាលាមិនត្រូវធ្វើតាមឡើយ។

ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា គឺជាការប្រើអំណាចអនុវត្តរបស់រដ្ឋ នោះមន្ត្រីដែលទទួលបន្ទុកការអនុវត្ត ពុំមែនជានិយោជិតរបស់ម្ចាស់បំណុលឡើយ។ ហេតុនេះហើយ ប្រសិនបើអាជ្ញាសាលាបង្កឱ្យមានការខូចខាតដល់កូនបំណុល ឬតតិយជន ដោយសារការធ្វើសកម្មភាពអនុវត្តដោយបង្ខំ នោះម្ចាស់បំណុលមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក្នុងនាមជានិយោជកឡើយ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលឱ្យ

[៥៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤២៩

[៥៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៣៦

[៥៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៥៩

[៦០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៥៧១

អាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវ ដោយចេតនា ឬដោយការធ្វេសប្រហែស ហើយបង្កមានការខូចខាតដល់អ្នកដទៃ នោះម្ចាស់បំណុលអាចនឹងមានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ដោយផ្ទាល់ខ្លួន ។

**ឧទាហរណ៍** ដូចជាករណីដែលម្ចាស់បំណុលកុហកថា អចលនវត្ថុណាមួយជាកម្មសិទ្ធិរបស់កូនបំណុល ហើយឱ្យអាជ្ញាសាលារឹបអូសអចលនវត្ថុនោះ ទាំងដែលខ្លួនដឹងថាវាជាកម្មសិទ្ធិរបស់តតិយជនសោះ។

**ទំនាក់ទំនងជាមួយនឹងកូនបំណុល និងតតិយជន** អាជ្ញាសាលា មានសិទ្ធិប្រើប្រាស់អំណាចបង្ខំទៅលើកូនបំណុល និងតតិយជន នៅក្នុងទំហំដែលចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ហើយត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពនេះដោយស្របច្បាប់។ ម៉្យាងទៀតដូចដែលបានរៀបរាប់ខាងលើ ដោយសារថាទំនាក់ទំនងរវាងម្ចាស់បំណុល និងអាជ្ញាសាលា ពុំមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេនោះ ម្ចាស់បំណុលមិនអាចប្រគល់ទៅឱ្យអាជ្ញាសាលានូវសិទ្ធិតំណាងតាមច្បាប់ឯកជន ដូចជាការទទួលការសង ការផ្សះផ្សា ជាអាទិ៍បានឡើយ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ អាជ្ញាសាលាមានសិទ្ធិទទួលការសងដោយស្ម័គ្រចិត្តទៅតាមច្បាប់បាន។ គោលបំណងនៃបញ្ញត្តិនេះគឺ ដើម្បីកុំឱ្យមានការខាតបង់នៅក្នុងការអនុវត្តក្នុងករណី ដែលកូនបំណុលនៃការអនុវត្តមានឆន្ទៈធ្វើការសងដោយស្ម័គ្រចិត្ត។[៦១]

**ទំនាក់ទំនងជាមួយនឹងតុលាការអនុវត្ត** តុលាការអនុវត្ត និងអាជ្ញាសាលា សុទ្ធតែជាស្ថាប័ន ឯករាជ្យរបស់រដ្ឋរៀងៗខ្លួន។ ហើយអាជ្ញាសាលា ពុំមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ។ ច្បាប់អនុញ្ញាតឱ្យតុលាការអនុវត្តផ្តល់ការណែនាំប្រគល់សិទ្ធិ និងបង្គាប់អាជ្ញាសាលា នៅក្នុងករណីជាក់លាក់មួយចំនួន ប៉ុន្តែបទប្បញ្ញត្តិទាំងនេះ ត្រូវបានរៀបចំឡើងដោយយកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរ មកជាមូលដ្ឋាន និងដោយគិតពិចារណា ទៅលើចរិតលក្ខណៈរបស់ស្ថាប័ននីមួយៗផងដែរ។ ដោយឡែក ចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យ ពីសាលាដំបូងដែលខ្លួនស្ថិតនៅ ចំពោះមុខងាររបស់ខ្លួន។ ក៏ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែល ជាអ្នកតែងតាំងមានសិទ្ធិអំណាចដាក់ទណ្ឌកម្មខាងផ្នែកវិន័យ ចំពោះការបំពានលើមុខងារជាអាទិ៍របស់អាជ្ញាសាលា។[៦២]

**ការដកហូត** ក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាតិ ឬ មានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងទៀតជាមួយនឹងភាគី អាជ្ញាសាលានោះត្រូវដកហូតចេញពីការអនុវត្តមុខការរបស់ខ្លួន ដើម្បីជៀសវាងភាពមន្ទិលសង្ស័យអំពីភាពត្រឹមត្រូវនៅក្នុងការបំពេញមុខនាទីនោះ។[៦៣]

---

[៦១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៨៥

[៦២] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា៦

[៦៣] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា១៣

### ឃ. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយអាជ្ញាសាលា

**ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ** អាជ្ញាសាលាត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬលក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ។[៦៤]

**ការអនុវត្តសិទ្ធិឆែកឆេរ** អាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្តបាន ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូស នៅក្នុងទំហំចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ។ នៅក្នុងករណីនេះប្រសិនបើមានភាពចាំបាច់អាជ្ញាសាលា អាចឱ្យកូនបំណុលនៃការអនុវត្តបើកទ្វារដែលចាក់សោរទូដែក និងប្រអប់ផ្សេងទៀតបាន។ ហើយប្រសិនបើកូនបំណុលនៃការអនុវត្ត បដិសេធមិនព្រមធ្វើតាមទេ អាជ្ញាសាលាអាចចាត់វិធានការណ៍ចាំបាច់ដើម្បីបើករបស់ទាំងនោះដោយប្រើកម្លាំង។[៦៥]

**ការបំបាត់នូវការប្រឆាំង** ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខងារ របស់ខ្លួន អាជ្ញាសាលានោះ អាចប្រើកម្លាំង ឬអាចសុំជំនួយពីនគរបាល ស្ថាប័នរដ្ឋផ្សេងទៀត ដែលទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំបាត់នូវការប្រឆាំងនោះបាន។[៦៦]

**អ្នកសង្កេតការណ៍** នៅពេលចូលទៅទីកន្លែងរស់នៅរបស់ជនណាម្នាក់ ដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងម្ចាស់នៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ត្រូវហៅរកអ្នកសង្កេតការណ៍ដែលអាចជាមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬអ្នកដទៃទៀតដែលយល់ឃើញថាសមរម្យអាចធ្វើជាអ្នក សង្កេតការណ៍បាន។ ក្នុងករណីដែលអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំ ដោយប្រើកម្លាំង ឬដោយមានជំនួយពីនគរបាល ជាអាទិ៍ តាមបញ្ញត្តិនៃមាត្រា៣៣៨ កថាខណ្ឌទី១ នោះបើទោះបីជាមិនចូលទៅក្នុង ទីកន្លែងរស់នៅក៏ដោយ ក៏ចាំបាច់ត្រូវមានអ្នកសង្កេតការណ៍ដែរ។ គោលបំណង នៃការកំណត់បែបនេះគឺ ដើម្បីសង្កេតទៅលើភាពត្រឹមត្រូវនៅក្នុងការអនុវត្ត និងដើម្បីបង្កើតភស្តុតាងសម្រាប់ពេលអនាគតផង ។[៦៧]

**ការអនុវត្តនៅថ្ងៃសម្រាក ឬពេលយប់** ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅរបស់ជនណាម្នាក់

---

[៦៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤១

[៦៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៨៥ កថាខណ្ឌ២

[៦៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៨ កថាខណ្ឌ១

[៦៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៩

នៅថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាក ដែលច្បាប់បានកំណត់ ក្នុងចន្លោះពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹក អាជ្ញាសាលាត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬតុលាការអនុវត្ត ដែលចេញដីកាបង្គាប់។ បន្ថែមពីលើនេះ នៅពេលបំពេញមុខនាទី អាជ្ញាសាលាត្រូវបង្ហាញលិខិតដែល បញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតនោះផងដែរ។ ការកំណត់បែបនេះគឺ ដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កូនបំណុលដោយពុំមានភាពចាំបាច់។[៦៨]

**ការធ្វើកំណត់ហេតុ** អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន ។[៦៩] អាជ្ញាសាលាត្រូវរក្សាទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំ ព្រមទាំងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងរឿងក្តីដែលមានការអនុវត្តដោយបង្ខំ ដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ។[៧០]

**១.២.១.២. វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ**

មិនមែនគ្រប់បុគ្គលសុទ្ធសឹងតែត្រូវទទួលរងនូវការអនុវត្តដោយបង្ខំនោះទេ។ វិសាលភាព នៃអ្នកដែលអាចអនុវត្តដោយបង្ខំបានកំណត់ដូចខាងក្រោមៈ

- ភាគីដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត
- តតិយជន ដែលមានបញ្ជាក់ក្នុងលិខិតអនុវត្ត(ភាគីសម្រាប់តតិយជន)
- អ្នកដែលបន្តសិទ្ធិ ឬករណីកិច្ច ក្នុងចំណុចពីរខាងលើ។[៧១]

**១.២.២. ភាគីនៃការអនុវត្ត និងអ្នកតំណាង**

**១.២.២.១. ភាគីអនុវត្ត**

ភាគីនៅក្នុងរឿងក្តីអនុវត្តដោយបង្ខំ ដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំហៅថា ភាគីម្ចាស់បំណុលនៃការអនុវត្ត ចំណែកឯភាគីម្ខាងទៀតហៅថា ភាគីកូនបំណុលនៃការអនុវត្ត។ នៅពេលដែលម្ចាស់បំណុលបានឱ្យកូនបំណុលរបស់ខ្លួនអនុវត្តកាតព្វកិច្ច ដែលមានចំពោះខ្លួន ប៉ុន្តែកូនបំណុលមិនព្រមអនុវត្តតាមសម្រួលនោះម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅស្ថាប័នអនុវត្តបាន ដើម្បីធ្វើការអនុវត្តដោយបង្ខំទៅលើកូនបំណុលតាមរយៈការប្រើប្រាស់អំណាចរដ្ឋ។ កូនបំណុល ក្នុងនោះត្រូវរាប់បញ្ចូលទាំង តតិយជន ដែលដាក់វត្ថុ ឬសិទ្ធិដើម្បីធានាបំណុលរបស់កូនបំណុលក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគផងដែរ។[៧២]

---

[៦៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤០

[៦៩] សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, មាត្រា២០

[៧០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៧៨ កថាខណ្ឌ២

[៧១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥១

[៧២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រ៣៤៧

### ១.២.២.២. អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីអនុវត្តដោយបង្ខំ

អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ គឺខុសគ្នាពីអ្នកតំណាងនៅក្នុងនីតិវិធីនៃបណ្ដឹង ដោយហេតុថានៅក្នុងនីតិវិធីនៃបណ្ដឹង អ្នកតំណាងដោយអាណត្តិតម្រូវឱ្យជាចាំបាច់ជាមេធាវី។ ប៉ុន្តែនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ អ្នកតំណាងដោយអាណត្តិមិនតម្រូវជាចាំបាច់ជាមេធាវីនោះទេ ដោយសារតែនីតិវិធីអនុវត្តដោយបង្ខំគ្រាន់ជាការអនុវត្តតាមសាលក្រមដែលចូលជាស្ថាពរ ឬលិខិតយថាភូតតែប៉ុណ្ណោះ។

ដោយឡែកក្នុងករណីចាំបាច់ នៃនីតិវិធីនៃការចេញសាលក្រម នីតិវិធីត្រូវធ្វើដោយហ្មត់ចត់ក្នុងការចេញសាលក្រមនេះ។ ក្នុងចំណោមនៃការចេញដីកាសម្រេចនោះ អ្នកតំណាងដោយអាណត្តិ ត្រូវមានលក្ខណៈសម្បត្តិដូចដែលបានកំណត់ក្នុងមាត្រា៥៣ កថាខណ្ឌទី១ ស្ដីពីលក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ។

ចំពោះនីតិវិធី ដែលតុលាការត្រូវទទួលបន្ទុកការកំណត់ទទួលស្គាល់នូវវិសាលភាព នៃអ្នកតំណាងដោយអាណត្តិ មានភាពទូលាយជាងលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា៥៣ កថាខណ្ឌទី១ ដោយកំណត់ឱ្យតុលាការអនុវត្ត ឬសាលាដំបូងអាចធ្វើការកំណត់ដោយឆន្ទានុសិទ្ធិរបស់ស្ថាប័នអនុវត្ត។ ម៉្យាងទៀតចំពោះនីតិវិធីដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកវិញ ការកំណត់ ឬជ្រើសរើសអ្នកតំណាង ច្បាប់បានផ្ដល់សិទ្ធិឱ្យភាគីដែលជាអ្នកមានសិទ្ធិក្នុងការជ្រើសរើសដោយឆន្ទៈសេរី ដោយគ្មានកំណត់លក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិឡើយ។ បានសេចក្ដីថា អ្នកណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ ក្នុងនីតិវិធីដែលជាបន្ទុករបស់ស្ថាប័នអាជ្ញាសាលា។[៧៣]

### ១.២.៣. នីតិវិធីប្ដឹងឧបាស្រ័យចំពោះការអនុវត្ត

នៅពេលដែលធ្វើការអនុវត្តដោយបង្ខំស្ថាប័នអនុវត្ត (តុលាការអនុវត្ត និងអាជ្ញាសាលា) ត្រូវតែអនុវត្តអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានបានកំណត់ទុក។ ក៏ប៉ុន្តែក្នុងករណីដែលមានការអនុវត្តបំពានទៅនឹងនីតិវិធីជាដើម ភាគីពាក់ព័ន្ធមានសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ នីតិវិធីដើម្បីការពារផលប្រយោជន៍ខ្លួនចំពោះការអនុវត្តបំពានកិច្ចនីតិវិធី គឺធ្វើវិធីឧបាស្រ័យចំពោះការអនុវត្តដែលមានពីរយ៉ាងដូចជា ការតវ៉ាចំពោះការអនុវត្ត និងបណ្ដឹងជំទាស់។[៧៤]

#### ១.២.៣.១. ការតវ៉ាចំពោះការអនុវត្ត

ការតវ៉ា គឺជាបែបបទសម្រាប់ភាគី ឬតតិយជន ដែលទទួលផលប៉ះពាល់ចំពោះផលប្រយោជន៍ខ្លួនក្នុងពេលដែលធ្វើការអនុវត្តដោយបង្ខំ។ ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យដែលមានភាពងាយស្រួល និងឆាប់រហ័សជាងការដាក់ពាក្យបណ្ដឹងជំទាស់។ បុគ្គលដែលមានសិទ្ធិក្នុងការតវ៉ាចំពោះការអនុវត្ត គឺជាបុគ្គល

[៧៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤៨

[៧៤] ក្រសួងយុត្តិធម៌ ស្ដីពីសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៨, ជំពូកទី២ សេចក្ដីពន្យល់ទូទៅ ផ្នែកទី១ ទំព័រទី១៩

ដែលទទួលរងនូវផលប៉ះពាល់ដោយការចាត់ចែង ការអនុវត្តខុសច្បាប់ ឬការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្ត រួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលទាមទារការចែកចំណែក និងតតិយជនជាដើម។ នីតិវិធីនៃការប្តឹងតវ៉ាចំពោះការអនុវត្ត អាចធ្វើបានដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃនីតិវិធី ឬធ្វើជាលាយលក្ខណ៍អក្សរទៅកាន់៖

- តុលាការអនុវត្តដែលពាក់ព័ន្ធផ្ទាល់ បើសិនការតវ៉ានោះជាការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ហើយមិនអាចធ្វើការប្តឹងជំទាស់បាន។
- សាលាដំបូង ដែលអាជ្ញាសាលាពាក់ព័ន្ធស្ថិតនៅ ប្រសិនបើការតវ៉ានោះធ្វើឡើងចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាង ឬការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្ត។
- នៅពេលមានការតវ៉ាចំពោះការអនុវត្ត ដំណើរការនៃនីតិវិធីអនុវត្តដោយបង្ខំមិនត្រូវបានផ្អាកឡើយ ប៉ុន្តែក្នុងអំឡុងពេលនៃដំណើរការនីតិវិធីដោះស្រាយចំពោះការតវ៉ានោះ ពោលគឺចាប់ពីពេលធ្វើការតវ៉ារហូតដល់សេចក្តីសម្រេចអំពីការតវ៉ាចំពោះការអនុវត្តកើតមានអានុភាពតុលាការអនុវត្តអាចចេញដីការសម្រេចផ្អាកនូវអានុភាពនៃដីកាសម្រេចដើម ដោយតម្រូវឱ្យមានការដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ ឬក៏ផ្អាកនូវនីតិវិធី នៃការអនុវត្តដោយបង្ខំទាំងស្រុង ឬមួយផ្នែកដោយដាក់ ឬមិនដាក់ប្រាតិភោគបាន។[៧៥]

### ១.២.៣.២. បណ្តឹងជំទាស់

ពាក្យថា បណ្តឹងជំទាស់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំ សំដៅទៅលើការឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្តី គឺដីកាសម្រេចរបស់តុលាការអនុវត្តដូចជាសេចក្តីសម្រេចអនុញ្ញាតឱ្យលក់ជាដើម ទៅកាន់តុលាការជាន់ខ្ពស់។ ជាគោលការណ៍ បណ្តឹងជំទាស់អាចធ្វើឡើងបានលុះត្រាតែសេចក្តីសម្រេចនោះបំពានទៅលើនីតិវិធីក្នុងច្បាប់ ឬផ្ទុយនឹងច្បាប់ ហើយមានបញ្ញត្តិចែងច្បាស់លាស់ បើកសិទ្ធិឱ្យធ្វើឧបាស្រ័យប្តឹងជំទាស់បាន។ បុគ្គលដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់ គឺជាបុគ្គលដែលបានទទួលរងនូវ ការប៉ះពាល់ដោយដីកាសម្រេច រួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលទាមទារការចែកចំណែក និងតតិយជនជាដើម។ សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យបណ្តឹងជំទាស់បានមានដូចជា៖

- ដីកាសម្រេចរបស់តុលាការអនុវត្ត ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ
- ដីកាសម្រេចរបស់សាលាដំបូង ដែលបង្គាប់ឱ្យអាជ្ញាសាលាលុបចោលនីតិវិធីអនុវត្តដោយបង្ខំ

[៧៥] ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៨, ជំពូកទី២ សេចក្តីពន្យល់ទូទៅ ផ្នែកទី១ ទំព័រទី២២

- ដីកាសម្រេចរបស់សាលាដំបូង ដែលលើកចោលពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់អាជ្ញាសាលា ដែលលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ
- នឹងដីកាសម្រេចផ្សេងៗទៀតដែលបំពានទៅលើនីតិវិធីច្បាប់ ឬផ្ទុយនឹងច្បាប់។

ដើម្បីធ្វើបណ្តឹងជំទាស់បាន អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់បាន ចាំបាច់ត្រូវធ្វើការដាក់ពាក្យប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលមួយសប្តាហ៍ ដោយគិតចាប់ពីថ្ងៃ ដែលបានទទួលដំណឹងអំពីសេចក្តីសម្រេច ដោយមិនអាចពន្យារពេលបានទៅកាន់តុលាការដើម។ ក្រោយពីទទួលបានពាក្យបណ្តឹងជំទាស់ តុលាការដើមត្រូវបញ្ជូនឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។ នៅពេលដែលមានការប្តឹងជំទាស់ អានុភាពនៃដីកាសម្រេចដើមមិនត្រូវបានផ្អាកឡើយ ក៏ប៉ុន្តែក្នុងអំឡុងពេលនៃដំណើរការនៃនីតិវិធីដោះស្រាយបណ្តឹងជំទាស់ ពោលគឺចាប់ពីពេលដែលបានដាក់ពាក្យបណ្តឹងជំទាស់រហូតដល់សេចក្តីសម្រេច អំពីបណ្តឹងជំទាស់កើតមានអានុភាព តុលាការនៃបណ្តឹងជំទាស់អាចចេញដីកាសម្រេចផ្អាកនូវអានុភាពនៃដីកាសម្រេចដើម ដោយតម្រូវឱ្យមានការដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគតាមការយល់ឃើញរបស់តុលាការដោះស្រាយបណ្តឹងជំទាស់ ឬក៏ផ្អាកនូវនីតិវិធីនៃការអនុវត្តដោយបង្ខំទាំងស្រុង ឬមួយផ្នែកដោយដាក់ ឬមិនដាក់ប្រាតិភោគបាន។[៧៦]

## ១.៣. សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

### ១.៣.១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជាប្រភេទនៃការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់។ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត តុលាការអនុវត្តដាក់កម្រិតទៅលើសិទ្ធិចាត់ចូលរបស់កូនបំណុលនៃការអនុវត្តចំពោះអចលនវត្ថុ ដែលជាកម្មវត្ថុ ដោយធ្វើការរឹបអូសអចលនវត្ថុនោះ ហើយលក់អចលនវត្ថុនោះ បន្ទាប់មកធ្វើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់នោះទៅសងម្ចាស់បំណុលនៃការអនុវត្ត។ ហេតុដូចនេះហើយបានជា ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ គឺជាការអនុវត្តតាមរយៈការលក់ដោយបង្ខំ ដែលតុលាការអនុវត្តរឹបអូសអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយទើបយកប្រាក់ដែលបានមកពីការលក់នោះទៅសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល។

[៧៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៤៥

### ១.៣.២. កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

អចលនវត្ថុ ដែលអាចក្លាយទៅជា កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរួមមាន ដី អគារ ដែលត្រូវបានចុះបញ្ជី ចំណែកកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគនោះដែលជាសិទ្ធិរួម (សិទ្ធិអវិភាគ)។[៧៧]

#### ១.៣.២.១. ដី ឬអគារ

ការចាត់ទុកថាអគារ គឺជាអចលនវត្ថុឯករាជ្យអំពីដី ឬយ៉ាងណានោះ វាអាស្រ័យទៅលើគោលនយោបាយនីតិកម្មរបស់ប្រទេសនីមួយៗ។ ដោយសារក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាចែងថា ជាគោលការណ៍ អគារ គឺជាសមាសភាគនៃដី។ ដូច្នេះជាគោលការណ៍ទូទៅ អគារមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក្នុងលក្ខណៈជាអចលនវត្ថុឯករាជ្យបានទេ។[៧៨] ក៏ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ននេះ យើងបានដឹងថាមានករណីដែលអាចចុះបញ្ជីអគារ ជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យបាន តាមច្បាប់រដ្ឋប្បវេណី ដោយសារមានកាលៈទេសៈពិសេសដែលថា ដី មិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិតាមច្បាប់រដ្ឋប្បវេណីទេ នៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា ជាពិសេសរាជធានីភ្នំពេញ។ ហេតុនេះហើយ នៅក្នុងករណីនេះអគារ ដែលត្រូវបានចុះបញ្ជីក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបានដែរ។ ចំពោះអគារដែលមិនបានចុះបញ្ជី គឺជាសមាសភាគនៃកម្មសិទ្ធិលើដី ឬសមាសភាគនៃសិទ្ធិប្រត្យក្សប្រើប្រាស់ដី (សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) ដែលមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះកម្មសិទ្ធិលើដី ឬចំពោះសិទ្ធិប្រត្យក្ស ប្រើប្រាស់ដីមានទៅលើអគារ ដែលជាសមាសភាគនៃសិទ្ធិនោះដែរ អគារទាំងនោះនឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងកម្មសិទ្ធិលើដី ឬសិទ្ធិប្រត្យក្សប្រើប្រាស់ដីនោះ។

#### ១.៣.២.២. កម្មសិទ្ធិអវិភាគលើដី ឬអគារ

ស្ថានភាពដែលបុគ្គលច្រើននាក់ មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតតាមចំនួននៅលើទ្រព្យតែមួយហៅថា សិទ្ធិអវិភាគ។[៧៩] ចំពោះភាគចំណែកនៃម្ចាស់កម្មសិទ្ធអវិភាគម្នាក់ៗ ត្រូវបានច្បាប់សន្មត់ថាស្មើគ្នា[៨០] ដែលមានន័យថា ប្រសិនបើក្នុងករណីម្ចាស់អវិភាគ មិនបានកំណត់ឱ្យលម្អិត ពីចំនួនចំណែកនៃកម្មសិទ្ធិអវិភាគ ឱ្យបានច្បាស់លាស់នោះទេ ចំណែកនៃកម្មសិទ្ធិករនីមួយៗ គឺស្មើគ្នា។

នៅក្នុងការគ្រប់គ្រង ប្រើប្រាស់អាស្រ័យផល លើវត្ថុអវិភាគតាមច្បាប់ម្ចាស់កម្មសិទ្ធិករម្នាក់ៗមានសិទ្ធិ

[៧៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤១៧

[៧៨] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា១២២

[៧៩] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២០២

[៨០] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២០៣

អាចធ្វើអនុប្បទាន ឬដាក់ជាប្រាតិភោគនូវចំណែកអវិភាគរបស់ខ្លួនបានដោយ មិនចាំបាច់មានការយល់ព្រមពីកម្មសិទ្ធិករអវិភាគផ្សេងទៀតឡើយ ហើយម្ចាស់បំណុលនៃម្ចាស់កម្មសិទ្ធិអវិភាគនេះ ក៏អាចរឹបអូសចំណែកនោះបានដែរ។ សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់កម្មសិទ្ធិអវិភាគមាន ៤ចំណុច គឺ៖

- **ការប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគ** ម្ចាស់កម្មសិទ្ធិករ អាចប្រើប្រាស់វត្ថុជាកម្មសិទ្ធិអវិភាគទាំងមូលតាមសមាមាត្រនៃចំណែករបស់ខ្លួនបាន ។
- **ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ** ម្ចាស់កម្មសិទ្ធិករ អាចធ្វើសកម្មភាពថែទាំវត្ថុ ដែលជាកម្មសិទ្ធិអវិភាគដោយឯកឯងបាន។
- **ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ** លុះណាតែមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិករអវិភាគផ្សេងទៀត។
- **ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ** កិច្ចការទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគត្រូវសម្រេចដោយមតិភាគច្រើន តាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ។

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ មានសិទ្ធិទាមទារឱ្យបែងចែកវត្ថុជាកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា។ ប៉ុន្តែម្ចាស់កម្មសិទ្ធិអវិភាគ អាចធ្វើកិច្ចសន្យាហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ក្នុងអំឡុងពេល ដែលមិនលើសពី៥(ប្រាំ) ឆ្នាំបាន។ ម្ចាស់កម្មសិទ្ធិករនៃវត្ថុអវិភាគម្នាក់ៗ ត្រូវទទួលបន្ទុកក្នុងការបង់សោហ៊ុយគ្រប់គ្រងពន្ធដារ តាមភាគចំណែកដែលខ្លួនមានរៀងៗខ្លួន ហើយបើក្នុងករណី ដែលកម្មសិទ្ធិករណាម្នាក់បានបង់សោហ៊ុយ ដើម្បីថែទាំគ្រប់គ្រង ឬបន្ទុកផ្សេងទៀតដែលលើសពីបន្ទុកដែលខ្លួនត្រូវបង់ ម្ចាស់កម្មសិទ្ធិករនោះអាចធ្វើការទាមទារឱ្យមានម្ចាស់កម្មសិទ្ធិករដទៃទៀត សងប្រាក់ដែលខ្លួនបានបង់លើសនោះ តាមសមាមាត្រនៃចំណែករៀងៗខ្លួន។

មួយវិញទៀត សិទ្ធិនៃការទាមទារខាងលើនេះ ក៏អាចធ្វើបានដែលចំពោះជនដែលបានទទួលបន្តនូវចំណែកកម្មសិទ្ធិអវិភាគផ្សេង។ លើសពីនេះទៅទៀត ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានបោះបង់នូវចំណែករបស់ខ្លួន ឬបានទទួលមរណៈភាព ហើយគ្មានសន្តតិជនទេនោះ ចំណែករបស់បុគ្គលនោះ នឹងត្រូវបានទៅម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត។ វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគមាន ២ប្រភេទ៖

- ធ្វើការបែងចែកតាមការព្រមព្រៀង ជាគោលការណ៍ វិធីបែងចែកត្រូវធ្វើឡើងដោយការពិភាក្សាគ្នាក្នុងចំណោមកម្មសិទ្ធិករអវិភាគទាំងអស់ ។
- ធ្វើការបែងចែកតាមផ្លូវតុលាការ គឺការបែងចែកវត្ថុតាមរូបដើម ការលក់ដេញថ្លៃ និងចែកប្រាក់តាមចំណែក និងការផ្ទេរចំណែកទៅឱ្យម្ចាស់កម្មសិទ្ធិករអវិភាគណាម្នាក់ដោយផ្តល់សំណង។

ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់កម្មសិទ្ធិអវិភាគឯទៀត ដោយសារការថែទាំ ការគ្រប់គ្រង ឬបន្ទុកផ្សេងទៀតទៅលើកម្មវត្ថុអវិភាគ ម្ចាស់កម្មសិទ្ធិអវិភាគ នោះអាចឱ្យកូនបំណុលសង ដោយយកចំណែក នៃចំណែកវត្ថុអវិភាគ ដែលជាចំណែករបស់កូនបំណុលបាន។ មួយវិញទៀត ក្នុងករណីដែលមានភាពចាំបាច់ត្រូវលក់វត្ថុ ដែលជាកម្មសិទ្ធិអវិភាគរបស់កូនបំណុលនោះ ម្ចាស់បំណុលអាចទាមទារការលក់ទៅតុលាការបាន។

សរុបជារួមមក កម្មសិទ្ធិអវិភាគ គឺជាអចលនទ្រព្យដូចជាដី ឬផ្ទះ ដែលមានម្ចាស់ចំនួនច្រើននាក់ ក៏ប៉ុន្តែទ្រព្យនោះ មិនអាចពុះចែកគ្នាបានទេ។ និយាយឱ្យងាយយល់ **ឧទាហរណ៍** ការចូលលុយគ្នាទិញផ្ទះមួយខ្នងចំនួន១០នាក់ ផ្ទះនោះមិនអាចពុះចែកគ្នាជា១០បានទេ ហើយម្ចាស់ទាំង១០ក៏នឹងទទួលបានប្លង់រឹងតែមួយសន្លឹកប៉ុណ្ណោះ។ ដូច្នេះ បើចង់លក់អចលនទ្រព្យ គឺត្រូវមានការយល់ព្រមពីម្ចាស់គ្រប់រូប។ ដូចគ្នានេះ ម្ចាស់ម្នាក់ៗក៏អាចលក់ចំណែករបស់ខ្លួនបានដូចការលក់ភាគហ៊ុនដូច្នេះដែរ។ ប៉ុន្តែត្រូវមានការយល់ស្របពីម្ចាស់ផ្សេងទៀត ហើយត្រូវយកប្លង់ទៅចុះឈ្មោះឡើងវិញជាមួយអាជ្ញាធរ។ ដូច្នេះ ក្នុងនាមជាអ្នកទិញ ជាបឋមអ្នកត្រូវចេះមើលលើចំណារនៅខាងក្រោយប្លង់រឹងនោះថា តើអចលនទ្រព្យនោះជាទ្រព្យអវិភាគ ឬយ៉ាងណា ហើយមានម្ចាស់ប៉ុន្មាននាក់។ ប៉ុន្តែមុននឹងសម្រេចចិត្តទិញគួរសាកសួរទៅកាន់អាជ្ញាធរក្រសួងដែនដី ដើម្បីទទួលបានព័ត៌មានជាក់លាក់។

### ១.៣.២.៣. សិទ្ធិជួលអចិន្ត្រៃយ៍ចំពោះអចលនវត្ថុ

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី ១៥ (ដប់ប្រាំ)ឆ្នាំ ឡើងទៅ។[៨១] ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ បើពុំបានធ្វើជាលាយលក្ខណ៍អក្សរទេ ត្រូវចាត់ទុកជាកិច្ចសន្យាដែលមិនកំណត់អំឡុងពេល ហើយអាចត្រូវបានរំលាយដោយភាគីម្ខាងនៅពេលណាក៏បាន (៣ ខែ ចំពោះអគារ និង១ឆ្នាំ ចំពោះដីធ្លី បានកន្លងហួស គឺគិតចាប់ពីពេលស្នើសុំឱ្យរំលាយ)។ អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព មិនអាចលើសពី ៥០(ហាសិប)ឆ្នាំ បានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើស ៥០(ហាសិបឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប)ឆ្នាំ។ សិទ្ធិជួលអចិន្ត្រៃយ៍ អាចបន្តសាជាថ្មីបាន ប៉ុន្តែអំឡុងពេលនេះមិនអាចលើសពី ៥០ (ហាសិប) ឆ្នាំឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី។

ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍ គឺជាការចុះបញ្ជីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដោយអ្នកជួលអចិន្ត្រៃយ៍ អាចយកមកតតាំងនឹងអនុប្បទានិក នៃកម្មសិទ្ធិដី ដែលជាកម្មវត្ថុនៃសិទ្ធិ

[៨១] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៤

ជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ។ មួយវិញទៀត ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមិនបានចុះបញ្ជីអាចតតាំងចំពោះជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុនោះបាន លុះត្រាតែអ្នកជួលអចិន្ត្រៃយ៍ បានទទួលការកាន់កាប់លើអចលនវត្ថុដោយត្រឹមត្រូវតាមច្បាប់ ព្រមទាំងមានការប្រើប្រាស់ និងអាស្រ័យផល លើអចលនវត្ថុនោះជាបន្តបន្ទាប់ ដែលការតតាំងនេះទៀតសោត គឺអាចប្រើប្រាស់បានត្រឹមអំឡុងពេល ១៥ (ដប់ប្រាំ)ឆ្នាំ។[៨២]

**សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍** សិទ្ធិទទួលបានថ្លៃឈ្នួលតាមពេលវេលាដែលបានកំណត់ ឬបង់នៅរាល់ដំណាច់ឆ្នាំក្នុងករណី ដែលមិនបានកំណត់ ឬបង់នៅក្រោយរដូវប្រមូលផល។ សិទ្ធិទាមទារតម្លើងថ្លៃឈ្នួល ដែលសិទ្ធិនេះអាចទាមទារតាមផ្លូវតុលាការឱ្យតម្លើងថ្លៃឈ្នួល ក្នុងករណីថ្លៃឈ្នួលមិនសមរម្យដោយយោងតាមស្ថានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចជាក់ស្តែង និងមានសិទ្ធិរំលាយសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងករណីអ្នកជួលអចិន្ត្រៃយ៍មិនបានបង់ថ្លៃឈ្នួលក្នុងកំឡុងពេល ៣ឆ្នាំ។ អ្នកឱ្យជួលអចិន្ត្រៃយ៍ មានកាតព្វកិច្ចជួសជុលជាចាំបាច់លើការកែលម្អ ឬសំណង់ជាអាទិ៍ និងមិនរាំងស្ទះក្នុងការប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុរបស់អ្នកជួលអចិន្ត្រៃយ៍ និងកាតព្វកិច្ចទទួលបន្ទុកចំណាយចាំបាច់ (សោហ៊ុយចំណាយដើម្បីកែលម្អ និងចំណាយផ្សេងទៀតដើម្បីបង្កើនតម្លៃអចលនវត្ថុ)។

**សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជួលអចិន្ត្រៃយ៍** សិទ្ធិទាមទារឱ្យបញ្ចុះថ្លៃឈ្នួល ដែលអាចទាមទារតាមផ្លូវតុលាការឱ្យបញ្ចុះថ្លៃឈ្នួល ក្នុងករណីតម្លៃមិនសមរម្យដោយយោងតាមស្ថានភាពផ្សេងៗ។[៨៣] សិទ្ធិធ្វើអនុប្បទាន ឬចាត់ចែងផ្សេងទៀត (អាចយកទៅជួលបន្តដាក់ធានាបំណុល ជាកម្មវត្ថុនៃសន្តតិកម្ម) សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (សិទ្ធិដូចដែលកម្មសិទ្ធិករមាន) សិទ្ធិរំលាយសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងករណីមិនទទួលបានចំណេញសោះ ពីអចលនវត្ថុក្នុងអំឡុងពេល៣ឆ្នាំ ដោយសារស្ថានភាពដែលមិនអាចព្យាករទុកជាមុនបាន ឬដោយសារប្រធានសក្តិ ឬក្នុងករណីដែលប្រាក់ចំណេញប្រចាំឆ្នាំ ដែលនឹងបានមកពីអចលនវត្ថុនៅពេលអនាគតពុំមានលទ្ធភាព អាចលើសថ្លៃឈ្នួលសម្រាប់មួយឆ្នាំបាន ដោយសារការខូចខាតផ្នែកណាមួយនៃអចលនវត្ថុនោះ។[៨៤] អ្នកជួលអចិន្ត្រៃយ៍មានកាតព្វកិច្ចបង់ថ្លៃឈ្នួលឱ្យទាន់ពេលវេលាកំណត់ ថែរក្សាអចលនវត្ថុ ដោយត្រូវប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុក្នុងនាមជាអ្នកគ្រប់គ្រប់ដោយសុចរិត។

**ការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍** នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ មិនអាចទាមទារឱ្យ

[៨២] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៦

[៨៣] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៩

[៨៤] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥២

អ្នកជួលអចិន្ត្រៃយ៍ធ្វើបដិទានចំពោះអចលនវត្ថុ (ធ្វើឱ្យទៅស្ថានភាពដើម) វិញបានឡើយ។ លើកលែងតែស្ថិត ក្នុងករណី ដែលអ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញ ឬបំប្លែងនូវទ្រង់ទ្រាយដើមរបស់អចលនវត្ថុនោះ ទើបអ្នកឱ្យ ជួលអចិន្ត្រៃយ៍ មានសិទ្ធិទាមទារឱ្យធ្វើការបដិទានឡើងវិញបាន។[៨៥] លើសពីនេះទៅទៀតចំពោះសំណង់ ឬការ កែលម្អជាអាទិ៍ ដែលអ្នកជួលអចិន្ត្រៃយ៍បានសាងសង់ ឬកែលម្អ គឺត្រូវក្លាយជាកម្មសិទ្ធិរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍ ប៉ុន្តែបើទោះបីជាច្បាប់បានកំណត់បែបនេះក៏ដោយ ក៏ភាគីនៃសិទ្ធិជួលអចិន្ត្រៃយ៍ អាចធ្វើការសន្យាពិសេសផ្សេង ពីការកំណត់ខាងលើនេះ ប៉ុន្តែការសន្យាពិសេសនោះ ត្រូវធ្វើការចុះបញ្ជីទើបអាចតតាំងចំពោះតតិយជនបាន។

សរុបមកសិទ្ធិជួលអចិន្ត្រៃយ៍ គឺជាសិទ្ធិមួយដែលអនុញ្ញាត និងផ្តល់អត្ថប្រយោជន៍ឱ្យអ្នកជួលអចិន្ត្រៃយ៍ អាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុក្នុងរយៈពេលវែង ដោយសិទ្ធិជួលអចិន្ត្រៃយ៍បានចូលរួមចំណែក យ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិឆ្ពោះទៅកាន់អនាគតដ៏រីកចម្រើន តាមរយៈការសាងសង់ សហគ្រាស ពាណិជ្ជកម្ម (រោងចក្រ) ការសាងសង់អគារសហកម្មសិទ្ធិ (ខុនដូ) ការសាងសង់ផ្ទះល្វែង និងសំណង់ អគារផ្សេងៗជាច្រើនទៀត ដែលសុទ្ធសឹងតែជួយលើកកម្ពស់ដល់វិស័យសេដ្ឋកិច្ចជាតិ និងជាកត្តារួមចំណែក ដែលប្រទេសជាតិពុំអាចខ្វះបានផងដែរ។

**១.៣.២.៤. ផលុបភោគដែលត្រូវបានចុះបញ្ជី**

ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។ មានអត្ថន័យថា ផលុបភោគ គឺជារបបគតិយុត្តមួយ ដែលផ្តល់សិទ្ធិឱ្យបុគ្គលម្នាក់ហៅថា ផលុបភោគី មានសិទ្ធិ ប្រើប្រាស់ដីសម្រាប់ដាំដំណាំ ធ្វើស្រែចំការ ឬផ្ទះដើរចូលបន្តឱ្យទៅអ្នកដទៃទៀតបាន និងមានសិទ្ធិអាស្រ័យផល ធម្មជាតិ ដែលមានដូចជាផលដំណាំ ហើយលើសពីនេះទៅទៀតដល់រូបភោគី អាចធ្វើការអាស្រ័យលើស៊ីវិល គឺប្រាក់ឈ្នួលកើតពីជួលអគារឱ្យអ្នកដទៃផងដែរ។[៨៦]

ផលុបភោគ អាចត្រូវបានបង្កើតឡើងតាមលិខិតលាយលក្ខណ៍អក្សរ ឬមិនតាមលិខិតលាយលក្ខណ៍អក្សរ (ផ្ទាល់មាត់) ហើយចំពោះអាណត្តិនៃការបង្កើតផលុបភោគ អាចបង្កើតបានក្នុងរយៈពេលកំណត់ណាមួយ ដែលមិនឱ្យលើសពី មួយជីវិតរបស់ផលុបភោគី។ បន្ទាប់ពីការបង្កើតផលុបភោគរួច ដើម្បីមានសិទ្ធិតតាំងចំពោះ បុគ្គលផ្សេងទៀត ដែលបានអះអាងលើអចលនវត្ថុ (ដី,អគារ/ផ្ទះ) ផលុបភោគីត្រូវចុះបញ្ជីនៅមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ផលភោគី មានសិទ្ធិអាស្រ័យផលធម្មជាតិ (ទទួលបានដំណាំដែលដុះលើដី), សិទ្ធិអាស្រ័យលើស៊ីវិល (ប្រាក់ឈ្នួល ដែលកើតចេញពីការជួលដី,អគារ/ផ្ទះ), សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិ

[៨៥] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥៤

[៨៦] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥៦

ប្រត្យក្ស ដូចដែលម្ចាស់កម្មសិទ្ធិករនៃដី មានសិទ្ធិយកអចលនវត្ថុ(ដី,អគារ/ផ្ទះ) ដែលជាកម្មវត្ថុនៃផលុបភោគ ទៅជួលបន្តបាន ដែលមានថេរវេលាមិនឱ្យលើសពី ៣(បី)ឆ្នាំ និងអាចបន្តសាជាថ្មីបាន ដោយមិនឱ្យលើសពី ៣(បី)ឆ្នាំ។

ផលុបភោគី ត្រូវមានករណីយកិច្ចជូនដំណឹងដោយគ្មានការយឺតយ៉ាវ ទៅម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុ (ដី,អគារ/ផ្ទះ) ក្នុងករណីមានបុគ្គលណាផ្សេងទៀត ដែលអះអាងថាខ្លួនមានសិទ្ធិលើអចលនវត្ថុ (ដី,អគារ/ផ្ទះ), ករណីយកិច្ចថែរក្សាអចលនវត្ថុ(ដី,អគារ/ផ្ទះ) ឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃផលុបភោគ, ករណីយកិច្ចចេញថ្លៃសេវាជួសជុលថែទាំអចលនវត្ថុ (លើកលែងតែជួសជុលធំៗ ជាបន្ទុករបស់កម្មសិទ្ធិករ), ករណីយកិច្ចទទួលបន្ទុកបង់ពន្ធ និងអាករ (បង់ពន្ធផ្ទះ បង់ពន្ធដី) និងករណីយកិច្ចបង់ថ្លៃសេវាធានារ៉ាប់រងអចលនវត្ថុជាដើម។

ផលុបភោគ ត្រូវបញ្ចប់នៅក្នុងករណីដូចជា មរណភាពនៃផលុបភោគី, ក្នុងអំឡុងពេលបញ្ចប់មកដល់, ផលុបភោគីប្រព្រឹត្តផ្ទុយពីខ្លឹមសារនៃកិច្ចព្រមព្រៀងផលុបភោគ ឬបញ្ញត្តិច្បាប់(បង្កឱ្យមានការខូចខាត, ថែរក្សាមិនបានត្រឹមត្រូវ), ចំពោះផលុបភោគដែលមិនធ្វើឡើងក្រោមទម្រង់ជាលាយលក្ខណ៍អក្សរ កម្មសិទ្ធិករ (ម្ចាស់ ដី អគារ/ផ្ទះ) អាចស្នើសុំឱ្យរំលត់ពេលណាក៏បាន។

ក្នុងករណីស្នើសុំរំលត់ផលុបភោគ ដោយមិនបញ្ជាក់អំពីពេលរលត់ នោះផលុបភោគត្រូវរលត់នៅក្នុងអំឡុងពេល ដែលបានកំណត់បានកន្លងហួសទៅដូចជា ៣(បី)ខែ ចំពោះអគារ, ១(មួយ)ឆ្នាំចំពោះដី, មុនពេលផលុបភោគីចាប់ផ្តើមការងារកសិកម្ម សម្រាប់រដូវបន្ទាប់ (ចំពោះដីមានរដូវប្រមូលផល)។

ជាចុងក្រោយយើងក៏អាចសង្កេតបានថា ផលុបភោគ គឺជារបបគតិយុត្តមួយ ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងជារបបដែលបង្កើតឡើង តាមរយៈការលាយលក្ខណ៍អក្សរ ឬមិនលាយលក្ខណ៍អក្សរក៏បាន, យកថ្លៃឈ្នួល ឬមិនយកថ្លៃឈ្នួលក៏បាន តាមរយៈការព្រមព្រៀងគ្នាជាក់ស្តែងរវាងកម្មសិទ្ធិករ និងផលុបភោគី។ ម្យ៉ាងវិញទៀត ផលុបភោគីត្រូវគោរពតាមសិទ្ធិ ក៏ដូចជាករណីយកិច្ចដូចដែលបានបញ្ញត្តិជៀសវាងមានបញ្ហាផ្សេងៗ កើតឡើងដូចជាការបញ្ចប់នូវបលុបភោគពីកម្មសិទ្ធិករជាដើម។[៨៣]

[៨៣] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៥៨ កថាខណ្ឌ១-២

# ជំពូកទី២
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះ
# អចលនវត្ថុ

# ជំពូកទី២

# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

## ២.១. នីតិវិធីនៃការដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ

នៅមុនពេលដែលចាប់ផ្តើមការអនុវត្តដោយបង្ខំ ម្ចាស់បំណុលតែងតែចង់បានការអនុវត្តដោយស្ម័គ្រចិត្ត ដោយចំណេញទាំងប្រាក់និង ពេលវេលាផងដែរ។ ប៉ុន្តែបើគ្មានការស្ម័គ្រចិត្តទេ ទើបឈានទៅដល់ការអនុវត្ត ដោយបង្ខំ។ ម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ មានកាតព្វកិច្ចស្រាវជ្រាវរកអចលនវត្ថុរបស់កូនបំណុល ដោយខ្លួនឯង ដោយនេះមិនមែនជាកាតព្វកិច្ចរបស់តុលាការអនុវត្តនោះទេ។

ការអនុវត្តដោយបង្ខំ ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ពាក្យសុំឱ្យអនុវត្ត ដោយបង្ខំ ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ[៨៨] ទៅស្ថាប័នអនុវត្ត ដែលមានសមត្ថកិច្ច គឺតុលាការអនុវត្ត និងអាជ្ញាសាលា។[៨៩]

**ឧទាហរណ៍** បើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំស្ថិតនៅក្នុងខេត្តកំពត នោះម្ចាស់បំណុល ត្រូវយកពាក្យសុំទៅដាក់នៅលេខាធិការដ្ឋានរដ្ឋបាល នៃសាលាដំបូងខេត្តកំពត។

នៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ ត្រូវមានបញ្ជាក់អំពីប្រភេទនៃការអនុវត្តដោយបង្ខំដែលសុំឱ្យធ្វើ (ការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬការបង្ខំដោយប្រយោល)។ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំ ដោយផ្ទាល់ ត្រូវបញ្ជាក់ផងដែរលើលិខិតនោះនូវទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ (ចលនវត្ថុ អចលនវត្ថុ ឬសិទ្ធិលើបំណុល ជាអាទិ៍) ហើយក្នុងករណី ដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬការ បង្ខំដោយប្រយោល ត្រូវបញ្ជាក់នូវខ្លឹមសារនៃសេចក្តីសម្រេចដែលទាមទារឱ្យមានការអនុវត្ត ព្រមទាំងភ្ជាប់ មកជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តផងដែរ។

បន្ថែមពីនេះទៅទៀត អាស្រ័យទៅតាមប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលសុំឱ្យធ្វើនៅក្នុងករណី មួយចំនួនមានការតម្រូវឱ្យសរសេររៀបរាប់ក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ អំពីចំណុចដើម្បីកំណត់ដោយ ជាក់លាក់នូវកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ក៏ដូចជាការតម្រូវឱ្យដាក់ឯកសារបញ្ជាក់មួយចំនួនដែលពាក់ព័ន្ធទៅ នឹងកម្មវត្ថុនោះផងដែរ។[៩០] នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ម្ចាស់បំណុលត្រូវបង់ពន្ធដាក់ពាក្យសុំទៅ

[៨៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦,មាត្រា៣៤៩ កថាខណ្ឌ១

[៨៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៣៦ កថាខណ្ឌ២

[៩០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤០៣-មាត្រា៤១៧ កថាខណ្ឌ៣ និងមាត្រា៤៥៥ កថាខណ្ឌ៣

ស្ថាប័នអនុវត្ត ឬត្រូវបង់ប្រាក់កម្រៃជាមុន ហើយលើសពីនេះ ក៏ត្រូវបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំផងដែរ។[៩១]

### ២.១.១. លិខិតបញ្ជាក់ពីការបញ្ជូនលិខិតអនុវត្ត

យោងទៅតាម មាត្រា៣៦០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការអនុវត្តដោយបង្ខំអាចចាប់ផ្តើមធ្វើបានក្នុងករណីឯកសារចម្លងយថាភូត ឬឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬសេចក្តីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ជាមុនសិន។ នៅក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្តល់តាមបញ្ញត្តិនៃមាត្រា៣៥៦ (រូបមន្តអនុវត្តពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី) ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃរូបមន្តអនុវត្ត និងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់តាមបញ្ញត្តិនៃមាត្រា៣៥៦ នោះក៏ត្រូវបញ្ជូនទៅជាមុនផងដែរ។ លិខិតអនុវត្តត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន។ លិខិតបញ្ជាក់ពីការបានបញ្ជូន គឺបញ្ជាក់ពីការដែលបានបញ្ជូនលិខិតរួចហើយ។ ចាំបាច់ត្រូវបញ្ជូនលិខិតអនុវត្ត ដើម្បីជូនដំណឹងទុកជាមុន ចំពោះកូនបំណុលនៃការអនុវត្តថា ខ្លឹមសារអ្វីខ្លះដែលនឹងត្រូវបានអនុវត្តដោយបង្ខំ។ ដោយឡែកក្នុងចំណោមលិខិតអនុវត្តសាលក្រម ត្រូវបានបញ្ជូនទៅឱ្យភាគីរួចហើយ ដូច្នេះពុំចាំបាច់បញ្ជូនម្តងទៀតទេ។[៩២]

### ២.១.២. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

យោងទៅតាម មាត្រា៣៤៩ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ត្រូវតែមានបញ្ជាក់ចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់ អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត ។
- សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំ ដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។
- ខ្លឹមសារនៃសេចក្តីសម្រេច ដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។
- ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ក៏ត្រូវភ្ជាប់មកជាមួយឯកសារចាំបាច់ដូចជា៖

[៩១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៧៥-មាត្រា២៤-មាត្រា២៥-មាត្រា២៨

[៩២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា១៩០

- លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត ដែលសំដៅទៅដល់លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលត្រូវបានផ្តល់រូបមន្តអនុវត្ត។
- លិខិតបញ្ជាក់ការបានបញ្ជូន ដើម្បីបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត។[៩៣]
- ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុជាអាទិ៍ ដើម្បីបញ្ជាក់ថាអចលនវត្ថុ គឺជាកម្មសិទ្ធិរបស់កូនបំណុល។[៩៤]

## ២.២. ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

ការចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ គឺផ្អែកទៅលើពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលបានដាក់មកកាន់ស្ថាប័នអនុវត្តមានតុលាការអនុវត្ត និងអាជ្ញាសាលា មានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់តាមផ្លូវច្បាប់ហើយ នោះតុលាការនឹងចាប់ផ្តើមការលក់ដោយបង្ខំ ដោយចេញដីកាសម្រេចចាប់ផ្តើម ការលក់ដោយបង្ខំយោងទៅតាមមាត្រា៤១៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីលក់នូវអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីនៃអចលនវត្ថុរួមទាំងការរឹបអូសអចលនវត្ថុនោះ ដើម្បីធានាឱ្យបានក្នុងការបំពេញការសងសិទ្ធិលើបំណុល ដែលម្ចាស់បំណុលនៃការអនុវត្តបានទាមទារ និងមានកំណត់ក្នុងឯកសារភ្ជាប់ស្តីពីលិខិតអនុវត្ត និងបញ្ជីរាយសិទ្ធិលើបំណុលដែលទាមទារ។

ក្នុងករណី ដែលតុលាការអនុវត្ត ដែលទទួលបានពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលពុំមានល័ក្ខខ័ណ្ឌត្រឹមត្រូវ ឬពុំមានឯកសារចាំបាច់នានា នោះតុលាការអនុវត្ត គឺត្រូវលើកចោលនូវពាក្យសុំនោះ និងផ្តល់សិទ្ធិចំពោះភាគីនៃម្ចាស់បំណុលនៃការអនុវត្តក្នុងការប្តឹងជំទាស់ទៅកាន់តុលាការជាន់ខ្ពស់។[៩៥]

## ២.៣. នីតិវិធីនៃការរឹបអូសចំពោះការអនុវត្តដោយបង្ខំ

ការរឹបអូសចំពោះអចលនវត្ថុដោយបង្ខំត្រូវធ្វើឡើងដោយមានការចេញនូវលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីជាមួយការចុះបញ្ជីអំពីការរឹបអូស ដែលធ្វើឡើងដោយសមត្ថកិច្ចជំនាញ និងការបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ។

ការប្រកាសនៃការរឹបអូស ចំពោះការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺមានគោលបំណងដើម្បីចង្អុលបង្ហាញទៅដល់ម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និងអចលនវត្ថុ ក្នុងការអនុវត្តនូវដីកាសម្រេចលក់ដោយបង្ខំចំពោះអចលនវត្ថុឱ្យមានអនុភាព។

---

[៩៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៦០

[៩៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤១៧ កថាខណ្ឌ៣ ចំណុច ក-ខ

[៩៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤១៩ កថាខណ្ឌ២-កថាខណ្ឌ៣

### ២.៣.១. ការចុះបញ្ជីនៃការរឹបអូស និងរបាយការណ៍នៃការរឹបអូស

នៅពេលដែលដីកាសម្រេចនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុត្រូវបានចេញ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ដើម្បីធ្វើការចុះបញ្ជីអំពីការរឹបអូសទៅស្ថាប័នដែលមានសមត្ថកិច្ចជំនាញ។

**ឧទាហរណ៍** ដូចជារដ្ឋបាល សុរិយោដី រាជធានី-ខេត្ត ជាអាទិ៍ ដើម្បីឱ្យសមត្ថកិច្ចធ្វើការចុះបញ្ជី អំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចនោះជាបន្ទាន់។ ដោយពុំតម្រូវឱ្យភាគីម្ចាស់បំណុលនៃការអនុវត្តធ្វើការដាក់ពាក្យសុំដោយឡែកទៀតនោះទេ។ លិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ដែលបានដាក់ដែលមានសមត្ថកិច្ចទទួលបន្ទុកក្នុងការធ្វើការចុះបញ្ជី ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី។ ក្រៅពីនេះត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃលិខិតផ្ទុកផ្តាក់។

ក្នុងករណី បានធ្វើការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើការផ្ទុកផ្តាក់របស់ក្រឡាបញ្ជីនៃតុលាការអនុវត្តហើយ សមត្ថកិច្ចនៃស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត ត្រូវធ្វើការផ្ញើឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជីវិញ។ នៅក្នុងចំណុចនេះមានន័យថា បើសិនជាអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីត្រូវបានអនុវត្ត ឬត្រូវបានចាប់ផ្តើមការលក់ដោយបង្ខំ ដោយផ្អែកទៅតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី នោះស្ថានប័នដែលមានសមត្ថកិច្ចត្រូវធ្វើការចុះនូវបញ្ជីអំពីសញ្ញាណនៃអចលនវត្ថុនោះ និងចុះបញ្ជីដើម្បីរក្សាទុកនូវកម្មសិទ្ធិដីនោះព្រមទាំងធ្វើការចុះបញ្ជីអំពីការរឹបអូសនោះ។

តុលាការអនុវត្ត គប្បីរង់ចាំការបញ្ជូនរបាយការណ៍របស់មន្ត្រីជំនាញដែលបង្ហាញឱ្យឃើញថា ការរឹបអូសចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តត្រូវបានចុះបញ្ជីត្រឹមត្រូវរួចជាមុនសិន ចាំបន្តចាត់ការ ឬចេញលិខិតនីតិវិធីបន្តទៀត ដើម្បីជៀសវាងការប៉ះពាល់ទៅដល់អានុភាពនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ។

### ២.៣.២. អានុភាពនៃការរឹបអូស

ជាគោលការណ៍ អានុភាពនៃការរឹបអូសកើតឡើង នៅពេលដែលដីកាសម្រេចចាប់ផ្តើមនោះត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។ ក៏ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើឡើងនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្តើម នោះអានុភាពនឹងកើតឡើងនៅពេលបានចុះបញ្ជី។ នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត នៅមុនពេលចុះបញ្ជីអំពីការរឹបអូសនោះ ដូចជាទុកឱកាសឱ្យកូនបំណុលអាចធ្វើអនុប្បទាននូវអចលនវត្ថុ ដែលជាកម្មវត្ថុនោះ

ទៅឱ្យតតិយជន ហើយការចុះបញ្ជីអំពីកម្មសិទ្ធិរបស់តតិយជននោះ អាចនឹងធ្វើបានមុនការចុះបញ្ជីអំពីការរឹបអូសផង។

នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អានុភាពចម្បងនៃការរឹបអូស គឺការហាមឃាត់មិនឱ្យធ្វើការចាត់ចែង នៅខណៈពេលដែលការរឹបអូសបង្កើតអានុភាព ដោយការបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំទៅឱ្យកូនបំណុលនៃការអនុវត្ត ឬដោយការចុះបញ្ជីអំពីការរឹបអូស នោះកូនបំណុលនឹងបាត់បង់សិទ្ធិចាត់ចែងនូវអចលនវត្ថុដែលជាកម្មវត្ថុ ហើយអាជ្ញាធររដ្ឋ ទទួលបាននូវសិទ្ធិចាត់ចែងនោះវិញ។ ប្រសិនបើកូនបំណុលនៃការអនុវត្ត ធ្វើអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុទៅឱ្យតតិយជន ក្រោយពេលដែលការរឹបអូសបង្កើតអានុភាព អនុប្បទាននោះត្រូវទុកជាមោឃៈ។ ក៏ប៉ុន្តែ មោឃភាពនេះគ្រាន់តែមានន័យថា ការធ្វើអនុប្បទាននោះមិនអាចយកទៅតតាំងបានជាមួយនឹងម្ចាស់បំណុល ដែលបានធ្វើការរឹបអូសតែប៉ុណ្ណោះ ពោលគឺវាជាមោឃភាពមិនដាច់ខាត។ ហេតុនេះហើយ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តធ្វើអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុទៅឱ្យតតិយជន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស នោះគេអាចនឹងចុះបញ្ជីអំពីលទ្ធកម្មនៃកម្មសិទ្ធិដោយតតិយជនដែលជាអនុប្បទានិកនោះបាន។ ក៏ប៉ុន្តែ ការចុះបញ្ជីនេះពុំមានសុពលភាព និងពុំមានន័យអ្វីទេ ចំពោះនីតិវិធីនៃការលក់ដោយបង្ខំ ដែលបានចាប់ផ្តើមឡើងដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ហើយនីតិវិធីនៃការលក់ដោយបង្ខំនោះ នៅតែបន្តដំណើរការដដែល។ អនុប្បទានិក មិនអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ដោយអះអាងចំពោះម្ចាស់បំណុលនៃការអនុវត្តថា អចលនវត្ថុដែលជាកម្មវត្ថុនោះ គឺជាកម្មសិទ្ធិរបស់ខ្លួនទេ។ ជាងនេះទៅទៀត ប្រសិនបើអចលនវត្ថុ ដែលពាក់ព័ន្ធនោះត្រូវបានលក់ទៅឱ្យអ្នកទិញតាមនីតិវិធីនៃការលក់ដោយបង្ខំ នោះអនុប្បទានពីមុនដោយប្រឆាំងនឹងការរឹបអូស ត្រូវបាត់បង់អានុភាព ហើយការចុះបញ្ជីអំពីលទ្ធកម្មនៃកម្មសិទ្ធិដោយអនុប្បទានិក ក៏ត្រូវលុបចោលដែរ។ [៩៦] ក៏ប៉ុន្តែ ប្រសិនបើអានុភាពនៃការរឹបអូស ត្រូវរលត់ទៅវិញដោយសារការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬដោយសារការលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ នោះការចាត់ចែងដែលបានធ្វើនៅក្រោយការរឹបអូសក៏ដោយនឹងមានអានុភាព។ អានុភាពនៃការរឹបអូសមានទៅលើអចលនវត្ថុដែលជាកម្មវត្ថុនោះ ព្រមទាំងលើវត្ថុដែលភ្ជាប់នឹងក្លាយទៅជាផ្នែកមួយនៃអចលនវត្ថុនោះ និងលើវត្ថុចំណុះ និងសិទ្ធិចំណុះនៃអចលនវត្ថុនោះផងដែរ។[៩៧]

**ឧទាហរណ៍** វត្ថុភ្ជាប់មានដូចជា អាគារ និងដើមឈើនៅលើដី ដែលជាកម្មវត្ថុនៃការរឹបអូស។ វត្ថុចំណុះមានដូចជាគ្រឿងសាងសង់ ក្នុងករណីនៃការរឹបអូសអាគារដែលបានចុះបញ្ជី។ ចំណែកសិទ្ធិចំណុះមានដូចជាសេវភាពនៃដីដែលនៅជាប់គ្នា ដែលជាសិទ្ធិរបស់កូនបំណុលក្នុងនាមជាកម្មសិទ្ធិករនៃដីនោះ។

[៩៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៤៨, កថាខណ្ឌ១ ចំណុច ខ

[៩៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤២១, កថាខណ្ឌ១

ការរឹបអូសអចលនវត្ថុ គ្រាន់តែជាការរារាំងកូនបំណុលមិនឱ្យធ្វើការចាត់ចែងតែប៉ុណ្ណោះ ពោលគឺមិនអាចរារាំងសិទ្ធិកាន់កាប់របស់កូនបំណុលនោះទេ ទោះជានៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាពក៏ដោយ ក៏កូនបំណុលនៅតែអាចប្រើប្រាស់ ឬអាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើប្រាស់ធម្មតាបាន។[៩៨]

**ឧទាហរណ៍** កូនបំណុលនៅតែអាចបន្តស្នាក់នៅក្នុងផ្ទះ ដែលស្ថិតនៅលើដីដែលបានរឹបអូស ឬនៅតែអាចបន្តបង្កបង្កើនផលលើដីកសិកម្មដែលបានរឹបអូស។ ម៉្យាងទៀតប្រសិនបើដី ឬអាគារនៅលើដីនោះកំពុងជួលឱ្យអ្នកដទៃ កូនបំណុលនៅតែអាចទទួលយកប្រាក់ឈ្នួលដដែល ក៏ប៉ុន្តែ ចំណុចនេះមិនត្រូវឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុតាមនីតិវិធីនៃការអនុវត្តសិទ្ធិលើប្រាតិភោគ នៅពេលដែលនីតិវិធីនៃការលក់ដោយបង្ខំ ដែលបានប្រព្រឹត្តទៅក្នុងនាមជាការអនុវត្តសិទ្ធិលើប្រាតិភោគ ត្រូវបានចាប់ផ្តើមត្រួតគ្នាទៅលើអចលនវត្ថុតែមួយនោះ។ ផ្ទុយទៅវិញ គួរកត់សម្គាល់ថាការបង្កើតសិទ្ធិប្រើប្រាស់ថ្មី ដែលនឹងធ្វើឱ្យថ្លៃលក់អចលនវត្ថុនោះធ្លាក់ចុះត្រូវបានចាត់ទុកថាជាការចាត់ចែង ហើយត្រូវបានហាមឃាត់។

### ២.៣.៣. នីតិវិធីវាយតម្លៃ និងគណនា

ក្រោយពេលដែលតុលាការអនុវត្តបានទទួលនូវរបាយការណ៍ អំពីការចុះបញ្ជីនៃអចលនវត្ថុពីសមត្ថកិច្ចជំនាញរួចរាល់ហើយ តុលាការអនុវត្តនឹងធ្វើការជ្រើសតាំងអ្នកវាយតម្លៃ និងធ្វើការបង្គាប់ឱ្យវាយតម្លៃទៅលើអចលនវត្ថុដែលបានធ្វើការរឹបអូសនោះ។[៩៩] បុគ្គលដែលត្រូវបានជ្រើសតាំងដោយតុលាការអនុវត្ត មានសិទ្ធិអំណាចដើម្បីសុំជំនួយពីអាជ្ញាសាលាបាន លុះត្រាតែទទួលបានការអនុញ្ញាតពីតុលាការអនុវត្តជាមុនសិន។ នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជន ដែលកាន់កាប់អចលនវត្ថុនោះបាន។[១០០]

ក្នុងការវាយតម្លៃទៅអចលនវត្ថុនៃការអនុវត្តនោះ បុគ្គលដែលត្រូវបានតុលាការអនុវត្តជ្រើសតាំងនោះត្រូវធ្វើការស្រាវជ្រាវដោយផ្អែកទៅលើ ទំហំផ្ទៃដី ទីតាំង ថាតើជាដីទំនេរ ឬក៏អាគារ? មាននរណាដែលកំពុងកាន់កាប់ទៅលើដី ឬអាគារនោះដែរឬទេ? តើមានភ្ជាប់ទៅជាមួយសិទ្ធិប្រាតិភោគដែរឬទេ?

ក្រោយពីបានការធ្វើការស្រាវជ្រាវទៅលើអចលនវត្ថុនៃការអនុវត្តនោះរួចរាល់ហើយ បុគ្គលដែលត្រូវបានជ្រើសតាំង ត្រូវធ្វើការវាយតម្លៃទៅលើអចលនវត្ថុនោះ ដោយផ្អែកទៅតាមលទ្ធផលដែលខ្លួនស្រាវជ្រាវបាន និងត្រូវដាក់ជូនដល់តុលាការអនុវត្តជាទម្រង់លាយល័ក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវ និងវាយតម្លៃលើអចលនវត្ថុនោះ។[១០១]

---

[៩៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤២១ កថាខណ្ឌ៣

[៩៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣០ កថាខណ្ឌ១

[១០០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣០ កថាខណ្ឌ២-៣

[១០១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣០ កថាខណ្ឌ៥

❖ **ឯកសារលម្អិតអំពីអចលនវត្ថុ**

ក្រោយពីតុលាការអនុវត្តបានទទួលនូវលទ្ធផលស្រាវជ្រាវ និងវាយតម្លៃពីបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងរួចមក តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីអចលវត្ថុនោះ ហើយត្រូវតែធ្វើការថតចម្លងទុកឱ្យសាធារណៈជនមើល។ បន្ទាប់មក តុលាការនឹងចេញដីកាសម្រេចមួយ ដើម្បីកំណត់ការលក់អចនវត្ថុនោះក្នុងតម្លៃអប្បបរិមា ដោយផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវ និងវាយតម្លៃរបស់អ្នកវាយតម្លៃនោះ។ ក្នុងករណីចាំបាច់តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បបរិមាបាន។[១០២] ក្នុងន័យនេះ តុលាការអនុវត្តអាចធ្វើការពិចារណាទៅលើតម្លៃអប្បបរិមា ដែលបានក្លាយទៅជាតម្លៃមួយដែលមិនសមរម្យ ដែលបណ្តាលមកពីការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច ឬករណីដទៃទៀតដែលយល់ឃើញថា តម្លៃអប្បបរិមាក្លាយទៅជាតម្លៃមិនសមរម្យនោះ គឺតុលាការអនុវត្តអាចផ្លាស់នូវតម្លៃលក់អប្បបរិមាបាន។

នៅពេលដែលតុលាការអនុវត្តបានចេញដីកាសម្រេចកំណត់លក់ក្នុងតម្លៃអប្បរិមារួចហើយ តុលាការនឹងចេញដីកាសម្រេចមួយទៀត ដែលសម្រេចបង្គាប់ឱ្យចាប់ផ្តើមការលក់ និងផ្តល់ព័ត៌មាន ឬជូនដំណឹងដល់ជនដែលពាក់ព័ន្ធទាំងអស់។ ជាទូទៅនៅក្នុង **ដីកាសម្រេចកំណត់លក់តម្លៃអប្បបរិមា** និង**ដីកាសម្រេចបង្គាប់ឱ្យអនុវត្តការលក់** គឺតែងតែចុះកាលបរិច្ឆេទក្នុងថ្ងៃតែមួយ ហើយដីកាសម្រេចនេះ គឺត្រូវបានបញ្ជូនទៅអាជ្ញាសាលា ដែលជាជំនួយនៃតុលាការអនុវត្តដើម្បីបន្តនីតិវិធី។

**២.៣.៤. នីតិវិធីលក់ដោយបង្ខំ**

ការលក់ដោយបង្ខំ គឺជាប្រភេទនៃការលក់ដែលធ្វើឡើងដោយអាជ្ញាធររដ្ឋអនុវត្តសិទ្ធិចាត់ចែង ដែលខ្លួនបានទទួលតាមរយៈការរឹបអូស។ ការលក់ដោយបង្ខំមានពីរប្រភេទ ការលក់ឡាយឡុងដោយស្រោមសំបុត្រ និងការលក់ឡាយឡុងដោយផ្ទាល់មាត់។[១០៣] ដែលសុទ្ធសឹងតែមានគោលគំនិតក្នុងការប្រកាសឱ្យអ្នកស្នើសុំទិញមកទិញវត្ថុ ហើយកំណត់យកបុគ្គលម្នាក់ពីក្នុងចំណោមអ្នកទាំងនោះឱ្យធ្វើជាអ្នកទិញ។

**២.៣.៤.១. ការលក់ឡាយឡុងដោយស្រោមសំបុត្រ**

ការលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីដែលឱ្យអ្នកមានបំណងទិញដែលបានចូលរួមនៅកាលបរិច្ឆេទនៃការលក់ឡាយឡុងស្នើសុំទិញដោយលិខិតឡាយឡុង ដែលបានសរសេរនូវតម្លៃឡាយឡុងបន្ទាប់មកធ្វើការបើកលិខិត ហើយកំណត់យកអ្នកសុំទិញក្នុងតម្លៃអតិបរិមានៅទីនោះ។ ការលក់ទៅតាមវិធីនេះ គឺមិនអាចឱ្យអ្នកដែលមានបំណងទិញផ្សេងទៀតបានដឹងនោះទេ។ ហើយក៏ពុំមានការបារម្ភអំពីបរិយាកាស

[១០២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣២ កថាខណ្ឌ២

[១០៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣៦

នៃការលក់ ឬការដែលត្រូវបានដៃគូប្រកួតប្រជែង ដែលមានលក្ខណៈមិនល្អដែរ។ ហេតុដូច្នេះហើយ វិធីលក់ឡាយឡុងដោយស្រោមសំបុត្រអាចគិតថាជាវិធីគោលក្នុងការលក់អចលនវត្ថុ។

**២.៣.៤.២. ការលក់ឡាយឡុងដោយផ្ទាល់មាត់**

ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីលក់ដែលកំណត់អ្នកសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកមានបំណងទិញស្នើសុំទិញដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ និងឱ្យប្រជែងថ្លៃនោះ។ ការលក់ឡាយឡុងដោយផ្ទាល់មាត់ មានលក្ខណៈពិសេស ត្រង់ចំណុចដែលអ្នកមានបំណងទិញដឹងនូវតម្លៃស្នើសុំរបស់គូប្រជែងឯទៀតទៅវិញទៅមក ហើយប្រជែងតម្លៃស្នើសុំទៅតាមលំដាប់លំដោយ។ វិធីនេះមានភាពងាយស្រួលក្នុងការស្នើសុំទិញ ហើយការប្រជែងត្រូវបានអនុវត្តផ្ទាល់ចំពោះមុខ ហេតុដូច្នេះមានគុណសម្បត្តិដែលអាចសង្ឃឹមនូវការលក់ដោយតម្លៃខ្ពស់ តែផ្ទុយទៅវិញក៏មានគុណវិបត្តិ ដោយសារចាំបាច់ត្រូវតែមានបច្ចេកទេសជំនាញ និងបទពិសោធន៍ដែលជាស្មៀតមួយ ដែលបណ្តាលឱ្យអ្នកជំនួញដែលមានបទពិសោធន៍មានប្រៀបជាង និងជាការលំបាកក្នុងការស្វែងរកការចូលរួមដោយជនទូទៅជាទូលំទូលាយ។

❖ **អំពីការលក់**

ក្រោយពីទទួលបានដីកាបង្គាប់ឱ្យអនុវត្តការលក់ អាជ្ញាសាលាដែលជាស្ថាប័នជំនួយដល់តុលាការអនុវត្ត នឹងធ្វើការដឹកនាំនីតិវិធីនៃការលក់ដោយបង្ខំទៅតាមការកំណត់ដែលមាននៅក្នុងដីកាសម្រេច។

ក្នុងនីតិវិធីនៃការលក់អចលនវត្ថុ គឺតុលាការអនុវត្តត្រូវធ្វើការកំណត់វិធីលក់ដូចដែលបានកំណត់ក្នុងចំណុច.**ការលក់ឡាយឡុងដោយស្រោមសំបុត្រ** និង**ការលក់ឡាយឡុងដោយផ្ទាល់មាត់ខាងលើ**។ ប៉ុន្តែក្នុងករណីដែលតុលាការអនុវត្តពុំអាចលក់ទៅតាមវិធីទាំងពីរខាងលើនេះបាន គឺតុលាការអនុវត្តអាចកំណត់នូវវិធីផ្សេងពីនេះបាន។ [១០៤] បន្ទាប់ពីបានកំណត់នីតិវិធីនៃការលក់ហើយនោះ តុលាការអនុវត្តត្រូវធ្វើការកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ហើយត្រូវឱ្យអាជ្ញាសាលាដើម្បីធ្វើការអនុវត្តលក់នេះ។ គួរបញ្ជាក់ផងដែរថា កូនបំណុលនៃការអនុវត្តមិនអាចធ្វើសំណើទិញបានទេ។ [១០៥] មានន័យថា កូនបំណុលនៃការអនុវត្តពុំអាចក្លាយជាអ្នកទិញបាននោះទេ ដោយហេតុថា បើកូនបំណុលនៃការអនុវត្តមានលទ្ធភាពទ្រព្យធន ដើម្បីស្នើសុំទិញកូនបំណុលនោះ គួរសងដោយស្ម័គ្រចិត្ត ចំពោះម្ចាស់បំណុលនៃការអនុវត្តដោយយកទ្រព្យធននោះ។ ហើយក្នុងការដេញថ្លៃនេះ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុដោយសរសេរនូវចំណុចដូចខាងក្រោមនេះ៖

ក. សញ្ញាណនៃអចលនវត្ថុ

ខ. កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់

[១០៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣៦ កថាខណ្ឌ២

[១០៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣៨

គ. សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរិមា និងអ្នកតំណាង

ឃ. តម្លៃទិញរបស់អ្នកសុំទិញក្នុងតម្លៃអតិបរិមា

ង. ហេតុការណ៍ និងស្ថានភាពបើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរិមា

ច. មូលហេតុ និងវិធានការដែលបានចាត់ធ្វើ។[១០៦]

អាជ្ញាសាលាត្រូវឱ្យអ្នកដែលស្នើសុំទិញក្នុងតម្លៃអតិបរិមា ឬអ្នកតំណាងចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។

❖ **ការកំណត់អ្នកស្នើទិញក្នុងតម្លៃអតិបរិមា**

បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និងបានប្រកាសនូវនាម ឬនាមករណ៍របស់អ្នកទិញ និងថ្លៃលក់ឡាយឡុងនោះ ។

ក្នុងករណីបើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមាមានច្រើននាក់ អាជ្ញាសាលា ត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត។ ក្នុងករណីនេះអ្នកដេញថ្លៃ មិនអាចដេញថ្លៃ ដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ។

❖ **ការបើកកាលបរិច្ឆេទមួយដើម្បីចេញដីកាសម្រេចការលក់**

នៅមុនពេលដែលតុលាការអនុវត្តសម្រេចអនុញ្ញាតលក់ ឬមិនអនុញ្ញាតលក់ តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទមួយដើម្បីចេញដីកាសម្រេចការលក់។ លុះពេលដែលបានកំណត់អំពីកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលាការអនុវត្តត្រូវប្រកាសអំពីកាលបរិច្ឆេទនោះ ទៅដល់ភាគីពាក់ព័ន្ធនឹងផលប្រយោជន៍។

ដោយហេតុថា បើប្រៀបធៀបអចលនវត្ថុទៅនឹងចលនវត្ថុ គឺយល់ឃើញថាអចលនវត្ថុ ជាទូទៅមានតម្លៃខ្ពស់ណាស់ ដូនេះដើម្បីធានាទៅដល់ការលក់ឱ្យមានល័ក្ខណៈហ្មត់ចត់ ក្រោយពេលដែលនីតិវិធីលក់បានបញ្ចប់ដោយអាជ្ញាសាលា តុលាការអនុវត្ត គួរតែចេញដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យលក់ ដោយបានពិនិត្យជាថ្មីនូវនីតិវិធីទាំងអស់ ចាប់តាំងពីដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរហូតដល់ការលក់។

❖ **ការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់**

តុលាការអនុវត្តនឹងធ្វើការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅពេលដែលតុលាការអនុវត្តទទួលបានសំណុំឯកសារ ឬកំណត់ហេតុអំពីការដេញថ្លៃពីអាជ្ញាសាលាដោយរួចរាល់ហើយ នោះតុលាការអនុវត្តនឹងធ្វើ

[១០៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៣៩

ការអនុញ្ញាតលក់អចលនវត្ថុនោះទៅឱ្យបុគ្គលដែលដេញថ្លៃបាន។

❖ **ការចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់**

ប៉ុន្តែក្នុងករណី ដែលតុលាការអនុវត្តចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ ត្រូវទទួលស្គាល់ថាមានហេតុណាមួយដូចកំណត់ក្នុងចំណុចខាងក្រោមនេះ៖

ក. មិនត្រូវចាប់ផ្ដើម ឬបន្តនូវនីតិវិធីនៃការលក់ដោយបង្ខំ

ខ. អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណៈសម្បត្តិ ឬសមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ

គ. មានសេចក្ដីស្នើសុំកុំឱ្យអនុញ្ញាតការលក់

ឃ. មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា

ង. មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់។

ក្នុងករណីដែលមានវិការៈបន្តិចបន្តួច បើត្រូវឱ្យធ្វើសារឡើងវិញជាថ្មីនូវនីតិវិធី ធ្វើឱ្យខាតបង់ពេលវេលា និងសោហ៊ុយនោះ ហេតុដូច្នេះចំណុច ដែលបានរៀបរាប់នូវហេតុជាវិការៈធ្ងន់ធ្ងរដែលមិនត្រូវអនុញ្ញាតឱ្យមានការលក់ បើសិនត្រូវនឹងចំណុចណាមួយក្នុងចំណោមចំណុចខាងលើទាំងនេះ ការលក់នឹងមិនអនុញ្ញាតទេ ហើយបើគ្មានហេតុទាំងនេះទេ ការលក់នឹងត្រូវអនុញ្ញាត។ ចំពោះហេតុនៃការមិនអនុញ្ញាតឱ្យលក់ទាំងនេះ បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍អាចថ្លែងជាយោបល់បាននៅកាលបរិច្ឆេទ ដើម្បីចេញដីកាសម្រេចការលក់។ ទោះជាមាន ឬគ្មានសេចក្ដីថ្លែងយោបល់នេះក៏ដោយ តុលាការអនុវត្តត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃហេតុទាំងនោះដោយឆន្ទានុសិទ្ធិ។[១០៧]

បញ្ជាក់ផងដែរថា ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចប្ដឹងជំទាស់នឹងដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬមិនអនុញ្ញាតឱ្យលក់បាន។[១០៨]

❖ **ក្រោយពេលតុលាការចេញដីកាសម្រេចអនុញ្ញាតឱ្យលក់**

ក្នុងពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរហើយ តុលាការអនុវត្តនឹងចេញដីកាសម្រេច អំពីអំឡុងពេលសម្រាប់បង់ថ្លៃលក់ទៅឱ្យអ្នកទិញ ដើម្បីមកបង់ប្រាក់ឱ្យគ្រប់ចំនួន។ ពេលកំណត់ត្រូវស្ថិតនៅក្នុងរយៈពេល ១ ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ។

បន្ទាប់ពីអ្នកទិញបានធ្វើការបង់ថ្លៃលក់គ្រប់ចំនួន ហើយក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ញើផ្ដាក់ទៅដល់ស្ថាប័នដែលមានសមត្ថកិច្ចឱ្យចុះបញ្ជី និងលុបចោលការចុះបញ្ជីដូចខាងក្រោម៖

---

[១០៧] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៤២ កថាខណ្ឌ២

[១០៨] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៤៤៤

ក. ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ដែលអ្នកទិញបានធ្វើលទ្ធកម្ម

ខ. ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់

គ. ការលុប ការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលត្រូវបានបាត់បង់អានុភាពដោយការលក់

ឃ. ការលុប ការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន។

ក្នុងករណីបើសិនអ្នកទិញ មិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះនឹងបាត់បង់អនុភាពទៅវិញ។ ដូចនេះអ្នកទិញមិនអាចធ្វើការទាមទារឱ្យសងត្រឡប់នូវប្រាក់ ដែលខ្លួនបានដាក់ធានាទៅលើសំណើសុំទិញបានទេ។ តុលាការអនុវត្តនឹងធ្វើការអនុវត្តដោយបង្ខំសារជាថ្មី។

ក្រោយពីការចុះបញ្ជីរួចហើយ ស្ថាប័នជំនាញត្រូវធ្វើការប្រគល់ឯកសារត្រឡប់មកតុលាការវិញ ដើម្បីឱ្យតុលាការប្រគល់ឱ្យអ្នកទិញ។ ដោយតុលាការត្រូវធ្វើការប្រគល់នូវច្បាប់ដើមទៅឱ្យអ្នកទិញ និងតម្កល់ឯកសារថតចម្លងនៅក្នុងសំណុំរឿង។

**២.៣.៥. នីតិវិធីចែកចំណែក**

តុលាការអនុវត្ត ត្រូវចេញដីកាសម្រេចដើម្បីកំណត់កាលបរិច្ឆេទចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និងទីកន្លែងទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និងកូនបំណុល។

នៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការត្រូវកោះហៅម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្ត។ ពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែក តុលាការអាចសួរម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្ត ដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារ ដែលអាចធ្វើការពិនិត្យភ្លាមៗបាននៅកាលបរិច្ឆេទនៃការចែកចំណែក។

នៅលើតារាងចែកចំណែក ទន្ទឹមគ្នានឹងចំនួនទឹកប្រាក់ដែលបានមកពីការលក់ តុលាការត្រូវសរសេរអំពីចំនួនប្រាក់ដើម ការប្រាក់សិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងៗ នៃសិទ្ធិលើបំណុល សោហ៊ុយសម្រាប់ការអនុវត្ត និងលំដាប់ ព្រមទាំងចំនួនទឹកប្រាក់នៃការចែកចំណែក។

លំដាប់ និងចំនួនទឹកប្រាក់នៃការចែកចំណែក ដែលត្រូវបានកំណត់ខាងលើនេះ ត្រូវសរសេរតាមការព្រមព្រៀង ក្នុងករណី ដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូបនៅកាលបរិច្ឆេទនៃការចែកចំណែក។ ឯក្នុងករណីផ្សេងទៀត ត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត។

### ២.៣.៦.ការដាក់ប្រាតិភោគ និងការផ្ញើ

នៅក្នុងករណីខ្លះ ការដាក់ប្រាតិភោគដោយកូនបំណុលនៃការអនុវត្ត គឺជាល័ក្ខខ័ណ្ឌសម្រាប់ការផ្អាក ឬការលុបចោលការអនុវត្តដោយបង្ខំ។[១០៩] នៅក្នុងករណីខ្លះទៀត ការដាក់ប្រាតិភោគដោយម្ចាស់បំណុលនៃការអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារ សម្រាប់ការចាប់ផ្ដើមការអនុវត្តដោយបង្ខំ។ ប្រាតិភោគនៅទីនេះ ត្រូវដាក់ដោយភាគីទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬតុលាការអនុវត្តតាមវិធីផ្ញើប្រាក់ ឬឧបករណ៍អាច ជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ។

ចំពោះនីតិវិធីនៃការផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបាន ទៅតុលាការដែលជាវិធីដាក់ប្រាតិភោគត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការផ្ញើតាមផ្លូវតុលាការ។ (នៅក្នុងជំពូកទី១ បទប្បញ្ញត្តិទូទៅ នៃការប្រកាសមានការចែងថាកិច្ចការទាក់ទងទៅនឹងការផ្ញើត្រូវបំពេញដោយក្រឡាបញ្ជី ដែលត្រូវចាត់តាំងដោយប្រធានតុលាការដែលត្រូវទទួលការផ្ញើនេះ។ ក្នុងជំពូកនេះ ក៏មានចែងអំពីពេលដែលការចាត់ចែងរបស់ក្រឡាបញ្ជីពាក់ព័ន្ធទៅនឹងការផ្ញើ ការបង្កើតអានុភាព ព្រមទាំងវិធីឧបាស្រ័យ សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្ដឹងផងដែរ។ ក្រៅពីនេះក៏មានការចែង អំពីនីតិវិធីនៃការផ្ញើវត្ថុដែលជាកម្មវត្ថុនៃការផ្ញើនៅក្នុងជំពូកទី២ និងនីតិវិធីនៃការប្រគល់នូវវត្ថុផ្ញើនៅក្នុងជំពូកទី៣ ផងដែរ)។

### ២.៣.៧. សោហ៊ុយសម្រាប់ការអនុវត្ត

សោហ៊ុយសម្រាប់ការអនុវត្ត មានន័យថាជាការចំណាយរបស់ស្ថាប័នអនុវត្ត និងភាគី ដែលជាសេចក្តីត្រូវការដើម្បីធ្វើការអនុវត្តដោយបង្ខំ។ ការចំណាយនេះខុសគ្នាពីប្រាក់ប្រដាប់ក្តីក្នុងន័យចង្អៀត ពោលគឺការចំណាយលើនីតិវិធីបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬសាលដីកាដែលជាលិខិតអនុវត្តចំពោះខ្លឹមសារ អ្នកទទួលបន្ទុកវិធីប្រមូលជាដើម។ សូមកត់សម្គាល់ថា ចំណាយលើការបញ្ជូនលិខិតអនុវត្ត ជាអាទិ៍ ដែលជាការត្រៀមរៀបចំការចាប់ផ្តើមការអនុវត្តដោយបង្ខំ គឺជាសោហ៊ុយសម្រាប់ការអនុវត្ត។[១១០] ការចំណាយចាំបាច់សម្រាប់ធ្វើការអនុវត្តដោយបង្ខំរួមមាន ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ។[១១១] ចំណាយដែលស្ថាប័នអនុវត្តត្រូវបង់ដូចជា ថ្លៃសម្រាប់ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ចំណាយសម្រាប់ការជូនដំណឹង និងការប្រកាសជាសាធារណៈ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងប្រាក់កម្រៃសម្រាប់អ្នកវាយតម្លៃអចលនវត្ថុជាអាទិ៍ ក៏ដូចជាថ្លៃធ្វើឯកសារនានារបស់ភាគី និងចំណាយសម្រាប់អ្នកសង្កេតការណ៍ចំពោះការអនុវត្ត។ ចំពោះការចំណាយ

---

[១០៩] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៤៣ កថាខណ្ឌ២ ចំណុច ខ មាត្រា៣៦៦ កថាខណ្ឌ១-២ មាត្រា៣៦៧ កថាខណ្ឌ១-២ មាត្រា៣៦៨-មាត្រា៣៦៩

[១១០] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៧៣

[១១១] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៧២

លើការតវ៉ាបណ្ដឹងជំទាស់ បណ្ដឹងផ្សេងជាអាទិ៍ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តដោយបង្ខំវិញ ចំណែកនៃការចំណាយទាំងនេះ ត្រូវកំណត់ដោយសាលក្រម ឬដីកាសម្រេចចុងក្រោយថាជាចំណាយសម្រាប់នីតិវិធីឯករាជ្យ។ ហេតុនេះហើយចំណាយទាំងនេះ មិនត្រូវបានរាប់ជាសោហ៊ុយសម្រាប់ការអនុវត្តទេ។

ការបង់សោហ៊ុយ ការទទួលបន្ទុក និងការប្រមូល គឺម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយសម្រាប់ការអនុវត្តជាមុន ពោលគឺត្រូវបង់ជាមុននូវចំណាយដែលត្រូវចាយដោយស្ថាប័នអនុវត្ត។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តមិនបង់សោហ៊ុយជាមុនទេ នោះមិនអាចសុំឱ្យធ្វើការអនុវត្តដោយបង្ខំបានឡើយ។ [១១២] ក៏ប៉ុន្តែចំណាយដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ឱ្យតែវាជាចំណាយចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំនៅទីបញ្ចប់នឹងក្លាយជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត។ [១១៣] ហេតុនេះហើយ ម្ចាស់បំណុលនៃការអនុវត្តនឹងទទួលបានសំណងត្រឹមកម្រិតនៃចំណាយចាំបាច់នោះវិញ។

ការសងវិញនូវប្រាក់ចំណាយ ដែលបានប្រមូលក្នុងករណីដែលសាលក្រមជាអាទិ៍ ដែលជាលិខិតអនុវត្តត្រូវបានលុបចោល ឬបដិសេធចោល ម្ចាស់បំណុលនៃការអនុវត្តត្រូវសងទៅកូនបំណុលនៃការអនុវត្តវិញនូវសោហ៊ុយដែលបានប្រមូលរួចហើយ ដោយផ្អែកលើសេចក្ដីសម្រេចនោះ។ **ឧទាហរណ៍** ដូចជាករណីដែលសាលក្រមដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នត្រូវបានលុបចោល ដោយការជំនុំជម្រះលើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងករណីដែលសាលក្រមស្ថាពរ ត្រូវបានលុបចោលដោយការជំនុំជម្រះសាជាថ្មី ដោយសារការដកចេញនូវការអនុវត្តដោយបង្ខំតាមរយៈបណ្ដឹងតវ៉ាចំពោះការទាមទារមិនមែនជាការលុបចោលដោយប្រតិសកម្ម នូវលិខិតអនុវត្តទេ នោះការណ៍នេះមិនស្ថិតនៅក្នុងករណីដូចបានរៀបរាប់ខាងលើឡើយ។ សោហ៊ុយសម្រាប់ការអនុវត្ត ដែលត្រូវសងវិញ រួមមានការចំណាយដែលកូនបំណុលនៃការអនុវត្តបានបង់។ **ឧទាហរណ៍** ការចំណាយលើអ្នកសង្កេតការណ៍ ការចំណាយលើការដាក់ពាក្យសុំឱ្យផ្អាកលើការអនុវត្តដោយបង្ខំជាអាទិ៍។ ចំពោះវិធីនៃការទាមទារឱ្យសងវិញ កូនបំណុលនៃការអនុវត្ត អាចទាមទារឱ្យក្រឡាបញ្ជីនៃតុលាការអនុវត្តនៃសាលាដំបូង ដែលអាជ្ញាសាលាស្ថិតនៅធ្វើការកំណត់ជាស្ថាពរនូវចំនួនទឹកប្រាក់នៃសោហ៊ុយនោះ ដោយផ្អែកលើសេចក្ដីសម្រេចលុបចោលលិខិតអនុវត្ត។

## ២.៤. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ

### ២.៤.១. ការផ្អាកការអនុវត្តដោយបង្ខំ

ការផ្អាកការអនុវត្តដោយបង្ខំសំដៅទៅលើស្ថានភាពដែលស្ថាប័នអនុវត្តមិនអាចចាប់ផ្ដើម ឬបន្តការអនុវត្តដោយបង្ខំទៅតាមច្បាប់បាន ហើយទំហំនៃអានុភាពក្នុងការផ្អាក ប្រែប្រួលទៅតាមមូលហេតុ ដែលបានកំណត់

[១១២] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៧៥

[១១៣] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៧៦ កថាខណ្ឌ១

ដូចខាងក្រោម៖

១. ឯកសារចម្លងយថាភូត នៃសេចក្ដីសម្រេច ដែលកំណត់ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។[១១៤]

២. ឯកសារដែលសរសេរថា ម្ចាស់បំណុលបានទទួលសំណង ឬបានយល់ព្រមពន្យារពេលត្រូវសង នៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។

សំណង ឬការពន្យារពេលត្រូវសងនេះគួរតែត្រូវបានអះអាងដោយបណ្ដឹងតវ៉ាចំពោះការទាមទារចំពោះតែឯកសារដែលបានកំណត់នៅក្នុងចំណុចនេះមានអានុភាពផ្អាកការអនុវត្តដោយខ្លួនឯង។ ប៉ុន្តែអានុភាពផ្អាកការអនុវត្តនេះតាមការពិតមានលក្ខណៈជាបណ្ដោះអាសន្នដោយសារអានុភាពនេះ បើមានរហូតដល់ពេលមានបណ្ដឹងតវ៉ាចំពោះការទាមទារជាការគ្រប់គ្រាន់ ហើយក្នុងករណីពន្យារពេលត្រូវសងត្រូវទទួលស្គាល់លទ្ធភាពក្នុងការអនុវត្តបន្តទៀត ហេតុនេះហើយបានជាចំណុចទី២ ខាងលើនេះកម្រិតអានុភាពផ្អាកត្រឹមតែ ២ខែតែប៉ុណ្ណោះ។ ចំពោះការសងក៏ដោយ ឬការពន្យារពេលក៏ដោយ ការផ្អាកការអនុវត្តតាមចំណុចទី២ នេះត្រូវបានអនុញ្ញាតតែម្ដង។ ទោះបីការពន្យារពេលត្រូវសងលើសពី ២ខែក៏ដោយ ការអនុវត្តដោយបង្ខំត្រូវផ្អាក ២ខែដែរ ក្នុងករណីដែលភាគីចង់ទាមទារឱ្យផ្អាកការអនុវត្តដោយបង្ខំ ក្នុងអំឡុងពេលវែងជាង ២ខែ ដោយយកការសង ការពន្យារពេល ត្រូវសងមកធ្វើជាមូលហេតុ ភាគីនោះចំបាច់ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ហើយទទួលដីកាសម្រេចផ្អាកការអនុវត្តតាមមាត្រា៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ២.៤.២. ការលុបចោលការអនុវត្តដោយបង្ខំ

ការលុបចោលដោយបង្ខំមានន័យថា គឺជាការជម្រះចេញនូវការចាត់ចែងនៃការអនុវត្តទាំងមូល ឬមួយផ្នែកដែលបានធ្វើរួចហើយ ដោយស្ថាប័នអនុវត្តនៅក្នុងដំណើរនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ។

❖ **មូលហេតុនៃការលុបចោលការអនុវត្តដោយបង្ខំ**

១. លិខិតដែលមានកំណត់ក្នុងចំណុច **១.១.២.៤.លិខិតអនុវត្ត(ជំពូកទី១)** ឬឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថាលុបចោលការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន។

២. ឯកសារចម្លងយថាភូតនៃសេចក្ដីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។

៣. អនុសាលក្រមស្ថាពរ ឬអនុសាលដីកាស្ថាពរ ដែលប្រកាសថាការផ្សះផ្សារ ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុអនុវត្តគ្មានអនុភាព។

៤. ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀតដែលក្រឡាបញ្ជីបានធ្វើដែលបញ្ជាក់

[១១៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៣៧០ កថាខណ្ឌ២ ចំណុចក

៥. ថាលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុច **១.១.២.៤.លិខិតអនុវត្ត(ជំពូកទី១)** បាត់បង់អានុភាព ដោយសារការដកពាក្យបណ្តឹង ឬមូលហេតុផ្សេងទៀត។

៦. ឯកសារចម្លងយថាភូតនៃកំណត់ហេតុ អំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលកំណត់ថាមិនអនុវត្តដោយបង្ខំ ឬការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

៧. ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ។

៨. ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងលុបចោលការចាត់ចែងការអនុវត្ត។

**២.៥. ទំនាក់ទំនងនៃការរក្សាការពារ និងការអនុវត្តដោយបង្ខំ**

ភាពចាំបាច់នៃការរក្សាការពារនៅក្នុងការរឹបអូសជាបណ្តោះអាសន្ន និងទទួលស្គាល់នៅពេល ដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនៅពេលដែលមានការបារម្ភថានឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។[១១៥]

ការរក្សាការពារ ត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬនឹងមានតែទ្រព្យសម្បត្តិ ដែលពិបាកប្តូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះ ដែលនៅសល់ដោយសារ ការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ជាអាទិ៍។ ការរក្សាការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្តូរលំនៅឋានជាច្រើនលើកច្រើនសារ ហើយបើការណ៍នោះត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ ការកំណត់នេះមិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។ ក៏ប៉ុន្តែដោយសារថា គោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន មិនមែនដើម្បីទទួលបានការសម្រេចសិទ្ធិដែលពេញលេញជាងពេលបច្ចុប្បន្នទេនោះ អសាធនភាពនាពេលបច្ចុប្បន្នរបស់កូនបំណុលតែឯកឯង មិនអាចធ្វើឱ្យការរក្សាការពារមានភាពចាំបាច់ទេ។ ដោយឡែកប្រសិនបើសាធនភាពរបស់កូនបំណុលមានភាពគ្រប់គ្រាន់ ហើយទំនងនឹងអាចសម្រេចសិទ្ធិទាមទារបាន ដោយងាយស្រួល នោះភាពចាំបាច់នៃការរក្សាការពារនឹងត្រូវបានបដិសេធ។ ការបដិសេធរបស់កូនបំណុល ចំពោះសិទ្ធិ ដែលត្រូវបានរក្សាការពារ ឬឥរិយាបថរបស់កូនបំណុលក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចចំពោះសិទ្ធិនោះ ពុំមែនជាមូលហេតុនៃការបញ្ជាក់អំពីភាពចាំបាច់នៃការរក្សាការពារទេ ព្រោះសកម្មភាពទាំងនោះមិនមែនជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំឡើយ។ ត្រង់ចំណុចនេះ ចរិតលក្ខណៈភាពចាំបាច់ក្នុងការរក្សាការពារ គឺខុសគ្នាពី

[១១៥] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៥៤៥ កថាខណ្ឌ១

ភាពចាំបាច់ដែលតម្រូវឱ្យធ្វើការទាមទារជាមុន ដែលជាល័ក្ខខ័ណ្ឌសម្រាប់ធ្វើបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត។[១១៦]

### ២.៥.១. ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ

ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ គឺជានីតិវិធីផ្សេងគ្នា តែទំនាក់ទំនងមាននៅត្រង់ថាដើម្បីអាចអនុវត្តដោយបង្ខំបាន ត្រូវរឹបអូសជាបណ្ដោះអាសន្នទុកជាមុន។

នៅពេលដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុត្រូវបានចេញ ការរក្សាការពារនឹងត្រូវបានអនុវត្ត។ ការអនុវត្តរក្សាការពារ គឺជាការអនុវត្តដើម្បីសម្រេចនូវគោលដៅនៃដីកាសម្រេចរក្សាកាពារ។

ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តចំពោះអចលនវត្ថុ គឺជានីតិវិធីដែលធ្វើបន្តបន្ទាប់គ្នា។ ហេតុដូច្នេះហើយ ការប្ដូរពីការរឹបអូសជាបណ្ដោះអាសន្នទៅការអនុវត្តដោយបង្ខំនោះត្រូវបានទទួលស្គាល់។ នៅក្នុងការងារអនុវត្តជាក់ស្ដែងហៅថា ការប្ដូរទៅការអនុវត្តពិតប្រាកដ។

### ២.៥.២. ការប្ដូរពីការរឹបអូសជាបណ្ដោះអាសន្នទៅជាការអនុវត្តពិតប្រាកដ

នៅក្រោយពេល ដែលការរឹបអូសជាបណ្ដោះអាសន្នត្រូវបានអនុវត្ត ប្រសិនបើគ្រប់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញហើយម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្ត នោះការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញ ត្រឹមទំហំនៃការអនុវត្តនោះ។ យ៉ាងណាក៏ដោយ ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលតម្រូវឱ្យមានការចុះបញ្ជីអំពីការរឹបអូសដាច់ដោយឡែកពីការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នោះត្រូវមានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ របស់តុលាការដែលមានសមត្ថកិច្ច។ ក្នុងករណីដែលម្ចាស់បំណុលមានការធ្វេសប្រហែសមិនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ បើទោះបីជាគ្រប់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំត្រូវបានបំពេញហើយក៏ដោយ នោះកូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយសារការផ្លាស់ប្ដូរស្ថានភាពបាន ដោយសំអាងទៅលើការរលត់នៃភាពចាំបាច់ នៃការរឹបអូសជាបណ្ដោះអាសន្ន។

[១១៦] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៦, មាត្រា៥៧៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ចំពោះ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីមួយដ៏ស្មុគស្មាញ ចំពោះការអនុវត្តពីមួយដំណាក់កាល ទៅមួយដំណាក់កាល នៃលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះ អលចនវត្ថុនេះក៏ពិតមែន ក៏ប៉ុន្តែវាគឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីធានាទៅដល់ការការពារផលប្រយោជន៍ របស់ម្ចាស់បំណុលនៃការអនុវត្ត ក្នុងការសម្រេចឱ្យបាននូវសិទ្ធិទាមទាររបស់ខ្លួន តាមរយៈតុលាការអនុវត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្ត ដោយធ្វើការរឹបអូសអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីធ្វើការលក់ដោយបង្ខំ តាមវិធីលក់ឡាយឡុងតាមស្រោមសំបុត្រ ឬលក់ឡាយឡុងដោយផ្ទាល់មាត់ បន្ទាប់មកត្រូវប្រមូលយកប្រាក់ ដែលបានមកពីការលក់ដោយបង្ខំនោះលើអចលនវត្ថុរបស់កូនបំណុលនៃការ អនុវត្តនោះ យកទៅធ្វើការបែងចែកចំណែកឱ្យទៅម្ចាស់បំណុលដែលមានសិទ្ធិទទួលបានចំណែកដើម្បីសម្រេច សិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តនោះ។

នីតិវីធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីមួយដែលមានលក្ខណៈឯករាជ ក៏ដូចជាមាន លក្ខណៈស្មុគស្មាញផងដែរ ដែលទាមទារឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅជាងនីតិវិធីនានា។ ចំពោះតុលាការ អនុវត្តក៏ត្រូវធ្វើការពិនិត្យអំពីលក្ខខ័ណ្ឌឱ្យបានហ្មត់ចត់មុននឹងធ្វើការចាប់ផ្តើម នីតិវិធីនៃការអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុ ឬក៏មុនសម្រេចដំណើរការនីតិវិធីបន្តបន្ទាប់ទៀត ដែលមានលំហូរនីតិវិធីវែងឆ្ងាយ និងមាន រយៈពេលយូរផងដែរ។ បន្ថែមពីនេះនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុទាមទារឱ្យតុលាការមាន ភាពច្បាស់លាស់ជៀសវៀងការអនុវត្តខុសនីតិវិធី និងធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិព្រមទាំងផលប្រយោជន៍របស់ ភាគីនៃការអនុវត្ត ឬតតិយជនផ្សេងទៀត។

សរុបសេចក្តីមក ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីមួយដែលជាប្រភេទនៃការអនុវត្ត ដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់ គឺជានីតិវិធីមួយដែលជួយសម្រេចនូវសិទ្ធិចុងក្រោយបង្អស់ របស់ម្ចាស់បំណុលឱ្យទទួលបាន ការសងត្រឡប់មកវិញនូវសិទ្ធិលើបំណុលរបស់ខ្លួន ជៀសឆ្ងាយពីការប្រើប្រាស់ អំពើហិង្សា ឬការប្រព្រឹត្តនូវសកម្មភាពណាមួយ ដែលផ្ទុយអំពីច្បាប់ ដើម្បីធ្វើការទាមទារនូវសិទ្ធិលើបំណុលរបស់ ខ្លួន។

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែកលើការសិក្សាស្រាវជ្រាវអស់រយៈពេលកន្លងមក ដែលទាក់ទងនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពិតជាមានសារៈសំខាន់ណាស់ចំពោះការសិក្សា និងការអនុវត្តផ្ទាល់នៅក្នុងសង្គម។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុបច្ចុប្បន្ន មានករណីជាច្រើនបានកើតឡើងចំពោះប្រជាជនគ្រប់ស្រទាប់វណ្ណៈមានទាំងគុណសម្បត្តិ និងគុណវិបត្តិ ហើយក៏មានទាំងបញ្ហាប្រឈមចំពោះសង្គមជាតិផងដែរ។ ដូចនេះខ្ញុំបាទ និងនាងខ្ញុំសូមមានជាមតិសំណូមពរមួយចំនួន ដើម្បីការពារនូវបញ្ហាប្រឈមដែលនឹងអាចកើតឡើង ក្នុងការអនុវត្តផ្ទាល់ដែលអាចមានកំហុសណាមួយកើតឡើងជាយថាហេតុ៖

- សូមតុលាការ ឬស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចគួរតែត្រួតពិនិត្យឱ្យច្បាស់លាស់ក្នុងការអនុវត្តផ្ទាល់រាល់ការសម្រេចចេញនូវដីកាអនុវត្តដោយបង្ខំលើអចលនវត្ថុ ជៀសវៀងភាពខុសឆ្គងលើទិដ្ឋភាពច្បាប់ និងទិដ្ឋភាពជាក់ស្តែង។
- ស្នើសុំដល់ស្ថាប័នមានសមត្ថកិច្ចពន្លឿនការចុះបញ្ជីដីធ្លីជាប្រព័ន្ធឱ្យបានលឿន ក្រៅពីទំនាស់ជំពាក់ប្រាក់ ដែលត្រូវសងជាប្រាក់មានទំនាស់ជាច្រើនដែលកើតឡើង ដោយសារការកំណត់ព្រំប្រទល់ដីមិនបានច្បាស់លាស់។ ដូច្នេះការចុះបញ្ជីដីធ្លីពិតជាមានសារៈសំខាន់ដើម្បីបង្ការទំនាស់កើតឡើង។
- ពង្រឹងសមត្ថភាព និងការបណ្តុះសីលធម៌មន្ត្រីអនុវត្តច្បាប់ គ្រប់មន្ត្រីអនុវត្តដែលមានសមត្ថកិច្ចទាំងអស់ត្រូវការពង្រឹងសមត្ថភាព គឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីធានាថាមន្ត្រីនីមួយៗយល់ដឹងអំពីនីតិវិធី និងតួនាទីរបស់ខ្លួនផ្តល់កិច្ចសហការហើយចូលរួមអនុវត្តច្បាប់ និងសេចក្តីសម្រេចរបស់តុលាការឱ្យមានប្រសិទ្ធភាពខ្ពស់ និងធ្វើឱ្យប្រជាពលរដ្ឋមានភាពទុកចិត្តខ្ពស់ថាមន្ត្រីអ្នកអនុវត្តច្បាប់ពិតជាមានសមត្ថភាពអាចរកយុត្តិធម៌ឱ្យខ្លួនបាន។ កាលណាមន្ត្រីទាំងអស់បំពេញការងាររបស់ខ្លួនប្រកបដោយសមត្ថភាព និងសីលធម៌ខ្ពស់វាស្តែងឱ្យឃើញពីប្រសិទ្ធភាពការងារ និងជំនឿទុកចិត្តពីប្រជាពលរដ្ឋចំពោះស្ថាប័នតុលាការ ដែលនាំមកនូវកិត្យានុភាពនៃស្ថាប័នរដ្ឋ និងសុខដុមរមនានៃពលរដ្ឋក្នុងសង្គមទាំងមូលផងដែរ។ ហេតុដូចនេះហើយ ក្នុងនាមខ្ញុំបាទ និងនាងខ្ញុំជានិស្សិតច្បាប់ក៏ដូចជាប្រជាពលរដ្ឋផ្សេងៗឯទៀត តែងតែចង់បានស្ថាប័នមានសមត្ថកិច្ចមួយដែលអាចជាទីទុកចិត្តក្នុងការស្វែងរកយុត្តិធម៌ពិតប្រាកដជូនដល់ប្រជាពលរដ្ឋទាំងអស់ ដោយស្មើភាពគ្នា។
- បង្កើនការផ្សព្វផ្សាយអប់រំច្បាប់ ការយល់ដឹងផ្នែកច្បាប់ គឺជារឿងសំខាន់ណាស់ពីព្រោះ កាលណាប្រជាពលរដ្ឋបានយល់ដឹកផ្នែកច្បាប់ ពួកគាត់នឹងអាចគេចផុតពីការបោកប្រាស់ពីសំណាក់ជន

ខិលខូចមួយចំនួន និងអាចកាត់បន្ថយបញ្ហាដែលអាចនឹងកើតមានឡើងនៅក្នុងសង្គម ព្រោះថាកាលណាប្រជាពលរដ្ឋមានចំណេះដឹងអំពីច្បាប់ ពួកគាត់នឹងមានសមត្ថភាពអាចវែកញែកបានថាសកម្មភាពណាខ្លះដែលស្របច្បាប់ និងសកម្មភាពណាដែលផ្ទុយនឹងច្បាប់។ ដូចនេះហើយ ខ្ញុំបាទ និងនាងខ្ញុំ សូមសំណូមពរដល់ស្ថាប័នដែលមានជំនាញវិជ្ជាជីវៈផ្នែកច្បាប់ និងបុគ្គលដែលមានជំនាញត្រូវតែផ្សព្វផ្សាយ និងចែករំលែកចំណេះដឹកផ្នែកច្បាប់នេះ ទៅឱ្យប្រជាពលរដ្ឋក្នុងសង្គមបានយល់ដើម្បីភាពរីកចម្រើន។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- សេចក្តីព្រាងច្បាប់លើកទី៣ ស្តីពីអាជ្ញាសាលា (កែសម្រួលដោយក្រុមប្រឹក្សាអ្នកច្បាប់ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ) ឆ្នាំ២០១២។
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ភាគ១ និងភាគ២, បោះពុម្ពនៅឆ្នាំ២០០៨។

## ❖ សៀវភៅនិងនិពន្ធ

- សៀវភៅ ស្តីពីនីតិវិធីនៃការអនុវត្តដោយបង្ខំ ការលក់ដោយបង្ខំចំពោះអចលនវត្ថុ សរសេរដោយលោក ម៉ុង មុនីសោភា ឆ្នាំ២០១២
- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។
- សន្ទានុក្រមពាក្យច្បាប់ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី របស់ទីស្តីការគណរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធគតិយុត្ត**

**ឧបសម្ព័ន្ធទី១៖** ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី២៖** ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី៣៖** រូបមន្តអនុវត្ត

**២. ឧបសម្ព័ន្ធរូបភាព**

**ឧបសម្ព័ន្ធទី១៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាលក់ឡាយឡុងតាមតុលាការ

**ឧបសម្ព័ន្ធទី២៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាអនុវត្តដីកាបង្គាប់ឱ្យស្រាវជ្រាវស្ថានភាពអចលនវត្ថុ

**ឧបសម្ព័ន្ធទី៣៖** ការអនុវត្តភារកិច្ចអាជ្ញាសាលាឱ្យប្រគល់អចលនវត្ថុ

# ឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី

ឆ្នាំ ២០០៧

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

# គន្ថីទី ៣
# សិទ្ធិប្រត្យក្ស
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ
### ផ្នែកទី ១
### វត្ថុ

**មាត្រា ១១៩.–** និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

**មាត្រា ១២០.–** ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

**មាត្រា ១២១.–** សមាសភាគនៃវត្ថុ

ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

**មាត្រា ១២២.-** សមាសភាគនៃដី : គោលការណ៍

វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬ ពូជដែលសាបនៅលើដី ដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង ។

**មាត្រា ១២៣.-** សមាសភាគនៃដី : ករណីលើកលែង

អាគារ ឬ សំណង់ផ្សេងទៀតដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិចំពោះដីរបស់អ្នកដទៃ មិនត្រូវក្លាយជាសមាសភាគនៃដីឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះវត្ថុដែលត្រូវបានភ្ជាប់ជាមួយនឹងដី ដោយមានគោលបំណងជាបណ្តោះអាសន្ន ។

**មាត្រា ១២៤.-** អាគារ ជាអាទិ៍ ដែលត្រូវបានសង់ដោយផ្អែកលើសិទ្ធិលើដីរបស់អ្នកដទៃ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៣ (សមាសភាគនៃដី : ករណីលើកលែង) នៃក្រមនេះ អាគារ ឬ សំណង់ផ្សេងទៀត ដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ត្រូវបានចាត់ទុកថាជាសមាសភាគនៃសិទ្ធិលើដីរបស់អ្នកដទៃ ។

**មាត្រា ១២៥.-** សមាសភាគនៃអាគារ

ចំពោះវត្ថុធាតុដែលជាសមាសភាគនៃអាគារ គ្រឿងអាគារ គ្រឿងសង្ហារិម ផ្ទាំងវត្ថុតុបតែង ជាអាទិ៍ ដែលមិនអាចបែងចែកបាន ដោយមិនបំបែកអាគារនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុនោះគឺជាសមាសភាគនៃអាគារ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

ថ្មែនោះ ត្រូវធ្លាក់ទៅម្ចាស់នៃវត្ថុធាតុដើម ។

២-ក្នុងករណីអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក មានតែករណីដែលតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ លើសពីតម្លៃវត្ថុធាតុដើមនៃអ្នកដទៃទេ ទើបអ្នកកែច្នៃត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។

**មាត្រា ២០០.-** អានុភាពនៃឧបាគមន៍នៃចលនវត្ថុ

១-ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា ឬ ការកែច្នៃ សិទ្ធិដែលមាននៅលើវត្ថុនោះ ក៏ត្រូវរលត់ដែរ ។

២-សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុជាប់គ្នា វត្ថុលាយច្របល់គ្នា ឬ វត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើលទ្ធកម្មជាថ្មីនេះទៀត ។ ក្នុងករណីនេះ ប្រសិនបើក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគ សិទ្ធិនោះត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគនោះ ។

**មាត្រា ២០១.-** ឧបាគមន៍ និង សិទ្ធិទាមទារប្រាក់សំណង

ជនដែលបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា ឬ ការកែច្នៃនៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះអ្នកដែលបានធ្វើលទ្ធកម្មសិទ្ធិ និង ទទួលផលប្រយោជន៍បាន តាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

## ផ្នែកទី ៥
## កម្មសិទ្ធិអវិភាគ

**មាត្រា ២០២.-** និយមន័យនៃកម្មសិទ្ធិអវិភាគ

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ។

**មាត្រា ២០៣.-** សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានបង់សោហ៊ុយដើម្បីការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតដែលលើសពីបន្ទុករបស់ខ្លួន ម្ចាស់កម្មសិទ្ធិអវិភាគនោះអាចទាមទារឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតសងប្រាក់ដែលខ្លួនបានបង់លើសនោះ តាមសមាមាត្រនៃចំណែករៀងៗខ្លួនបាន ។

៣-សិទ្ធិទាមទារសងសោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក៏អាចអនុវត្តបានដែរ ចំពោះជនដែលបានទទួលបន្តនូវចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

**មាត្រា ២១០.-** ការបោះបង់សិទ្ធិនៃចំណែក ជាអាទិ៍

ពេលដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ បានបោះបង់នូវចំណែករបស់ខ្លួន ឬ បានទទួលមរណភាពហើយគ្មានសន្តតិជនទេនោះ ចំណែករបស់អ្នកនោះនឹងត្រូវបានទៅម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

**មាត្រា ២១១.-** សិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា ។ ប៉ុន្តែ ម្ចាស់កម្មសិទ្ធិអវិភាគអាចធ្វើកិច្ចសន្យាហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ បាន ។

២-កិច្ចសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបន្តបាន តែកិច្ចសន្យាដែលត្រូវបានធ្វើបន្តថ្មីនេះ មិនអាចមានអំឡុងពេលលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។

**មាត្រា ២១២.-** វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

ក្នុងករណីការពិភាក្សារបស់ម្ចាស់កម្មសិទ្ធិអវិភាគអំពីការបែងចែកមិនអាចសម្របសម្រួលគ្នាបានទេ ម្ចាស់កម្មសិទ្ធិអវិភាគ អាចទាមទារការបែងចែង ដោយប្តឹងទៅតុលាការបាន ។ ក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យបែងចែកវត្ថុ តាមរូបដើមរបស់វា ឬ ប្រសិនបើមានការបារម្ភថា ការបែងចែកតាមរូបដើមនឹងធ្វើឱ្យខូចតម្លៃហួសហេតុ ឬ ប្រសិនបើ

២-ភោគីដែលបានចាប់ផ្តើមកាន់កាប់អចលនវត្ថុនៅមុនពេលប្រកាសឱ្យប្រើច្បាប់ភូមិបាល ហើយបានទទួលការអនុញ្ញាតក្នុងការបន្តការកាន់កាប់ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិពីស្ថាប័នដែលមានសមត្ថកិច្ច អាចអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

៣-ក្នុងការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អំឡុងពេល ១ (មួយ) ឆ្នាំ ដែលបានកំណត់នៅក្នុងមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤០ (សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់) នៃក្រមនេះ ត្រូវបានបកស្រាយថា ៣ (បី) ឆ្នាំ ។

## ជំពូកទី ៤
## សិទ្ធិជួលអចិន្ត្រៃយ៍

**មាត្រា ២៤៤.-** និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុ រយៈពេលវែង ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤៥.-** ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបានបង្កើតឡើង ជាលាយលក្ខណ៍អក្សរ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ហើយអាចត្រូវបានបញ្ឈប់ ដោយភាគីម្ខាងនៅពេលណាក៏បាន ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) នៃក្រមនេះ ។

**មាត្រា ២៤៦.–** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍

១-អ្នកជួលអចិន្ត្រៃយ៍ មិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលបានចុះបញ្ជីហើយ អាចតតាំងនឹងអនុប្បទានិកនៃកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

៣-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ដែលមិនបានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៥៩៨ (ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ) នៃក្រមនេះ ត្រូវយកមកអនុវត្ត រហូតដល់គ្រប់អំឡុងពេល ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២៤៧.–** អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព

១-អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព មិនអាចឱ្យលើសពី ៥០ (ហាសិប) ឆ្នាំ បានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ (ហាសិប) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប) ឆ្នាំ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះមិនអាចលើសពី ៥០ (ហាសិប) ឆ្នាំ ឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី ។

**មាត្រា ២៤៨.–** ថ្លៃឈ្នួល

១-អ្នកជួលអចិន្ត្រៃយ៍មានករណីយកិច្ចបង់ថ្លៃឈ្នួល ចំពោះអ្នកឱ្យជួលអចិន្ត្រៃយ៍នៅពេលដែលបានកំណត់ ។

២-ប្រសិនបើពុំមានកំណត់ពេលបង់ថ្លៃឈ្នួលទេ អ្នកជួលអចិន្ត្រៃយ៍ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយរដូវនោះដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ២៤៩.-** សិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល

ភាគីទាំងសងខាងនៃសិទ្ធិជួលអចិន្ត្រៃយ៍ អាចទាមទារទៅតុលាការ ឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ទៅតម្លៃសមរម្យបាន ក្នុងករណីដែលថ្លៃឈ្នួលនោះក្លាយជាតម្លៃមិនសមរម្យដោយសារស្ថានភាពផ្សេងៗ ។

**មាត្រា ២៥០.-** សិទ្ធិរំលាយរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍

ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍មិនបានបង់ថ្លៃឈ្នួលដែលបានកំណត់ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ អ្នកឱ្យជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

**មាត្រា ២៥១.-** សិទ្ធិរំលាយរបស់អ្នកជួលអចិន្ត្រៃយ៍

ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍មិនបានទទួលចំណេញសោះពីអចលនវត្ថុ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ ដោយសារស្ថានភាពដែលមិនអាចព្យាករទុកជាមុនបាន ឬ ដោយសារប្រធានសក្តិ ឬ ក្នុងករណីដែលប្រាក់ចំណេញប្រចាំឆ្នាំ ដែលនឹងបានមកពីអចលនវត្ថុនៅពេលអនាគត ពុំមានលទ្ធភាពអាចលើសថ្លៃឈ្នួលសម្រាប់មួយឆ្នាំបាន ដោយសារការខូចខាតផ្នែកណាមួយនៃអចលនវត្ថុនោះ អ្នកជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

**មាត្រា ២៥២.-** អនុប្បទាន ជាអាទិ៍ នូវសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍អាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

២-អ្នកជួលអចិន្ត្រៃយ៍ អាចយកវត្ថុជួលអចិន្ត្រៃយ៍នោះ ទៅជួលបន្តបាន ។

៣-សិទ្ធិជួលអចិន្ត្រៃយ៍អាចជាកម្មវត្ថុនៃសន្តតិកម្មបាន ។

**មាត្រា ២៥៣.-** សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់អ្នកជួលអចិន្ត្រៃយ៍

អ្នកជួលអចិន្ត្រៃយ៍ អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួល

អចិន្ត្រៃយ៍ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

**មាត្រា ២៥៤.-** ការបញ្ចប់ការជួលអចិន្ត្រៃយ៍

១-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ មិនអាចទាមទារឱ្យអ្នកជួលអចិន្ត្រៃយ៍ ធ្វើបដិទានបានឡើយ លើកលែងតែករណីដែលអ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ អាចទទួលកម្មសិទ្ធិលើការកែលំអ ឬ សំណង់ ជាអាទិ៍ ដែលអ្នកជួលអចិន្ត្រៃយ៍បានធ្វើចំពោះអចលនវត្ថុ ដោយគ្មានសងប្រាក់សំណងទៅអ្នកជួលអចិន្ត្រៃយ៍ ។

៣-ភាគីអាចធ្វើការសន្យាពិសេស ផ្សេងពីកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ការសន្យានោះ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

**មាត្រា ២៥៥.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីភតិសន្យា

បញ្ញត្តិស្តីពីភតិសន្យា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ចំពោះចំណុចដែលមិនបានកំណត់នៅក្នុងជំពូកទី ៤ (សិទ្ធិជួលអចិន្ត្រៃយ៍) នេះ ។

## ជំពូកទី ៥

## ផលុបភោគ

**មាត្រា ២៥៦.-** និយមន័យនៃផលុបភោគ

១-ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី ។

២-ផលុបភោគីមានសិទ្ធិប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាមវិធីប្រើប្រាស់ និង មានសិទ្ធិអាស្រ័យផលធម្មជាតិ និង ផលស៊ីវិលដែលកើតចេញពីអចលនវត្ថុនោះ ។

**មាត្រា ២៥៧.–** ផលុបភោគដែលកំណត់ដោយការព្រមព្រៀង និង ផលុបភោគដែលច្បាប់បានកំណត់

១-ផលុបភោគ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងភាគី ឬ ដោយបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃជំពូកទី ៥ (ផលុបភោគ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

៣-ផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ មានអាទិភាពជាងផលុបភោគដែលត្រូវបានបង្កើតដោយការព្រមព្រៀង លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

**មាត្រា ២៥៨.–** ការបង្កើតផលុបភោគ

១-ផលុបភោគអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ផលុបភោគដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់ មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ ផលុបភោគត្រូវរលត់ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់ :

ក-៣ (បី) ខែ ចំពោះអាគារ ។

ខ-១ (មួយ) ឆ្នាំ ចំពោះដី ។

៣-ចំពោះផលុបភោគដីដែលមានរដូវប្រមូលផល ការស្នើឱ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្តើមការងារកសិកម្ម សម្រាប់រដូវបន្ទាប់ពីរដូវមុន ។

**មាត្រា ២៥៩.–** ល័ក្ខខ័ណ្ឌតតាំងនៃផលុបភោគ

១-ផលុបភោគីមិនអាចយកផលុបភោគរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-ផលុបភោគដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទានិកនៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

**មាត្រា ២៦០.–** អំឡុងពេលដែលផលុបភោគមានអត្ថិភាព

១-ផលុបភោគអាចមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ ឬ រហូតដល់ពេលដែលហេតុណាមួយដែលបានកំណត់ កើតឡើង ។

២-ប្រសិនបើមិនបានកំណត់អំឡុងពេលដែលផលុបភោគមានអត្ថិភាពទេ ផលុបភោគនោះត្រូវចាត់ទុកថា មានអត្ថិភាព រហូតដល់ពេលផលុបភោគីទទួលមរណភាព ។

**មាត្រា ២៦១.–** សិទ្ធិអាស្រ័យផលធម្មជាតិ

១-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលបង្កើតផលុបភោគ ត្រូវបានទៅផលុបភោគី ។

២-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលផលុបភោគរលត់ ត្រូវបានទៅកម្មសិទ្ធិករនៃដី ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទំនាក់ទំនងនៃសេចក្តីចម្រើនដោយឥតហេតុ ចំពោះការងារពលកម្ម ជាអាទិ៍ ដើម្បីបង្កើតផលធម្មជាតិនោះ មិនត្រូវកើតឡើយ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលមានសិទ្ធិជួលដែលមានអានុភាពតតាំងលើដីដែលជាកម្មវត្ថុនៃផលុបភោគ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានឥទ្ធិពលដល់សិទ្ធិរបស់ភតិកៈនោះក្នុងការអាស្រ័យផលធម្មជាតិឡើយ ។

៥-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ចំពោះផលធម្មជាតិដែលខ្លួនបានថែទាំរហូតដល់ផលុបភោគរលត់ ភតិកៈដែលជួលដីពីផលុបភោគីមានសិទ្ធិអាស្រ័យផលធម្មជាតិ ។

**មាត្រា ២៦២.‒** សិទ្ធិអាស្រ័យផលស៊ីវិល

ផលស៊ីវិលត្រូវបានទៅផលុបភោគី តាមសមាមាត្រទៅនឹងអំឡុងពេលដែលផលុប-ភោគមានអត្ថិភាព ។

**មាត្រា ២៦៣.‒** អនុប្បទាន ជាអាទិ៍ នូវផលុបភោគ

ផលុបភោគីអាចធ្វើអនុប្បទាននូវផលុបភោគ ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

**មាត្រា ២៦៤.‒** ភតិសន្យានៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ

១-ផលុបភោគីអាចយកអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ធ្វើជាកម្មវត្ថុនៃភតិសន្យា ដោយកំណត់អំឡុងពេលដែលមិនឱ្យលើសពី ៣ (បី) ឆ្នាំ ។

២-អំឡុងពេលនៃភតិសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះអាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះ មិនអាចលើសពី ៣ (បី) ឆ្នាំ បានឡើយ ។

៣-បើផលុបភោគរលត់ ភតិសន្យាអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ មិនអាចតតាំងចំពោះកម្មសិទ្ធិករនៃអចលនវត្ថុបានឡើយ ។

**មាត្រា ២៦៥.‒** សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ផលុបភោគី

ផលុបភោគី អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានផលុបភោគ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

**មាត្រា ២៦៦.‒** ករណីយកិច្ចជូនដំណឹងរបស់ផលុបភោគី

១-បើមានតតិយជនអះអាងអំពីសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ

ផលុបភោគីត្រូវជូនដំណឹងអំពីហេតុនេះ ទៅកម្មសិទ្ធិករនៃអចលនវត្ថុនោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកម្មសិទ្ធិករដឹងអំពីហេតុនោះហើយ ។

២-ផលុបភោគីត្រូវទទួលករណីយកិច្ចសងសំណងនៃការខូចខាតដែលកើតឡើងចំពោះកម្មសិទ្ធិករ ដោយសារខ្លួនបានធ្វេសប្រហែសក្នុងការជូនដំណឹង ។

**មាត្រា ២៦៧.–** ការទាមទារឱ្យរំលត់ផលុបភោគ

១-ក្នុងករណីដែលផលុបភោគីបានធ្វើអំពើផ្ទុយនឹងខ្លឹមសារនៃផលុបភោគ ដូចជាករណីដែលបានបង្កឱ្យមានការខូចខាត ឬ ថែរក្សាមិនបានត្រឹមត្រូវ ជាអាទិ៍ នូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ កម្មសិទ្ធិករនៃអចលនវត្ថុនោះ អាចទាមទារទៅតុលាការឱ្យរំលត់ផលុបភោគបាន ។

២-ការទាមទារឱ្យរំលត់ផលុបភោគដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណង ការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលចំពោះផលុបភោគីឡើយ ។

**មាត្រា ២៦៨.–** ការរលត់ផលុបភោគដោយមរណភាពនៃផលុបភោគី ឬ ការបញ្ចប់អំឡុងពេល

ផលុបភោគត្រូវរលត់ នៅពេលដែលផលុបភោគីទទួលមរណភាព ឬ បញ្ចប់អំឡុងពេលដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតផលុបភោគ ។

**មាត្រា ២៦៩.–** អានុភាពនៃការរំលត់ផលុបភោគ

១-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធិករអចលនវត្ថុ មិនអាចទាមទារឱ្យផលុបភោគីធ្វើបដិទានបានឡើយ លើកលែងតែករណីដែលផលុបភោគីបានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធករអចលនវត្ថុ អាចទទួលកម្មសិទ្ធិលើការដែលបានកែលំអ ឬ សំណង់ ជាអាទិ៍ ដែលផលុបភោគីបានធ្វើចំពោះអចលនវត្ថុ

# គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកតែមួយ

### អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ចារល.០៧១២.៦២៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

៣-ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និង ឯកសារខាងក្រោមនេះ :

ក-ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និង ក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

ខ-ចំពោះដីដែលមិនបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។

**មាត្រា ៤១៨.-** តុលាការអនុវត្ត

ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ តុលាការដែលបានកំណត់ខាងក្រោមនេះ គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច :

ក-បើយកដី ឬ អាគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ ។

ខ-បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬ លើអាគារដែលបានចុះបញ្ជី ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬ ចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី ។

**មាត្រា ៤១៩.-** ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍

១-នៅពេលចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាប់ផ្តើមនេះ ។

២-ដីកាសម្រេចចាប់ផ្តើមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ។

៣-ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អាចប្តឹងជំទាស់បាន ។

**មាត្រា ៤២០.-** ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ជាអាទិ៍

១-បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់ ។

២-បើបានធ្វើការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើការផ្ទុកផ្តាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។

**មាត្រា ៤២១.-** អានុភាពនៃការរឹបអូស

១-អានុភាពនៃការរឹបអូសអចលនវត្ថុ មានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះនិងសិទ្ធិចំណុះនៃអចលនវត្ថុនោះ ។

២-អានុភាពនៃការរឹបអូស នឹងកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានបញ្ជូន ទៅកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែ បើការចុះបញ្ជីអំពីការរឹបអូស ត្រូវបានធ្វើនៅមុនពេលបញ្ជូនដីកាសម្រេចចាប់ផ្តើមនោះ អានុភាពនោះនឹងកើតឡើងនៅពេលបានចុះបញ្ជី ។

៣-ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុ តាមវិធីប្រើធម្មតាឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួលអចលនវត្ថុ ត្រូវបានរឹបអូស ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) និង ករណីដែលការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២៩ (ការចាត់ចែងការរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៤២២.-** ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ

១-ក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ

នៃការលក់ដោយបង្ខំ ។

**មាត្រា ៤២៨.–** ការផ្អកផ្អាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស

១-បើពាក្យសុំឱ្យលក់ដោយបង្ខំត្រូវបានដកចេញ ឬ បើអានុភាពនៃដីកាសម្រេចលុបចោលនីតិវិធីលក់ដោយបង្ខំ បានកើតឡើង ក្រឡាបញ្ជីត្រូវផ្អកផ្អាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចលុបការចុះបញ្ជីអំពីការរឹបអូស ដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះ ។

២-សោហ៊ុយចាំបាច់សម្រាប់ការផ្អកផ្អាក់ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដកពាក្យសុំចេញ ឬ ម្ចាស់បំណុលនៃការអនុវត្តដែលបានទទួលដីកាសម្រេចលុបចោលនោះ ។

**មាត្រា ៤២៩.–** ការចាត់ចែងការរក្សាការពារ

១-ប្រសិនបើកូនបំណុល ឬ អ្នកកាន់កាប់អចលនវត្ថុបានប្រព្រឹត្តអំពើដែលធ្វើឱ្យតម្លៃអចលនវត្ថុចុះថយគួរឱ្យកត់សំគាល់ ឬ ធ្វើឱ្យមានការលំបាកដល់ការលក់ ឬ ការប្រគល់អចលនវត្ថុ ឬ បើមានការបារម្ភថា អ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាការអនុវត្តអាចហាមឃាត់ជនដែលបានប្រព្រឹត្តអំពើទាំងនេះ ឬ ជនដែលត្រូវគេមានការបារម្ភថា នឹងប្រព្រឹត្តអំពើទាំងនេះ មិនឱ្យប្រព្រឹត្តអំពើនោះ ឬ បង្គាប់ឱ្យជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬ បង្គាប់ឱ្យជននោះលះបង់ការកាន់កាប់អចលនវត្ថុហើយឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុនោះបាន ដោយដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកទិញ ដោយឱ្យដាក់ ឬ មិនឱ្យដាក់ប្រាតិភោគ ។ ប៉ុន្តែ មានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់ឱ្យជននោះប្រគល់អចលនវត្ថុឱ្យអាជ្ញាសាលា ដើម្បីឱ្យថែរក្សាគ្រប់គ្រងបាន ។

២-ក្នុងករណីចេញដីកាសម្រេចដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុល តុលាការអនុវត្តត្រូវសួរជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពបន្ទាន់ចាំបាច់ត្រូវចេញដីកាសម្រេចនោះ ។

៣-បើស្ថានភាពមានការប្រែប្រួល តុលាការអនុវត្តអាចលុបចោល ឬ កែប្រែដីកា

សម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តាមពាក្យសុំបាន ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទោះជានៅមុនពេលដែលត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។

៦-សោហ៊ុយចាំបាច់សម្រាប់ពាក្យសុំ ឬ ការអនុវត្តដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ ។

## កថាភាគទី ២
## លំនាំនៃការលក់

**មាត្រា ៤៣០.-** ការវាយតម្លៃ

១-តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត ។

២-ដើម្បីសុំជំនួយពីអាជ្ញាសាលាយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។

៣-នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ។

៤-បើមានភាពចាំបាច់ អាជ្ញាសាលាដែលអ្នកវាយតម្លៃបានសុំជាជំនួយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) នៃក្រមនេះ អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន នៅក្នុងករណីដែលអ្នកវាយតម្លៃចូលទៅកាន់អចលនវត្ថុ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ។

៥-អ្នកវាយតម្លៃត្រូវដាក់ជូនតុលាការអនុវត្តជាលាយល័ក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ ។

**មាត្រា ៤៣១.-** សិទ្ធិដែលនឹងបន្តអត្ថិភាព និង សិទ្ធិដែលត្រូវរលត់ក្រោយការលក់

១-ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួលដែលមានលើអចលនវត្ថុ ចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន ត្រូវបន្តអត្ថិភាពនៅក្រោយការលក់ ។

២-សិទ្ធិលើអចលនវត្ថុ ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ដោយសារការលក់ ។

៣-ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលពាក់ព័ន្ធនឹងអចលនវត្ថុ និង ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលពុំអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបាត់បង់អានុភាព ដោយសារការលក់ ។

៤-មុនពេលដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ បើបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានរាយការណ៍ថា ការព្រមព្រៀងដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ត្រូវបានធ្វើឡើង ការប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ដោយការលក់ ត្រូវអាស្រ័យតាមការព្រមព្រៀងនោះ ។

**មាត្រា ៤៣២.-** ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍

១-តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ។

២-បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្ដូរតម្លៃលក់អប្បបរមាបាន ។

**មាត្រា ៤៣៣.-** ការលក់សរុប

បើយល់ឃើញថាជាការសមរម្យក្នុងការឱ្យអ្នកទិញណាមួយ ទិញសរុបតែម្ដងនូវអចលនវត្ថុ ជាមួយនឹងអចលនវត្ថុផ្សេងទៀត ដោយយោងតាមទំនាក់ទំនងគ្នាក្នុងការប្រើប្រាស់ ទោះបីជាអចលនវត្ថុនីមួយៗនោះមានម្ចាស់បំណុលនៃការអនុវត្តផ្សេងគ្នា ឬ កូនបំណុល

ដើម្បីបើកទ្វារដែលបិទបាន ។

**មាត្រា ៤៣៥.–** វិធានការក្នុងករណីដែលមានការបារម្ភថាគ្មានសំណល់

១-ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។

២-តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើម្ចាស់បំណុលនៃការអនុវត្ត មិនបានធ្វើសកម្មភាពដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-សំណើថា ខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ក្នុងករណីដែលគ្មានសំណើទិញក្នុងតម្លៃដែលឡើងដល់តម្លៃស្នើសុំនោះ ។ ប៉ុន្តែ សំណើនោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយតម្លៃស្នើសុំនោះ ត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ។

ខ-ការដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំដែលបានកំណត់នៅក្នុងចំណុច ក ខាងលើនេះ ។

## កថាភាគទី ៣
## វិធីលក់

**មាត្រា ៤៣៦.–** វិធីលក់ ជាអាទិ៍

១-ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

២-តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

៣-ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុ-វត្តការលក់នោះ ។

៤-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។

៥-បញ្ញត្តិនៃមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៣៧.–** ការធានាលើសំណើទិញ

១-ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ (មួយភាគដប់) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួននេះបាន ។

២-ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក្រោយពេលបញ្ចប់ការលក់ដែលធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ (វិធីលក់ជាអាទិ៍) នៃក្រមនេះ ។

**មាត្រា ៤៣៨.–** ការហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើសំណើទិញ

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ ។

**មាត្រា ៤៣៩.–** ការកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ជាអាទិ៍

១-បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើសុំទិញ ក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

២-បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា

មានច្រើននាក់ អាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីនេះ អ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

៣-បើអ្នកដេញថ្លៃដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនដេញថ្លៃម្តងទៀតទេ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដេញថ្លៃដោយស្រោមសំបុត្រដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមា មានច្រើននាក់ នៅក្នុងការលក់ឡាយឡុងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នោះ ។

៤-បើបានអនុវត្តការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ដែលសរសេរនូវចំណុចដូចខាងក្រោម ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម:

ក-សញ្ញាណនៃអចលនវត្ថុ ។

ខ-កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

គ-សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង អ្នកតំណាង ។

ឃ-តម្លៃទិញរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ង-ហេតុការណ៍នោះ និង ស្ថានភាព បើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ច-មូលហេតុ និង វិធានការដែលបានចាត់ធ្វើ បើបានចាត់វិធានការដែលបានកំណត់នៅក្នុងមាត្រា ៣៩៦ (ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់) នៃក្រមនេះ ។

៥-អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាង ចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

**មាត្រា ៤៤០.-** កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់

១-តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ។

២-នៅពេលដែលបានកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលា-

ការអនុវត្តត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ៤៤១.–** ការថ្លែងយោបល់អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

បុគ្គលដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់អចលនវត្ថុ អាចថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ២ មាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ដែលបណ្ដាលឱ្យមានឥទ្ធិពលដល់សិទ្ធិរបស់ខ្លួន នៅក្នុងកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់បាន ។

**មាត្រា ៤៤២.–** ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ ។

២-តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ បើទទួលស្គាល់ថា មានហេតុណាមួយដូចកំណត់ក្នុងចំណុចខាងក្រោមនេះ :

ក-មិនត្រូវចាប់ផ្ដើម ឬ បន្តនីតិវិធីនៃការលក់ដោយបង្ខំ ។

ខ-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬ សមត្ថភាពដើម្បីទិញអចលនវត្ថុ ឬ អ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានសិទ្ធិនោះ ។

គ-មានសេចក្ដីស្នើសុំកុំឱ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៤៥ (ការស្នើសុំកុំឱ្យអនុញ្ញាតការលក់ ជាអាទិ៍ ក្នុងករណីដែលអចលនវត្ថុត្រូវបានខូចខាត) នៃក្រមនេះ ។

ឃ-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ។

ង-មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់ ។

**មាត្រា ៤៤៣.–** វិធានការក្នុងករណីលក់ហួសកម្រិត

១-ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើន ក្នុងចំណោមអចលនវត្ថុទាំងអស់នោះ ត្រូវបានប៉ាន់ប្រមាណឃើញថា អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់

បានតុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឱ្យលក់អចលនវត្ថុផ្សេងទៀត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានអចលនវត្ថុច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃអចលនវត្ថុនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន ឬ បើសមាយោគនៃអចលនវត្ថុមានច្រើនដែលត្រូវបានប៉ាន់ប្រមាណថា តម្លៃស្នើសុំទិញនៃសមាយោគនីមួយៗនោះ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន តុលាការអនុវត្តត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុន អំពីអចលនវត្ថុដែលត្រូវអនុញ្ញាតឱ្យលក់ ។

៣-អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានៃអចលនវត្ថុដែលដីកាសម្រេចអនុញ្ញាតឱ្យលក់ត្រូវបានបម្រុងទុក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលសំណើទិញនោះ ដោយជូនដំណឹងទៅតុលាការអនុវត្តបាន ។

៤-បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុដែលមានដីកាសម្រេចអនុញ្ញាតឱ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ ដែលទាក់ទងនឹងអចលន-វត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។

**មាត្រា ៤៤៤.–** បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់

១-ចំពោះដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យមានខូចខាតដល់សិទ្ធិរបស់ខ្លួន ។

២-បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឱ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ នៃមាត្រា ៤៤២ (ការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់) នៃក្រមនេះ ឬ កំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ មកធ្វើជាមូលហេតុ ។

៣-បើទទួលស្គាល់ថាចាំបាច់ តុលាការនៃបណ្តឹងជំទាស់ អាចកំណត់ភាគីម្ខាងទៀតនៃម្ចាស់បណ្តឹងជំទាស់បាន ។

៤-ដីកាសម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់នេះ ពុំមានអានុភាពឡើយ បើមិន

ក្រោយការលក់) នៃក្រមនេះ បើកូនបំណុលនៃការអនុវត្ត ជាកូនបំណុលនៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគទាំងនេះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសង នូវសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសិទ្ធិប្រាតិភោគ ដែលនឹងបន្តអត្ថិភាពក្រោយការលក់ ជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកទិញត្រូវ ទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានា បំណុលអណ្តែតនោះ ក្នុងកម្រិតនៃចំនួនអតិបរមា ។

**មាត្រា ៤៥០.-** ដីកាសម្រេចបង្គាប់ឱ្យប្រគល់អចលនវត្ថុ

១-តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឬ អ្នក កាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះទៅឱ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែល បានបង់ថ្លៃលក់ហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវ បានទទួលស្គាល់ថា កាន់កាប់អចលនវត្ថុនោះ ដោយផ្អែកលើសិទ្ធិដែលអាចតតាំងជាមួយ នឹងអ្នកទិញ ដោយយោងទៅតាមសំណុំរឿងនៃការអនុវត្តដោយបង្ខំ ។

២-បើហួសអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ ហើយ អ្នកទិញនោះ ពុំអាចដាក់ពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ។

៣-ក្នុងករណីដែលបានចេញដីកាសម្រេចចំពោះអ្នកកាន់កាប់ ក្រៅពីកូនបំណុលនៃ ការអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអនុវត្តត្រូវសួរជននោះ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះ អាចប្តឹងជំទាស់បាន ។

៥-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុ- ភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៥១.-** អានុភាពនៃការមិនបង់ថ្លៃលក់

១-បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នោះ នឹងបាត់បង់ អានុភាព ។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឱ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជា

ចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ។

## ផ្នែកទី ៦
## នីតិវិធីចែកចំណែកដោយតុលាការ

**មាត្រា ៤៨៧.–** តុលាការដែលត្រូវអនុវត្តការចែកចំណែក

តុលាការដែលត្រូវអនុវត្តការចែកចំណែក គឺសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅចំពោះការអនុវត្តដោយបង្ខំ ចំពោះចលនវត្ថុ ឬ តុលាការអនុវត្ត ចំពោះករណីផ្សេងទៀត ។

**មាត្រា ៤៨៨.–** ការរៀបចំការចែកចំណែក

១-បើមានមូលហេតុដែលចែងនៅចំណុចនីមួយៗខាងក្រោម តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និង ទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និង កូនបំណុល :

ក-ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពេលដែលមូលហេតុនៃការផ្ញើប្រាក់បានរលត់ ក្នុងករណីដែលមានការជូនដំណឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤០០ (ការផ្ញើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬ ពេលដែលមានការជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនេះ ។

ខ-ក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ពេលដែលបានធ្វើការផ្ញើប្រាក់ តាមបញ្ញត្តិនៃមាត្រា ៤១២ (បណ្តឹងទាមទារប្រមូលបំណុល) ឬ ពេលដែលបានធ្វើការលក់ ដោយដីកាសម្រេចបង្គាប់ឱ្យលក់ តាមបញ្ញត្តិនៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឱ្យលក់) ឬ ពេលដែលប្រាក់ដែលបានមកពីការលក់ ត្រូវបានប្រគល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១៤ (ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ ។

គ-ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬ ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា ៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ ។

**មាត្រា ៤៩០.-** ការធ្វើតារាងចែកចំណែក

១-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើតារាងចែកចំណែក នៅកាលបរិច្ឆេទនៃការចែកចំណែកនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៨៩ (ការអនុវត្តការចែកចំណែក) នៃក្រមនេះ ។

២-នៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការត្រូវកោះហៅម្ចាស់បំណុលដែលបានកំណត់ខាងក្រោមនេះ និង កូនបំណុលនៃការអនុវត្ត:

ក-ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៣៩៨ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកជាប្រាក់) នៃក្រមនេះ ។

ខ-ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤១៥ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

គ-ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៥៣ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

ឃ-ករណីអនុវត្តដោយបង្ខំចំពោះនាវា : ម្ចាស់បំណុលដែលបានកំណត់នៅក្នុងមាត្រា ៤៨៦ (វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក) នៃក្រមនេះ ។

៣-ពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែក តុលាការអាចសួរម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។

៤-នៅលើតារាងចែកចំណែក ទន្ទឹមគ្នានឹងចំនួនទឹកប្រាក់ខាងក្រោមនេះ តុលាការត្រូវសរសេរអំពីចំនួនប្រាក់ដើម ការប្រាក់ សិទ្ធិលើបំណុលបន្ទាប់បន្សំផ្សេងៗនៃសិទ្ធិលើបំណុល សោហ៊ុយសម្រាប់ការអនុវត្ត និង លំដាប់និងចំនួនទឹកប្រាក់នៃការចែកចំណែក:

ក-ករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ : ចំនួនទឹកប្រាក់បានមកពីការលក់វត្ថុ ដែលត្រូវបានរឹបអូស និង ចំនួនទឹកប្រាក់ដែលត្រូវបានរឹបអូស ។

ខ-ករណីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត : ចំនួនទឹកប្រាក់ដែលត្រូវអនុវត្តការចែកចំណែក ។

គ-ករណីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ៖ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

ឃ-ករណីអនុវត្តដោយបង្ខំចំពោះនាវា ៖ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ ។

៥-លំដាប់ និង ចំនួនទឹកប្រាក់នៃការចែកចំណែក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវសរសេរតាមការព្រមព្រៀង ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នៅកាលបរិច្ឆេទនៃការចែកចំណែក ឯក្នុងករណីផ្សេងទៀត ត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត ។

៦-ពាក់ព័ន្ធនឹងការចែកចំណែក សិទ្ធិលើបំណុលដែលពេលកំណត់ពិតប្រាកដពុំទាន់ឈានចូលមកដល់ ត្រូវចាត់ទុកថា ពេលកំណត់សងបានចូលមកដល់ ។

**មាត្រា ៤៩១.-** ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យ ចំពោះសិទ្ធិលើបំណុល ឬ ចំនួនប្រាក់ចំណែក របស់ម្ចាស់បំណុលម្នាក់ៗដែលត្រូវបានសរសេរលើតារាងចែកចំណែក អាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក ។

២-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកតែផ្នែកដែលគ្មានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ។

៣-ជាលទ្ធផលនៃការអនុវត្តការចែកចំណែក បើម្ចាស់បំណុលនៃការអនុវត្ត ឬ ម្ចាស់បំណុលដែលបានទាមទារចំណែក ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត បានទទួលនូវចំណែកគ្រប់ចំនួននៃសិទ្ធិលើបំណុល នោះកូនបំណុលនៃការអនុវត្តអាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តដែលម្ចាស់បំណុលនោះបានផ្តល់ ។

៤-លើកលែងតែករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ កាលដែលរឿងក្តីបានបញ្ចប់ហើយ ម្ចាស់បំណុលដែលបានកំណត់នៅកថាខណ្ឌទី ៣ នោះ អាចទាមទារឱ្យក្រឡាបញ្ជីប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តបាន ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលនោះជាជនដែលបានទទួលចំណែកនៃសិទ្ធិលើបំណុលតែមួយ

ផ្នែក ក្រឡាបញ្ជីត្រូវប្រគល់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយចារនូវចំនួននៃចំណែកដែលម្ចាស់បំណុលនោះ បានទទួលលើឯកសារនោះ ។

**មាត្រា ៤៩២.-** បណ្តឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-ម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្តឹងតវ៉ា ចំពោះការសរសេរលើតារាងចែកចំណែក ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

២-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការចែកចំណែក ។

៣-បើម្ចាស់បំណុលដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថា បានដកវិញ ។

៤-ក្នុងសាលក្រមនៃបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។

**មាត្រា ៤៩៣.-** បណ្តឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

១-កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

២-កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ចំពោះម្ចាស់បំណុលដែលគ្មានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

ដោយយកម្ចាស់បំណុលដែលជាភាគីម្ខាងទៀតនៃការស្នើសុំតវ៉ាជាចុងចម្លើយ ។

៣-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការចែកចំណែក ។

៤-បើកូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្តីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទៅតុលាការ ហើយមិនផ្តល់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចបង្គាប់ឱ្យផ្អាកការអនុ-វត្តដែលទាក់ទងនឹងបណ្តឹងរបស់ខ្លួន ទៅតុលាការ ឬ មិនបញ្ជាក់ថា ខ្លួនបានដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ទៅតុលាការ ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកត្រូវចាត់ទុកថា បានដកវិញ ។

៥-ក្នុងសាលក្រមនៃបណ្តឹងដែលបានកំណត់នៅកថាខណ្ឌទី ១ បើយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវ តុលាការដែលត្រូវអនុវត្តការចែកចំណែកត្រូវធ្វើការផ្លាស់ប្តូរតារាងចែកចំណែក ឬ លុបចោលតារាងចែកចំណែកដើម្បីធ្វើតារាងចែកចំណែកថ្មី ។

**មាត្រា ៤៩៤.-** ការផ្អាកទុកចំនួនប្រាក់ចំណែក

១-ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលត្រូវទទួលចំណែក បើមានមូលហេតុដូចខាងក្រោមនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែកនោះ :

ក-សិទ្ធិលើបំណុលនោះភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬ ពេលកំណត់មិនពិតប្រាកដ ។

ខ-សិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្តោះអាសន្ន ។

គ-ឯកសារដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៣៧០ (ការផ្អាក និង លុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវបានផ្តល់ ។

ឃ-ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចហាមឃាត់មួយរយៈនូវការអនុវត្តឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែកដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ ត្រូវបានផ្តល់ ។

ង-ពាក្យបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩២ (បណ្ដឹងតវ៉ារបស់ម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) ឬ កថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែក ចំណែក) នៃក្រមនេះ ។

២-តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវផ្អាកទុកទឹកប្រាក់ដែលស្មើនឹងចំនួននៃចំណែករបស់ម្ចាស់បំណុលដែលពុំបានបង្ហាញខ្លួនចំពោះមុខតុលាការដើម្បីទទួលចំណែកនោះ ។

**មាត្រា ៤៩៥.–** ការអនុវត្តការចែកចំណែក ដោយការសម្រេចសិទ្ធិជាស្ថាពរ ជាអាទិ៍

១-ក្នុងករណីដែលការផ្អាកទុកត្រូវបានអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ បើហេតុនៃការផ្អាកទុកនោះបានរលត់ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកចំពោះប្រាក់ផ្អាកទុកនោះ ។

២-ក្នុងករណីដែលត្រូវអនុវត្តការចែកចំណែក តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការផ្លាស់ប្ដូរតារាងចែកចំណែក ដើម្បីម្ចាស់បំណុលដែលមិនបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកផងដែរ បើត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-បើមិនអាចធ្វើការចែកចំណែកបាន ចំពោះម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ចំណុច ឃ នៃកថាខណ្ឌ ទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) នៃក្រមនេះ ។

ខ-បើម្ចាស់បំណុលដែលត្រូវបានផ្អាកទុកចំណែក ដោយមានហេតុដែលបានកំណត់នៅក្នុងចំណុច ង នៃកថាខណ្ឌទី ១ មាត្រា ៤៩៤ (ការផ្អាកទុកចំនួនប្រាក់ចំណែក) បានចាញ់ក្ដីក្នុងបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ដែលកូនបំណុលនៃការអនុវត្តបានដាក់ពាក្យ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៩៣ (បណ្ដឹងតវ៉ារបស់កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក) នៃក្រមនេះ ។

# ជំពូកទី ៣
# បទប្បញ្ញត្តិពិសេសស្តីពីការអនុវត្តសិទ្ធិប្រាតិភោគ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.–** លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

ទោះបីមានបញ្ញត្តិនៃមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះក៏ដោយ ក៏ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើង ដោយលិខិតអនុវត្តដែលបានកំណត់ខាងក្រោមនេះ :

ក-សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ ។

ខ-លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ។

**មាត្រា ៤៩៧.–** បញ្ញត្តិពិសេសស្តីពីសមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះការទាមទារ និងបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដែលពាក់ព័ន្ធនឹងលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ

១-ទោះបីមានបញ្ញត្តិនៃមាត្រា ៣៦៣ (បណ្តឹងតវ៉ាចំពោះការទាមទារ) នៃក្រមនេះក៏ដោយ បណ្តឹងតវ៉ាចំពោះការទាមទារដែលពាក់ព័ន្ធនឹងលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលបានកំណត់នៅក្នុងចំណុចនីមួយៗតាមប្រភេទនៃលិខិតអនុវត្តដែលបែងចែកដូចខាងក្រោមនេះ :

ក-ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ក នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : សាលាដំបូងដែលបានធ្វើនីតិវិធីនៃបណ្តឹងនោះ ។

ខ-ចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ខ នៃមាត្រា ៤៩៦ (លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ : តុលាការមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់

ចំពោះអចលនវត្ថុ ឬ ការអនុវត្តសិទ្ធិប្រាតិភោគដែលមានដំណើរការមុន) នៃក្រមនេះ នៅពេលកំណត់តម្លៃលក់អប្បបរមា និង ធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្តត្រូវពិចារណាអំពីការរលត់នៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំក្រោយ និង សិទ្ធិប្រាតិភោគផ្សេង សិទ្ធិប្រត្យក្សប្រើប្រាស់និងអាស្រ័យផល និង សិទ្ធិជួល ដែលមិនអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើមានភាពចាំបាច់ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ឬ ធ្វើឯកសារលំអិតអំពីវត្ថុឡើងវិញ ។

**មាត្រា ៥១៥.–** ការចាត់ចែងក្នុងករណីដែលមានពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគក្រោយពេលដែលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ បានចាប់ផ្តើម

១-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្ត សិទ្ធិប្រាតិភោគ ត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្តើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិប្រាតិភោគនោះ មិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តមុនបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១២ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តសិទ្ធិប្រាតិភោគ) នៃក្រមនេះ បើពាក្យសុំឱ្យលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានដាក់ ក្រោយពេលកាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្នុងនីតិវិធីអនុវត្តដោយបង្ខំមុន បានចាប់ផ្តើម តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនោះ ហើយព្រមជាមួយគ្នានេះ ត្រូវផ្អាកនីតិវិធីលក់ដោយបង្ខំក្រោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិន

**មាត្រា ៥៤២.–** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.–** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.–** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.–** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.–** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

## ជំពូកតែមួយ

## អវសានប្បញ្ញត្តិ

**មាត្រា ៥៨៧.–** ការអនុវត្តក្រមនេះ

ក្រោយពីចូលជាធរមាន ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល ១ (មួយ) ឆ្នាំ ទើបអនុវត្ត ។

**មាត្រា ៥៨៨.–** ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេង ជាអាទិ៍

១-ច្បាប់ដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត :

ក-ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥១ ក្រ ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

ខ-ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

២-បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦

នស.រកម.០៧០៦.០១០ **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ : ៥៨៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............. អាយុ......ឆ្នាំ មានអាសយដ្ឋាននៅ ............រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សុំលក់ដោយបង្ខំនូវដីដែលមានវិញ្ញាបនបត្រលេខ...ចុះថ្ងៃទី...ខែ... ឆ្នាំ... ដែលជា កម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ................. ភេទ... អាយុ...ឆ្នាំ មានអាសយដ្ឋាននៅ ......................រាជធានីភ្នំពេញ ។

**យោង** ៖ សាលក្រម..........................................

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា ខ្ញុំបាទគឺជាម្ចាស់បំណុលនៃការ អនុវត្តមានសិទ្ធិលើបំណុលចំពោះកូនបំណុលចំនួន ២០.០០០ (ពីរម៉ឺនដុល្លាអាមេរិក) ដូចមានលម្អិតនៅក្នុងឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ប៉ុន្តែកូនបំណុលនៅតែមិនព្រមសងប្រាក់តាម ការទាមទារទៀត ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាចាប់ផ្តើមលក់ដោយបង្ខំទៅលើអចលនវត្ថុដែលជាកម្មសិទ្ធិ របស់កូនបំណុលដោយក្តីអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ .............. ឆ្នាំ ....................

**ស្នាមមេដៃម្ចាស់បំណុលនៃការអនុវត្ត**

**ជូនភ្ជាប់មកជាមួយនូវ៖**

| | |
|---|---|
| ១-អនុសារសាលក្រមដែលមានអនុភាពអនុវត្ត | ០១ច្បាប់ |
| ២-លិខិតបញ្ជាក់ស្នាក់នៅ | ០១ច្បាប់ |
| ៣-ឯកសារស្តីពីអត្តសញ្ញាណកម្មវត្ថុ | ០១ច្បាប់ |

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ

លេខ .......

យើង ...................................... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ: មាត្រា ៥១៩-១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញ: សំណុំរឿងអនុវត្តលេខ ..... ចុះថ្ងៃទី.... ខែ........ ឆ្នាំ........... របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ: ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ចុះថ្ងៃទី..... ខែ.... ឆ្នាំ........ របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ........ ភេទ... អាយុ......ឆ្នាំ ។

បានឃើញ: សាលក្រមរដ្ឋប្បវេណីលេខ .... ចុះថ្ងៃទី... ខែ.... ឆ្នាំ........ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ: លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមលេខ ....... ចុះថ្ងៃទី....... ខែ......... ឆ្នាំ............. របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ: រូបមន្តអនុវត្តសាលក្រមលេខ ............... ចុះថ្ងៃទី..... ខែ........ ឆ្នាំ........... របស់សាលាដំបូងរាជធានីភ្នំពេញ ។

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ............. ភេទ......... អាយុ......ឆ្នាំ មានទីលំនៅបច្ចុប្បន្ន.......................................... រាជធានីភ្នំពេញ ។

ដោយមានលោក .................. ជាមេធាវីតំណាងដោយអាណត្តិ ។

កូនបំណុលនៃការអនុវត្តឈ្មោះ ......... ភេទ.......... អាយុ......ឆ្នាំ មានទីលំនៅបច្ចុប្បន្ន.....................................រាជធានីភ្នំពេញ ។

សិទ្ធិលើបំណុលដែលទាមទារ:

Scanned with CamScanner

ខ្លឹមសារនៃសាលក្រមដែលទាមទារដោយម្ចាស់បំណុលនៃការអនុវត្តៈ

សុំឲ្យអនុវត្តតាមវិធានបង្ខំដោយផ្ទាល់ ដោយយកដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ..... ក្បាលដីលេខ ... ទំហំ... ម² ចុះថ្ងៃទី..... ខែ....... ឆ្នាំ.... របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅ................................ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ........... ភេទ...... អាយុ......ឆ្នាំ និងប្ដី/ប្រពន្ធឈ្មោះ ............ មានទីលំនៅបច្ចុប្បន្ន........................រាជធានីភ្នំពេញ ដោយផ្អែកលើសាលក្រមរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី....... ខែ....... ឆ្នាំ.......... របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចដូចខាងក្រោមៈ

១-..............................

២-..............................

**ហេតុដូច្នេះសម្រេច**

១-ចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំ ។

២-រឹបអូសដី និង ផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .... ក្បាលដីលេខ .. ទំហំ ..... ម² ចុះថ្ងៃទី...... ខែ....... ឆ្នាំ... ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅ........................................ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ..............ភេទ..... អាយុ...ឆ្នាំ និងប្ដី/ប្រពន្ធឈ្មោះ .................... ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ......... ឆ្នាំ.............

**ចៅក្រម**

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ .....

# លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូស

យើង ........................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**សូមជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ**

**កម្មវត្ថុ:** ការផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសដូចមានបញ្ជាក់ដូចខាងក្រោម:

ក-អត្តសញ្ញាណនៃអចលនវត្ថុ: ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ........... ក្បាលដីលេខ ....... ទំហំ ....... ម$^2$ ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅ........................................... រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ......... ភេទ... អាយុ...ឆ្នាំ និងប្តី/ប្រពន្ធឈ្មោះ ................. ។

ខ-ឈ្មោះកម្មសិទ្ធិករ: ឈ្មោះ ......... ភេទ... អាយុ...ឆ្នាំ និងប្តី/ប្រពន្ធឈ្មោះ ................. មានទីលំនៅបច្ចុប្បន្នស្នាក់នៅ.................................. រាជធានីភ្នំពេញ ។

គ-គោលបំណងនៃការចុះបញ្ជី: រឹបអូស ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ........... ក្បាលដីលេខ ....... ទំហំ ....... ម$^2$ ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅ.......................................... រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ......... ភេទ... អាយុ...ឆ្នាំ និងប្តី/ប្រពន្ធឈ្មោះ ................. ។

Scanned with CamScanner

ឃ-មូលហេតុ: ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ............. ចុះថ្ងៃទី ... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

ង-ម្ចាស់បំណុលនៃការអនុវត្ត

-ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ................ ភេទ... អាយុ...ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់...................................................................... រាជធានីភ្នំពេញ ។

ដោយមានលោក .................................. ជាមេធាវីតំណាងដោយអាណត្តិ ។

ច-កូនបំណុលនៃការអនុវត្ត

-កូនបំណុលនៃការអនុវត្តឈ្មោះ ................ ភេទ... អាយុ...ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់..................................................................... រាជធានីភ្នំពេញ ។

ដោយមានលោក .................................. ជាមេធាវីតំណាងដោយអាណត្តិ ។

ឯកសារភ្ជាប់មកជាមួយ:

១-ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ .....ចុះថ្ងៃទី ... ខែ... ឆ្នាំ.... របស់សាលាដំបូងរាជធានីភ្នំពេញ ។

២-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ... ក្បាលដីលេខ ... ទំហំ ... ម$^2$ ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។ (ថតចម្លងមួយច្បាប់)

រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ... ឆ្នាំ..........

ក្រឡាបញ្ជី

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍បញ្ជូន

*ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី*

កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី....................ខែ........................ឆ្នាំ.............................................

លេខសំណុំរឿង :..............................................................................................................

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : **ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ**

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន :.......................................................................

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន :................................................................................

*ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង :*..........................................................

*ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន ( កញ្ញាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី )*

| | |
|---|---|
| ទីកន្លែងដែលធ្វើការបញ្ជូន :................................................................................. | |
| កាលបរិច្ឆេទនៃការបញ្ជូន :<br>ថ្ងៃទី.........................ខែ...........................ឆ្នាំ.....................ម៉ោង...............................ព្រឹក/រសៀល | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ១ | ☐ បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ដល់ជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |

Scanned with CamScanner

| | |
|---|---|
| ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ<br>☐ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូន ដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ :.................................................................................................................................... |
| ៣ | ☐ ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន<br>ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ :.................................................................................................................................... |
| ☐ *ខ្ញុំបានបញ្ជូនឯកសារដូចនីតិវិធីខាងលើ* | |
| ☐ *ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែល មានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។* | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី......................ខែ...........................ឆ្នាំ...................... | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ :.................................................................................... | |

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

# ដីកាបង្គាប់ឲ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ

យើង ............................... ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា៤៣៤-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ សំណុំរឿងអនុវត្តលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន ៖

ម្ចាស់បំណុលនៃការអនុវត្ត ៖ ...........................................................................

កូនបំណុលនៃការអនុវត្ត ៖...............................................................................

បានឃើញ ពាក្យសុំអនុវត្តដោយបង្ខំចុះថ្ងៃទី... ខែ... ឆ្នាំ... ។

បានឃើញ ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំលេខ ... ចុះថ្ងៃទី ........ ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

## ហេតុដូច្នេះសម្រេច

បង្គាប់ឲ្យមន្ត្រីអាជ្ញាសាលា ចុះធ្វើការស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ អំពីទំនាក់ទំនង និងការកាន់កាប់ព្រមទាំងស្ថានភាពផ្សេងៗនៃអចលនវត្ថុដែលមានវិញ្ញាបនប័ត្រលេខ ........ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... មានទីតាំងស្ថិតនៅ........................................................ ......................... រាជធានីភ្នំពេញ ។

បន្ទាប់ពីចុះធ្វើការស្រាវជ្រាវរួចមក សូមផ្ញើលទ្ធផល មកសាលាដំបូងរាជធានីភ្នំពេញវិញឲ្យឆាប់តាមលទ្ធភាពអាចធ្វើបាន ។

ក្នុងករណីមានឧបសគ្គរាំងនៃការអនុវត្តនេះ មន្ត្រីអាជ្ញាសាលា ត្រូវប្រើកំលាំងមានសមត្ថកិច្ចដើម្បីអនុវត្តឲ្យបានសម្រេច ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ......... ឆ្នាំ..............

**ចៅក្រម**

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

## ដីកាបង្គាប់ឲ្យវាយតម្លៃ

យើង ........................................ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ មាត្រា ៤៣០-១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦។

បានឃើញ សំណុំរឿងអនុវត្តលេខ... ចុះថ្ងៃទី...ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ......... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីរឹបអូសលេខ........ ចុះថ្ងៃទី ... ខែ... ឆ្នាំ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

## ហេតុដូច្នេះសម្រេច

ចាត់តាំងក្រុមហ៊ុន ......................... ដែលមានអសយដ្ឋាននៅ............................ ឲ្យធ្វើការវាយតម្លៃអចលនវត្ថុដែលមានវិញ្ញាបនប័ត្រលេខ........ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... មានទីតាំងស្ថិតនៅ.......................... រាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់ ឈ្មោះ....................... បន្ទាប់ពីវាយតម្លៃរួចហើយ សូមផ្ញើរបាយការណ៍នេះមកតុលាការដើម្បីចាត់តាមច្បាប់ ។

រាជធានីភ្នំពេញ,ថ្ងៃទី .... ខែ......... ឆ្នាំ.............

**ចៅក្រម**

Scanned with CamScanner

